20 ខួបលើកទី
CDRI 1990-2010
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ចំណាកស្រុក របស់ យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា





ឯកសារពិភាក្សាលេខ ៣៦

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

ឧសភា ២០១០

# ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា

## ឯកសារពិភាក្សាលេខ ៣៦

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

*ចុះកិច្ចសន្យាអោយអនុវត្តដោយ*

**អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន**

**ខែឧសភា ឆ្នាំ២០១០**

© **រក្សាសិទ្ធិឆ្នាំ២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក រឺផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN: 978-99950-52-06-5

**ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅប្រទេសកម្ពុជា**
ខែឧសភា ឆ្នាំ២០១០

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI)
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@wicam.com.kh
គេហទំព័រ: http://www.cdri.org.kh

កែសម្រួល និងរចនាដោយ: ម៉ែន-ច័ន្ទធីតា អ៊ុំ-ចាន់ថា និង យូ-សិទ្ធីរិទ្ធ
បកប្រែដោយ: ខេង សេង និង អ៊ឹង សុជាតិ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព T & S ភ្នំពេញ

# មាតិកា


សម្រង់អត្ថបទ ........ ៧
បញ្ជីក្រាហ្វិក និងតារាង ........ ៩
បញ្ជីអក្សរកាត់ ........ ១១
សេចក្ដីថ្លែងអំណរគុណ ........ ១៣

ជំពូកទី ១. សេចក្ដីផ្ដើម និងការពិនិត្យជារួម ........ ១៥

១.១. សាវតារ និងមូលហេតុ ........ ១៥
១.២. គោលដៅការស្រាវជ្រាវ ........ ១៦
១.៣. វិធីសាស្ត្រស្រាវជ្រាវ ........ ១៧
១.៤. ការកំណត់គំរូតាង ........ ១៧

ជំពូកទី ២. ប្រជាជន និងចំណាកស្រុក ........ ២១

២.១. ទ្រឹស្ដីពលកម្មចំណាកស្រុក ........ ២១
២.២. ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម ........ ២៣
២.៣. សាវតារសេដ្ឋកិច្ច-សង្គមកិច្ច នៃគ្រួសារយុវជនចំណាកស្រុក ........ ២៤
២.៤. លក្ខណៈសំគាល់នៃយុវជនពលករចំណាកស្រុក ........ ២៥
២.៥. ចំណាកស្រុកតាមរដូវ រឺជាអចិន្ត្រៃយ៍? ........ ២៩
២.៦. មូលហេតុនៃការធ្វើចំណាកស្រុក ........ ២៩

ជំពូកទី ៣. បណ្ដាញសង្គម និងចំណាកស្រុក ........ ៣១

៣.១. ប្រភពព័ត៌មាន ........ ៣១
៣.២. ការធ្វើដំណើរតែម្នាក់ឯង រឺមានគ្នា ........ ៣២
៣.៣. ការចំណាយ ........ ៣៣
៣.៤. បន្ទុកចំណាយពាក់ព័ន្ធនឹងចំណាកស្រុក ........ ៣៣
៣.៥. ប្រភពហិរញ្ញវត្ថុ ........ ៣៤

ជំពូកទី ៤. សមាហរណកម្មចូលក្នុងបរិយាកាសទីក្រុង ..... ៣៥

៤.១. ការចូលរួមក្នុងសកម្មភាពសង្គមនៅពេលទំនេរ ..... ៣៥
៤.២. ប្រភេទនៃការស្នាក់នៅ ..... ៣៦
៤.៣. អ្នករួមបន្ទប់ ..... ៣៧
៤.៤. ការបណ្តុះបណ្តាលជំនាញ និងរយៈពេល ..... ៣៨
៤.៥. លទ្ធភាពទទួលបានការថែទាំសុខភាព ..... ៣៨
៤.៦. បញ្ហាប្រឈម និងការលំបាក ..... ៣៩
៤.៧. ការដោះស្រាយបញ្ហា និងកិច្ចការពារខាងសង្គមកិច្ច ..... ៤១

ជំពូកទី ៥. បន្ទុកចំណាយ និងផលប្រយោជន៍នៃចំណាកស្រុក ..... ៤៣

៥.១. ការងារនៅតំបន់ទីក្រុង ..... ៤៣
៥.២. លក្ខខណ្ឌការងារ ..... ៤៥
៥.៣. លក្ខខណ្ឌរកប្រាក់ចំណូល និងការរស់នៅ ..... ៤៧

ជំពូកទី ៦. ផលប៉ះពាល់លើគ្រួសារ និងសហគមន៍របស់យុវជនចំណាកស្រុក ..... ៥១

៦.១. ប្រាក់ផ្ញើមកផ្ទះ ..... ៥១
៦.២. ចំណងទាក់ទងជាមួយគ្រួសារ និងសហគមន៍អ្នកបញ្ជូន ..... ៥៧

ជំពូកទី ៧. សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ ..... ៦១

ឯកសារយោង ..... ៦៥

ឧបសម្ព័ន្ធ ..... ៦៧

បញ្ជីឯកសារពិភាក្សារបស់ វបសអ ..... ៧១

# សម្រង់អត្ថបទ

ចាប់តាំងពីចុងទសវត្សរ៍១៩៩០ យុវជននៅជនបទកម្ពុជា បានធ្វើចំណាកស្រុកមកកាន់ទីក្រុង ដើម្បីរកការងារធ្វើកាន់តែច្រើនឡើង ដោយសារប្រទេសកម្ពុជា បានបើកចំហសេដ្ឋកិច្ចទីផ្សារសេរី និងមានកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ ។ ការផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត រមែងមានហានិភ័យ ជាពិសេសចំពោះកម្មករវ័យក្មេង ដោយពួកគេភាគច្រើនពុំធ្លាប់ចាកចេញឆ្ងាយពីភូមិកំណើតសោះ ហើយពួកគេថែមទាំងមានការអប់រំមូលដ្ឋានទាប និងគ្មាន វិមានជំនាញតិចតួចប៉ុណ្ណោះ ។ ពិតហើយមានហេតុផលជាក់ស្តែងមួយចំនួន ដែលធ្វើអោយយុវជនជាច្រើនចាកចេញពីជនបទមកកាន់ទីក្រុង ។ ប៉ុន្តែនៅមិនទាន់មានការស្វែងយល់អោយស៊ីជម្រៅនៅឡើយទេ អំពីដំណើរការចំណាកស្រុក ទំនាក់ទំនង លក្ខខណ្ឌរស់នៅនិងការងារ បញ្ហាប្រឈម និងការលំបាករបស់ពួកគេ រឺក៏ផលប៉ះពាល់នៃប្រាក់ផ្ញើមកផ្ទះ និងចំណាកស្រុក ទៅលើក្រុមគ្រួសារ និងសហគមន៍ ។ ការសិក្សាមានគោលដៅបំពេញនូវកង្វះខាតចំណេះដឹងទាំងនេះ តាមរយៈគោលបំណងជាក់លាក់ចំនួន ៥ (ក) ស្វែងយល់ពីសាវតារខាងសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារយុវជនចំណាកស្រុក (ខ) កំណត់ពីកត្តា និងកាលៈទេសៈ ដែលជំរុញអោយមានចំណាកស្រុក និងស្វែងយល់ពីបែបបទដែលយុវជនធ្វើការសម្រេចចិត្តធ្វើចំណាកស្រុក (គ) ពិនិត្យមើលពីតួនាទីនៃបណ្តាញសង្គមនៅក្នុងការជួយសម្រួលដល់ការធ្វើចំណាកស្រុក (ឃ) កំណត់ពីប្រភេទការងារផ្សេងៗនៅទីក្រុងសម្រាប់យុវជនចំណាកស្រុក និងការបញ្ចូលខ្លួនពួកគេទៅក្នុងការរស់នៅក្នុងទីក្រុង (ង) ស្វែងយល់ពីទំនាក់ទំនងរបស់ពួកគេជាមួយគ្រួសារដែលបញ្ជូនពួកគេមក និងផលប៉ះពាល់លើភាពក្រីក្រក្នុងគ្រួសារ និងសហគមន៍ពួកគេ ។

ការសិក្សាបង្ហាញថា យុវជនចំណាកស្រុកភាគច្រើន ចេញមកពីគ្រួសារមធ្យម និងក្រីក្រ ។ អ្នកក្រីក្រខ្លាំង ខ្វះនូវមូលធនសង្គម និងហិរញ្ញវត្ថុ សម្រាប់ធ្វើចំណាកស្រុក រីឯអ្នកធូរធារ សម្រេចចិត្តរស់នៅក្នុងភូមិដដែល ដើម្បីជៀសវាងពីហានិភ័យដោយសារចំណាកស្រុក ។ ពលករវ័យក្មេង ច្រើនធ្វើចំណាកស្រុកពីតំបន់ជនបទមកទីក្រុងតាមរយៈច្រក និងបណ្តាញក្រៅផ្លូវការ ហើយបណ្តាញផ្លូវការមិនមានច្រើនទេ ។ ការសិក្សាក៏បានរកឃើញដែរថា ពលករចំណាកស្រុកវ័យក្មេង ជួបប្រទះការលំបាកជាច្រើន ទាំងក្នុងការរស់នៅ និងក្នុងការងារ ។ ទោះជាយ៉ាងណា ពួកគេមិនបានត្អូញត្អែរច្រើនទេ ហើយព្យាយាមជំនះរាល់ការលំបាកទាំងនោះ ។ ទោះបីរស់នៅទីក្រុងច្រើនឆ្នាំហើយក៏ដោយ ពួកគេភាគច្រើននៅតែមិនអាចសម្របខ្លួនជាមួយបរិយាកាសទីក្រុង ប៉ុន្តែអាចសម្របបានជាមួយពលករចំណាកស្រុកឯទៀតៗ ដែលមកពីភូមិជាមួយគ្នា និងពីតំបន់ជនបទដទៃទៀតនៃប្រទេសកម្ពុជា ។ ការសិក្សាក៏បានរកឃើញថា មានចំណងតភ្ជាប់រឹងមាំ រវាងពលករចំណាកស្រុកវ័យក្មេង ជាមួយគ្រួសារ និងសហគមន៍របស់ពួកគេ ។ ពួកគេផ្ញើប្រាក់មកផ្ទះយ៉ាងទៀងទាត់ និងញឹកញាប់ ហើយទៅលេងផ្ទះនៅថ្ងៃបុណ្យសំខាន់ៗ ។ ប្រាក់ផ្ញើមកផ្ទះរបស់ពលករចំណាកស្រុកវ័យក្មេង ត្រូវបានប្រើសម្រាប់តម្រូវការមូលដ្ឋាន ដែលអាចជួយគ្រួសារអោយរួចផុតពីភាពក្រីក្រ ប៉ុន្តែភាគច្រើនមិនអាចធ្វើអោយជីវភាពគ្រួសារប្រសើរខ្លាំងទេ ។

# បញ្ជីក្រាហ្វិក និងតារាង

**បញ្ជីក្រាហ្វិក**


ក្រាហ្វិក ១.១: ចំនួនអ្នកចំណាកស្រុកវ័យក្មេងដែលបានសម្ភាសតាមខេត្តនីមួយៗ.......... ១៩

ក្រាហ្វិក ២.១: សុខុមាលភាពនៃគ្រួសារយុវជនចំណាកស្រុកបានឆ្លើយសម្ភាសន៍.......... ២៤
ក្រាហ្វិក ២.២: ចំនួនឆ្នាំសិក្សារបស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍.......... ២៧
ក្រាហ្វិក ២.៣: ចំនួនពលករចំណាកស្រុកក្នុងមួយគ្រួសារដែលបានសម្ភាស.......... ២៨
ក្រាហ្វិក ២.៤: គោលដៅការងាររបស់សាច់ញាតិយុវជនពលករចំណាកស្រុក.......... ២៨
ក្រាហ្វិក ២.៥: ការងារតាមរដូវ និងអចិន្ត្រៃយ៍របស់យុវជនពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍.......... ២៩
ក្រាហ្វិក ២.៦: មូលហេតុចំបងនៃចំណាកស្រុករបស់យុវជនពលករចំណាកស្រុក.......... ៣០

ក្រាហ្វិក ៣.១: ប្រភពព័ត៌មានពាក់ព័ន្ធនឹងការងារ.......... ៣២
ក្រាហ្វិក ៣.២: អ្នករួមដំណើរជាមួយយុវជនពលករចំណាកស្រុក.......... ៣២
ក្រាហ្វិក ៣.៣: ប្រភពហិរញ្ញវត្ថុសម្រាប់ចំណាយលើការធ្វើដំណើរ
និងរកការងាររបស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍.......... ៣៤

ក្រាហ្វិក ៤.១: អ្នកដែលយុវជនចំណាកស្រុកជួបច្រើនជាងគេនៅពេលទំនេរ.......... ៣៦
ក្រាហ្វិក ៤.២: ការបណ្តុះបណ្តាលជំនាញនៃយុវជនពលករចំណាកស្រុក.......... ៣៨
ក្រាហ្វិក ៤.៣: ការដោះស្រាយបញ្ហា និងកិច្ចការពារខាងសង្គមកិច្ច.......... ៤១

ក្រាហ្វិក ៥.១: ពេលវេលាជាមធ្យមចំណាយនៅទីក្រុង និងលើការងារបច្ចុប្បន្ន.......... ៤៤
ក្រាហ្វិក ៥.២: ចំនួនថ្ងៃធ្វើការក្នុងមួយសប្តាហ៍របស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍.......... ៤៥
ក្រាហ្វិក ៥.៣: ម៉ោងធ្វើការក្នុងមួយថ្ងៃរបស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍.......... ៤៦
ក្រាហ្វិក ៥.៤: ការពេញចិត្តចំពោះការងាររបស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍.......... ៤៦
ក្រាហ្វិក ៥.៥: ការពេញចិត្តចំពោះប្រាក់ចំណូល នៃយុវជនពលករចំណាកស្រុក.......... ៤៨
ក្រាហ្វិក ៥.៦: ការចាកចេញដើម្បីជីវភាពប្រសើរឡើង.......... ៤៩

ក្រាហ្វិក ៦.១: ភាគរយយុវជនពលករចំណាកស្រុកដែលផ្ញើប្រាក់មកផ្ទះ.......... ៥១
ក្រាហ្វិក ៦.២: ភាពញឹកញាប់នៃការផ្ញើប្រាក់មកផ្ទះ.......... ៥២
ក្រាហ្វិក ៦.៣: ចំនួនប្រាក់ផ្ញើមកផ្ទះជាមធ្យមក្នុងមួយលើក.......... ៥២
ក្រាហ្វិក ៦.៤: ប្រាក់ផ្ញើមកផ្ទះជាមធ្យមក្នុងមួយឆ្នាំ.......... ៥៣
ក្រាហ្វិក ៦.៥: ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ.......... ៥៥

ក្រាហ្វិក ៦.៦: ការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុនៃគ្រួសារបញ្ជូនចេញ......៥៦
ក្រាហ្វិក ៦.៧: ផែនការអនាគតរបស់យុវជនពលករចំណាកស្រុក......៦០

**បញ្ជីតារាង**

តារាង ១.១: គំរូតាងដំណាក់កាលទីមួយ......១៨
តារាង ១.២: យេនឌ័រនៃយុវជនចំណាកស្រុកបានឆ្លើយសម្ភាសន៍......១៨

តារាង ២.១: ចំនួនភ្ញៀវទេសចរមកដល់......២៣
តារាង ២.២: ការងារក្នុងផ្នែកកាត់ដេរ សំណង់ និងទេសចរណ៍ នៅកម្ពុជា......២៤
តារាង ២.៣: ពលករចំណាកស្រុកបានសម្ភាស បែងចែកតាមអាយុ......២៥
តារាង ២.៤: អាយុរបស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍......២៦
តារាង ២.៥: ស្ថានភាពនៅលីវ/រៀបការ របស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍......២៦

តារាង ៣.១: តើអ្នកមានសូកប៉ាន់អ្នកណា ដើម្បីទទួលបានការងារបច្ចុប្បន្ននេះទេ?......៣៣

តារាង ៤.១: សកម្មភាពរបស់យុវជនពលករចំណាកស្រុកនៅពេលទំនេរ......៣៥
តារាង ៤.២: ការស្នាក់នៅរបស់យុវជនពលករចំណាកស្រុក......៣៧
តារាង ៤.៣: អ្នករួមបន្ទប់របស់យុវជនពលករចំណាកស្រុក......៣៧
តារាង ៤.៤: លទ្ធភាពទទួលបានការថែទាំសុខភាពរបស់យុវជនពលករចំណាកស្រុក......៣៩
តារាង ៤.៥: បញ្ហាប្រឈម និងការលំបាកដែលយុវជនពលករចំណាកស្រុកជួបប្រទះ......៤០
តារាង ៤.៦: ការលំបាកដែលយុវជនពលករចំណាកស្រុករាយការណ៍ទៅគ្រួសារ......៤១

តារាង ៥.១: រយៈពេលរំពឹងថានៅបម្រើការងារបច្ចុប្បន្ន......៤៤
តារាង ៥.២: ការរកប្រាក់ចំណូលប្រចាំខែរបស់យុវជនពលករចំណាកស្រុក......៤៧
តារាង ៥.៣: លំនាំចំណាយរបស់យុវជនពលករចំណាកស្រុក......៤៧
តារាង ៥.៤: មូលហេតុធ្វើអោយជីវភាពរស់នៅប្រែប្រួល......៤៩

តារាង ៦.១: ប្រាក់ផ្ញើជាចំណែកនៃប្រាក់ចំណូល......៥៣
តារាង ៦.២: ច្រកផ្ញើប្រាក់......៥៤
តារាង ៦.៣: ចំនួនដងនៃការមកលេងផ្ទះរបស់យុវជនពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍......៥៧
តារាង ៦.៤: ជម្រើសការងាររបស់យុវជនពលករចំណាកស្រុក......៥៩

# បញ្ជីអក្សរកាត់

| | |
|---|---|
| វបសអ | វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Research Institute-CDRI) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| MFIs | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Micro Finance Institutes) |
| NCPD | គណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ (National Committee for Population and Development) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| UNFPA | អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (United Nations Population Fund) |

# សេចក្តីថ្លែងអំណរគុណ

ឯកសារនេះ បានរៀបរៀងឡើងដោយលោក លឹម សុវណ្ណារា ។ យើងសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅដល់លោកអ្នកដែលបានរួមវិភាគទានយ៉ាងសំខាន់ និងថ្លៃថ្លាដល់ការសិក្សានេះ ។ សូមថ្លែងអំណរគុណដល់លោកស្រី រាជ មុន្នី និងលោកស្រី អាន ស៊ុនណារី សម្រាប់ការខិតខំប្រឹងប្រែង និងការងារចុះអង្កេតប្រកបដោយគុណភាពខ្ពស់ ។ សូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី ប៉ុន ដូរីណា ដែលបានបកប្រែកំរងសំនួរ ជួយសម្របសម្រួល និងចុះធ្វើការដល់កន្លែង ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកស្រី Christine Chan មកពី UNFPA សម្រាប់ការងារសម្របសម្រួលលើគម្រោងនេះ ចាប់តាំងពីពេលចាប់ផ្តើមដំបូងរហូតដល់ពេលបញ្ចប់ ។ លោកស្រីជាក្បាលម៉ាស៊ីនដ៏សំខាន់ និងបានចូលរួមក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការសិក្សា ចាប់តាំងពីការជួយពិនិត្យបញ្ជីសំនួរ រហូតដល់កសាងឯកសារសម្រេច ។

អ្នកនិពន្ធសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម រង ឈង អគ្គលេខាធិការគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ (NCPD) ដែលបានផ្តល់អនុសាសន៍ដ៏មានតម្លៃលើដំណើរការស្រាវជ្រាវ ព្រមទាំងផ្តល់ជំនួយដល់ការធ្វើបញ្ជីសំនួរ និងឯកសារសម្រេច ។

សូមថ្លែងអំណរគុណដល់បណ្ឌិត Bruno Maltoni នៃអង្គការអន្តរជាតិសម្រាប់ចំណាកស្រុក ដែលបានផ្តល់មតិយោបល់យ៉ាងស៊ីជម្រៅ ។

សូមសំដែងការដឹងគុណ និងអរគុណជាពិសេសផងដែរ ចំពោះលោក ច័ន្ទ សុផល អ្នកគ្រប់គ្រងការស្រាវជ្រាវនៅ វបសអ ដែលបានដឹកនាំការសិក្សានេះ ។

អ្នកនិពន្ធសូមអរគុណដល់បុគ្គលិកអង្គការ UNFPA និង NCPD ដែលបានចូលរួមដោយផ្ទាល់ រឺដោយប្រយោលក្នុងការសិក្សានេះ ។ បើគ្មានការឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តពីអ្នកទាំងនេះទេ ការសិក្សានេះក៏ពុំអាចសម្រេចបានដែរ ។

ជាចុងក្រោយ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អង្គការ UNFPA ដែលបានឧបត្ថម្ភខាងហិរញ្ញវត្ថុដល់ការសិក្សានេះ ។

# ជំពូកទី ១ សេចក្តីផ្តើម និងការពិនិត្យឯកសារ

## ១.១. សាវតារ និងមូលហេតុ

នៅទសវត្សរ៍១៩៦០ ប្រជាជនកម្ពុជាប្រហែល ១១% រស់នៅតំបន់ទីក្រុង[១] ប៉ុន្តែនៅអំឡុងពេលរបប ប៉ុល ពត ទីក្រុងត្រូវគេជំលៀសមនុស្សចេញស្ទើរតែអស់ ។ នគរូបនីយកម្មបានចាប់ផ្តើមឡើងវិញ ក្រោយការដួលរលំរបបខ្មែរក្រហម ហើយនៅឆ្នាំ១៩៩៨ ជំរឿនប្រជាជនកម្ពុជាបានធ្វើឡើង ដោយប៉ាន់ស្មានថា នៅទីក្រុងមានប្រជាជនរស់នៅប្រហែល ១៦%[២] ។ ប្រជាជនកម្ពុជាមានវ័យក្មេង ដោយក្រុមអាយុ ២៤ឆ្នាំ រឺតិចជាង មានដល់ទៅ ៦០,៨% នៃចំនួនប្រជាជនសរុប[៣] ។ អ្នកចំណូលថ្មីមានដល់ ៥៦% នៃប្រជាជននៅទីក្រុង គឺខ្ពស់ជាងនៅតំបន់ជនបទដែលមានត្រឹមតែ ៣១% ។ ៥៣% នៃអ្នករស់នៅទីក្រុងមិនមែនជាអ្នកកើតនៅទីក្រុងដែលបានអង្កេតនោះទេ[៤] ដោយសារកន្លងមក មានចំណាកស្រុកចូលក្រុងពីរលើកធំៗ គឺលើកទី១ នៅឆ្នាំ១៩៧៩ ក្រោយការដួលរលំរបប ប៉ុល ពត និងលើកទី២ នៅឆ្នាំ១៩៩៣ នៅពេលមានមនុស្សរាប់សែននាក់ បានត្រលប់មកពីជំរំតាមព្រំដែនវិញ ។ លំហូរចូលកម្លាំងពលកម្ម ជាបាតុភូតថ្មីមួយ និងបានកើនឡើងយ៉ាងខ្លាំងនៅចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ ។ និន្នាការនេះ នៅតែបន្តទៅមុខឥតអាក់ ហើយជនចំណាកស្រុកភាគច្រើន ជាយុវជនអាយុប្រហែល ២០ រឺតិចជាង ដែលធ្វើចំណាកស្រុក ដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារ រឺរកចិញ្ចឹមជីវិតខ្លួនឯង ។

ក្នុងមួយឆ្នាំៗ មានកំណើនចំនួនយុវជន ដែលធ្វើចំណាកស្រុកចូលមករស់នៅក្នុងទីក្រុង រឺប្រទេសនានា នៅក្នុងតំបន់ដែលត្រូវការពលករមានជំនាញទាប រឺគ្មានជំនាញ ។ ដោយឡែក ចំណាកស្រុកឆ្លងប្រទេស តែងជួបឧបសគ្គ និងចោទបញ្ហាច្រើន ។ ការសិក្សាពីការធ្វើចំណាកស្រុកនេះ នឹងសង្កត់ធ្ងន់លើចំណាកស្រុកឆ្លងប្រទេស ច្រើនជាងចំណាកស្រុកក្នុងប្រទេស ។ អ្នកធ្វើចំណាកស្រុកក្នុងប្រទេស មានចំនួនច្រើនលើសលុបជាងអ្នកធ្វើចំណាកស្រុកឆ្លងប្រទេស និងមានផលប៉ះពាល់ច្រើនជាង ទៅលើការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ ចំណាកស្រុកក្នុងប្រទេសភាគច្រើន ធ្វើពីជនបទទៅទីក្រុង មិនមែនពីជនបទទៅជនបទ រឺពីទីក្រុងទៅជនបទទេ ប៉ុន្តែចំណាកស្រុកឆ្លងប្រទេសមួយចំនួនមានប្រភពចេញពីទីក្រុងទៅ ។ ការសិក្សានេះ ផ្តោតជាសំខាន់លើចំណាកស្រុករបស់យុវជនពីជនបទទៅទីក្រុង និងផលប៉ះពាល់ទៅលើនគរូបនីយកម្ម និងការកាត់បន្ថយភាពក្រីក្រ ។

ចំណាកស្រុកអាចមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ទៅលើការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ហើយផលប៉ះពាល់សុទ្ធ នៅតែជាចំណុចកំពុងពិភាក្សាវែកញែកមិនទាន់ដាច់ស្រេចនៅឡើយ ។ Dang (2003) បានបញ្ជាក់ថា កន្លងមក គេតែងចាត់ទុកចំណាកស្រុកជាលទ្ធផលនៃភាពក្រីក្រ និងកង្វះការងារ រឺជាកត្តាដែលរួមចំណែកដល់ភាពក្រីក្រនៅ

---

១ យោងតាមវិទ្យាស្ថានជាតិស្ថិតិ (២០០៤ក) តំបន់មួយអាចចាត់ចូលជាតំបន់ទីក្រុង លុះត្រាវាមានលក្ខណៈបី (១) ដង់ស៊ីតេប្រជាជនលើសពី ២០០នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ (២) កម្លាំងពលកម្មមនុស្សប្រុសក្នុងវិស័យកសិកម្មទាបជាង ៥០% (៣) ចំនួនប្រជាជន-សរុបក្នុងឃុំមានលើសពី ២០០០នាក់ ។

២ ចំនួននេះត្រូវបានកែសម្រួលទៅជា ១៧,៧% ដោយយោងតាមនិយមន័យថ្មីនៃ "តំបន់ទីក្រុង" ទទួលបានពីវិទ្យាស្ថានជាតិស្ថិតិ (2004a) ។

៣ វិទ្យាស្ថានជាតិស្ថិតិ (2006), p.35 ។

៤ វិទ្យាស្ថានជាតិស្ថិតិ (2004b), p.23. Analysis of CIPS Results, Report 5: Spacial Distribution amd Mogratory Movement. July, 2005. វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ ។ ឧបត្ថមដោយ UNFPA ។

តំបន់ទីក្រុង និងជនបទ ។ ដូចនេះ ចំណាកស្រុកក្នុងប្រទេស ជួនកាលគេបានចាត់ទុកវាជាឧបសគ្គរាំងដល់ការអភិវឌ្ឍ ដែលត្រូវតែដាក់កំហិត និងត្រួតត្រាអោយបាន ។ Dang បានរៃកញែកទៀតថា គោលនយោបាយចំណាកស្រុក អាចព្យាយាមសម្រេចឱ្យបាននូវរបាយប្រជាជនមួយបែបដែលគេចង់បាននៅក្នុងសង្គម ។ ទោះបីផលប៉ះពាល់សុទ្ធរបស់វា មិនទាន់រៃកញែកឃើញច្បាស់ក្តី ក៏ចំណាកស្រុកក្នុងប្រទេស អាចជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតមួយដ៏សំខាន់សម្រាប់ប្រជាជនក្រីក្រជាច្រើន និងបានរួមចំណែកដ៏សំខាន់ដល់កំណើនសេដ្ឋកិច្ចជាតិ (DFID 2004) ។ មតិខាងលើនេះ ទទួលបានការគាំទ្រពី Laczko (2005) ដែលបានចង្អុលបង្ហាញថា ចំណាកស្រុកនៅក្នុងប្រទេស មានសក្តានុពលជួយជំរុញការអភិវឌ្ឍបានច្រើនបែបយ៉ាង ។ ដោយអាចរកចំណូលបន្ថែមតាមរយៈការងារមិនមែនកសិកម្មនៅតំបន់ទីក្រុង គ្រួសារនៅជនបទបានបង្កើនប្រភពប្រាក់ចំណូល និងមូលធនជាច្រើន ។ ក្នុងរយៈពេលខ្លី ចំណាកស្រុកអាចបង្កជាការខាតបង់ហិរញ្ញវត្ថុ និងធនធានមនុស្សនៅក្នុងមូលដ្ឋាន ប៉ុន្តែក្នុងរយៈពេលវែង វាអាចជួយរួមចំណែកដល់ការអភិវឌ្ឍតំបន់ជនបទ ។ ជាពិសេស ប្រាក់ផ្ញើមកផ្ទះរបស់ជនចំណាកស្រុក មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់គ្រួសារនៅជនបទ ។ ប្រាក់ផ្ញើដែលបានមកពីការងារនៅទីក្រុង អាចជួយបំពេញបន្ថែមលើប្រាក់ចំណូលនៅជនបទ បង្កើនចំណាយប្រើប្រាស់ បង្កើនប្រាក់សន្សំរបស់គ្រួសារ និងអាចជួយបង្កើនសេដ្ឋកិច្ចនៅមូលដ្ឋានបានមួយកម្រិតទៀត ។ ក្នុងរយៈពេលវែង គ្រួសារនៅជនបទ ទទួលបានផលប្រយោជន៍ដ៏សំខាន់ពីប្រាក់ផ្ញើមកផ្ទះនេះ ។

ជនចំណាកស្រុកនៅកម្ពុជា ចាត់ទុកចំណាកស្រុកជាយុទ្ធសាស្ត្ររយៈពេលខ្លី សម្រាប់ដោះស្រាយបញ្ហាស្ថានមិនដល់មួយចំនួន និងមិនមែនជាដំណើរការរយៈពេលវែង រឺមធ្យម សម្រាប់កែលំអស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៃគ្រួសារឡើយ ។ ពួកគេសម្រេចចិត្តធ្វើចំណាកស្រុកចេញពីសហគមន៍របស់ខ្លួន ដោយសារមានកត្តារុញច្រានដ៏ច្រើនជាងកត្តាទាក់ទាញ ។ កត្តារុញច្រាន រួមមានភាពក្រីក្ររ៉ាំរ៉ៃ ភាពគ្មានដីធ្លី កង្វះការងារ បំណុល និងគ្រោះធម្មជាតិដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ជាដើម ។ វិស័យកាត់ដេរគឺជាកត្តាទាក់ទាញដ៏ជាក់ស្តែងតែមួយគត់នៅកម្ពុជា (Maltoni 2006) ។

នៅឆ្នាំ១៩៩៨ ចំនួនជនចំណាកស្រុកឆ្លងខេត្ត មាន ២៨៦.៤១០នាក់ និងឡើងបន្តិចដល់ ២៩៧.៩០៣នាក់ នៅឆ្នាំ២០០៤ (NIS 2006) ។ ប្រជាជនដែលធ្វើចំណាកស្រុកទៅរកការងារធ្វើ ជាទូទៅគឺ អ្នកក្រ និងអ្នកក្របំផុត ដែលមិនអាចរកចំណូលបានគ្រប់គ្រាន់នៅឯភូមិស្រុកខ្លួនដើម្បីផ្គត់ផ្គង់គ្រួសារ ហើយនៅភ្នំពេញ គឺជាគោលដៅសំខាន់បំផុត ព្រោះមានរោងចក្រកាត់ដេរកំពុងរីកដុះដាលដូចផ្សិតនៅក្នុង និងជុំវិញក្រុង ដែលធ្វើអោយជនចំណាកស្រុក ពិសេសស្ត្រីក្មេងៗទៅចាប់យកការងារក្នុងវិស័យកាត់ដេរនេះ ។ សំណង់ក៏រីកដុះដាលលឿនស្ទើរតែពាសពេញផ្ទៃប្រទេស និងបានស្រូបយកកម្លាំងពលកម្មបុរសជាច្រើន ។ ភាគច្រើននៃជនចំណាកស្រុកបុរស បានចាប់យកការងារពាក់ព័ន្ធនឹងវិស័យសំណង់ក្នុងទីក្រុងធំៗ ដូចជា ក្រុងភ្នំពេញ និងសៀមរាប ជាដើម ។

គេបានសង្កេតឃើញជាយូរមកហើយថា ប្រជាជនច្រើនធ្វើចំណាកស្រុកនៅពេលមានវ័យក្មេង ដូច្នេះ បើសិនមានកំណើនចំណាកស្រុក គឺទំនងជាបង្កដោយក្រុមយុវជន ។ ទោះយ៉ាងនេះក្តី កន្លងមក មានការស្រាវជ្រាវតែបន្តិចបន្តួច និងមានការយល់ដឹងតិចតួចណាស់ពីពលករចំណាកស្រុកវ័យក្មេងនៅក្នុងទីក្រុងនៃប្រទេសកម្ពុជា ។ នៅដើមឆ្នាំ២០០៦ ប្រជុំពិគ្រោះយោបល់មួយខ្សែលើការស្រាវជ្រាវពីចំណាកស្រុក ត្រូវបានរៀបចំឡើងនៅក្រុងភ្នំពេញ ដោយគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ (NCPD) ដើម្បីកំណត់ពីចំនួនការស្រាវជ្រាវផ្សេងៗដែលមានប្រធានបទពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក ។ គេបានរកឃើញថា មានកង្វះខាតជាទូទៅនូវការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយអំពីចំណាកស្រុកនៅកម្ពុជា ។

## ១.២. គោលដៅការស្រាវជ្រាវ

ក្នុងគោលបំណងបំពេញកង្វះខាតដូចបានរៀបរាប់ខាងលើ ការសិក្សានេះ បានកំណត់គោលដៅលំអិតចំនួន ៥ (ក) ស្វែងយល់ពីសាវតារសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារយុវជនចំណាកស្រុក (ខ) កំណត់ពីកត្តា និងកាលៈទេសៈ ដែលជំរុញអោយមានចំណាកស្រុក និងស្វែងយល់ពីបែបបទដែលយុវជនធ្វើការសម្រេចចិត្តធ្វើចំណាកស្រុកចេញពីតំបន់ជនបទ (គ) ពិនិត្យមើលពីតួនាទីនៃទំនាក់ទំនងសង្គមក្នុងការសម្របសម្រួលចំណាកស្រុក និងដំណើរការចំណាកស្រុក (ឃ) កំណត់ពីប្រភេទការងារ

នៅទីក្រុងសម្រាប់យុវជនចំណាកស្រុក និងស្វែងយល់ពីការសម្របខ្លួនរបស់ពួកគេទៅនឹងការរស់នៅក្នុងទីក្រុង (ង) ស្វែងយល់ពីទំនាក់ទំនងរវាងគ្រួសារនៅជនបទ ជាមួយជនចំណាកស្រុក និងផលប៉ះពាល់នៃចំណាកស្រុកទៅលើភាពក្រីក្រនៃគ្រួសារ និងសហគមន៍របស់ជនចំណាកស្រុក ។

**ការសិក្សាបានព្យាយាមផ្ទៀងផ្ទាត់លើសម្មតិកម្មដូចខាងក្រោម:**

(ក) ពលករចំណាកស្រុកភាគច្រើនមកពីគ្រួសារមធ្យម និងក្រីក្រ ។ ពួកគ្រួសារធូរធារមិនធ្វើចំណាកស្រុកទេ ព្រោះគេមានប្រភពប្រាក់ចំណូលច្រើនមុខរួចស្រេចទៅហើយ រីឯអ្នកក្រីក្របំផុតខ្វះខាតធនធានហិរញ្ញវត្ថុដើម្បីធ្វើចំណាកស្រុក[៥] ។

(ខ) កត្តារុញច្រាន (កង្វះឱកាសការងារ ដីធ្លីកាន់កាប់មានតិចតួច រឺគ្មាន ការខូចខាតផលដំណាំបណ្ដាលមកពីគ្រោះរាំងស្ងួត និងទឹកជំនន់ ការជាប់បំណុល) មានច្រើនជាខ្លាំងជាងកត្តាទាក់ទាញ (នៅទីក្រុងមានប្រាក់កម្រៃខ្ពស់ និងលក្ខខណ្ឌរស់នៅប្រសើរជាង) ។

(គ) អវត្តមានទំនាក់ទំនង និងការសម្របសម្រួលល្អក្នុងការធ្វើចំណាកស្រុក ។

(ឃ) ពលករចំណាកស្រុកជួបប្រទះការលំបាក និងបញ្ហាប្រឈមជាច្រើន ក្នុងការសម្របខ្លួនចូលក្នុងបរិយាកាសទីក្រុង ហើយក្នុងពេលជាមួយគ្នា ពេលវេលាបានដាក់សំពាធទៅលើការងារនៅទីក្រុង ។

(ង) ប្រាក់ផ្ញើរបស់ជនចំណាកស្រុក អាចមានផលប៉ះពាល់ខាងសេដ្ឋកិច្ចយ៉ាងខ្លាំងទៅលើគ្រួសារ និងសហគមន៍នៅជនបទ តាមរយៈការកាត់បន្ថយភាពក្រីក្រ និងការកែលំអសុខុមាលភាព ។

## ១.៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ផ្អែកលើទិន្នន័យដំបូង និងទិន្នន័យទីពីរ ហើយការស្រាវជ្រាវបានចែកជាពីរដំណាក់កាល ។ ទោះជាយ៉ាងនេះក្តី ចំណុចសំខាន់នៃការសិក្សា គឺការស្រាវជ្រាវដំបូង ដោយប្រើប្រាស់កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KII) អង្កេតគ្រួសារ និងការពិភាក្សាតាមក្រុមស្នូល (FGD) ។ បញ្ជីសំនួររៀបរយមួយ បានរៀបចំឡើងសម្រាប់កិច្ចសម្ភាសន៍ដំណាក់កាលទីមួយជាមួយពលករចំណាកស្រុកវ័យក្មេង ហើយបញ្ជីសំនួរដាច់ដោយឡែកមួយបានបង្កើតឡើងសម្រាប់កិច្ចសម្ភាសន៍ដំណាក់កាលទីពីរ ជាមួយឪពុកម្តាយ និងសាច់ញាតិពួកគេ ។ ក្រៅពីនេះ បញ្ជីឈ្មោះក្នុងភូមិសម្រាប់ត្រួតពិនិត្យមួយ ត្រូវបានរៀបចំឡើងសម្រាប់ FGD ។ ទិន្នន័យទីពីរ ប្រមូលបានតាមរយៈការសិក្សានៅការិយាល័យ ។ ទិន្នន័យបានមកពីការសិក្សាឯកសារ ត្រូវបានប្រើប្រាស់ដើម្បីជួយសម្រួលដល់ការរចនារៀបចំការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ និងផ្តល់ជាព័ត៌មានបន្ថែមសម្រាប់ការសិក្សា ។

## ១.៤. ការកំណត់គំរូតាង

ក្នុងដំណាក់កាលទីមួយនៃការស្រាវជ្រាវ យើងបានធ្វើសម្ភាសន៍ជាមួយយុវជនជាពលករចំណាកស្រុកចំនួន ៦០០នាក់ ជ្រើសរើសដោយចៃដន្យចេញពី ៨ក្រុមការងារខុសៗគ្នា ហើយពួកគេបានជួយកំណត់នូវពលករចំណាកស្រុកដទៃទៀត តាមវិធីសាស្ត្រជ្រើសយកគំរូតាងដោយមានគោលដៅ ។ ក្នុងដំណាក់កាលទីពីរ បានធ្វើសម្ភាសន៍ជាមួយ ៥០គ្រួសារ ក្នុង ៥ភូមិដែលជាភូមិកំណើតរបស់អ្នកឆ្លើយសម្ភាសន៍ក្នុងដំណាក់កាលទីមួយ ។ ចំណុចសំខាន់នៃអង្កេតគ្រួសារលើកទីពីរនេះ គឺដើម្បីផ្ទៀងផ្ទាត់ជាមួយលទ្ធផលរកឃើញកាលពីអង្កេតលើកទី១ ។ លើសពីនេះទៀត FGD ត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលទាំងពីរ ដើម្បីប្រមូលនូវព័ត៌មានបែបគុណភាព ។

---

៥ នៅក្នុងការសិក្សានេះ គេចែកគ្រួសារជាបួនក្រុម: គ្រួសារអ្នកធូរធារ អ្នកមធ្យម អ្នកក្រ និងអ្នកក្របំផុត ។

**កន្លែងសម្ភាសន៍ជុំទីមួយ និងការជ្រើសរើសគំរូតាង**

ក្នុងដំណាក់កាលទីមួយ ទីក្រុង និងខេត្ត ចំនួន ៤ ដែលមានប្រជាជនចំណាកស្រុកចូលច្រើន ត្រូវបានជ្រើសរើសជាតំបន់គំរូតាងៈ ភ្នំពេញ សៀមរាប បាត់ដំបង និងបន្ទាយមានជ័យ (ប៉ោយប៉ែត)[៦] ។ ទិន្នន័យដំបូង ត្រូវបានប្រមូលតាមរយៈការចុះសម្ភាសន៍ផ្ទាល់ជាមួយពលករចំណាកស្រុកអាយុចាប់ពី ១៥ ដល់ ២៤ឆ្នាំ នៅតាមតំបន់ទាំងនេះ ។ អ្នកផ្តល់ព័ត៌មានគន្លឹះ ត្រូវបានជ្រើសរើសដោយចៃដន្យ និងបានជួយដល់ការកំណត់យុវជនចំណាកស្រុកជាច្រើននាក់ទៀត ។

ទីផ្សារពលកម្មនៅកម្ពុជា ផ្អែកយ៉ាងខ្លាំងទៅលើយេនឌ័រ ហើយវិស័យសេដ្ឋកិច្ចបានបែងចែកយ៉ាងច្បាស់រវាងបុរស និងស្ត្រី ។ ជាទូទៅ ស្ត្រីមានការងារធ្វើនៅក្នុងវិស័យមិនផ្លូវការ (អាជីវកម្មតូចតាច អ្នកលក់ម្ហូបអាហារ...) នៅរោងចក្រកាត់ដេរ និងនៅក្នុងវិស័យលំហែកំសាន្ត ។ ដើម្បីអោយមានតុល្យភាពខាងយេនឌ័រ ការសិក្សាសម្រេចជ្រើសរើសគំរូតាងជាក្រុមមុខរបរមាននារីភាគច្រើនពីរក្រុម គឺកម្មករកាត់ដេរ និងបុគ្គលិកនៅកាស៊ីណូ និងក្រុមមុខរបរមានបុរសភាគច្រើនពីរក្រុម គឺកម្មករសំណង់ និងអ្នករត់ម៉ូតូឌុប ។ ក្រៅពីនេះ មាន ៤ក្រុមមុខរបរផ្សេងទៀត ដែលមានពលករបុរស និងនារីប្រហាក់ប្រហែលគ្នា ។

នៅតាមកន្លែងដូចខាងលើនេះដែរ បានជ្រើសរើសគំរូតាងចំនួន ៤៨០នាក់ ចេញពីក្រុមចំនួន ៤ គឺអ្នកបម្រើតុតាមភោជនីយដ្ឋាន (ប្រុស/ស្រី) កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់ ។ ដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈដោយឡែកនៃតំបន់នីមួយៗ កម្មករលាងរថយន្ត ៣០នាក់ អ្នកលក់ដូរកំប៉ិចកំប៉ុក ៣០នាក់ នៅសៀមរាប និងបុគ្គលិកកាស៊ីណូ និងអ្នកអូសរទេះនៅតាមព្រំដែនកម្ពុជា-ថៃ (ប៉ោយប៉ែត) ត្រូវបានដាក់ចូលបន្ថែមទៀត ។ ក្រៅពីក្រុមអ្នករត់ម៉ូតូឌុប និងក្រុមអ្នកអូសរទេះ វិធីជ្រើសរើសដោយមានគោលដៅនូវគំរូតាងត្រូវបានប្រើប្រាស់ ។

*តារាង ១.១: គំរូតាងដំណាក់កាលទីមួយ*

| | អ្នកបម្រើតុ | អ្នករត់ម៉ូតូឌុប | កម្មករសំណង់ | កម្មករកាត់ដេរ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|
| ភ្នំពេញ | 30 | 30 | 60 | 90 | 30* | 240 |
| សៀមរាប | 30 | 30 | 30 | NA | 30** | 120 |
| បាត់ដំបង | 30 | 30 | 30 | NA | NA | 90 |
| ប៉ោយប៉ែត | 30 | NA | 30 | 30 | 60*** | 150 |

*កម្មករលាងរថយន្ត, **អ្នកលក់ដូរតូចតាច, ***បុគ្គលិកកាស៊ីណូ និងអ្នកអូសរទេះ

ក្នុងចំណោមគំរូតាង ជាកម្មករកាត់ដេរចំនួន ១២០នាក់ មានស្ត្រី ១០៥នាក់ ជាកម្មករសំណង់ ១២០នាក់ មានបុរស ១១០នាក់ ប៉ុន្តែអ្នករត់ម៉ូតូឌុបសុទ្ធតែជាបុរសទាំងអស់ ។ មុខរបរដទៃទៀត មានបុរស និងស្ត្រីប្រហាក់ប្រហែលគ្នា ។ ជារួមយុវជនចំណាកស្រុកដែលជាបុរសវ័យក្មេង មានចំនួន ៣៥០នាក់ និងជានារីវ័យក្មេង មានចំនួន ២៥០នាក់ ។

*តារាង ១.២: យេនឌ័រនៃយុវជនចំណាកស្រុកបានឆ្លើយសម្ភាសន៍*

| | បុរស | នារី | សរុប |
|---|---|---|---|
| កម្មករកាត់ដេរ | 15 | 105 | 120 |
| អ្នកបម្រើតុ | 49 | 71 | 120 |
| កម្មករសំណង់ | 110 | 10 | 120 |
| អ្នករត់ម៉ូតូឌុប | 120 | 0 | 120 |
| បុគ្គលិកកាស៊ីណូ | 5 | 25 | 30 |
| អ្នកលក់ដូរតូចតាច | 9 | 21 | 30 |
| កម្មករលាងរថយន្ត | 16 | 14 | 30 |
| អ្នកអូសរទេះ | 26 | 4 | 30 |
| សរុប | 350 | 250 | 600 |

៦ មើលឧបសម្ព័ន្ធ ១ សម្រាប់ចំនួនចំណាកស្រុកតាមខេត្តនីមួយៗ ។

ក្រៅពីបំណងធ្វើឱ្យមានតុល្យភាពរវាងក្រុមទាំង ២ភេទ នោះ ក្រុមសិក្សាទាំង ៨ នេះ ត្រូវបានជ្រើសរើស ពីព្រោះជាមុខរបរទូទៅ អនុវត្តដោយក្រុមពលករចំណាកស្រុកវ័យក្មេង ។ ប៉ុន្តែនៅមានមុខរបរជាច្រើនទៀត ដែលមិនបានដាក់ចូលទៅក្នុងការសិក្សានេះ ។ គំរូតាងចំនួន ៦០០នាក់ គឺសមស្រប ហើយជាលក្ខណៈស្ថិតិ ប៉ុន្តែគំរូតាងនេះ អាចចាត់ទុកថាមានលក្ខណៈចង្អុលបង្ហាញ ជាជាងលក្ខណៈតំណាង ។

### កន្លែងសម្ភាសន៍ដំណាក់កាលទីពីរ និងការជ្រើសរើសគំរូតាង

អង្កេតដំណាក់កាលទីមួយ បង្ហាញថា ខេត្តកំពង់ចាម និងព្រៃវែង មានចំនួនយុវជនចំណាកស្រុកខ្ពស់បំផុត ។ ហេតុនេះ ភូមិចំនួន ៥ ក្នុងខេត្តទាំងពីរ ត្រូវបានជ្រើសរើសធ្វើជាគំរូតាងសម្រាប់អង្កេតដំណាក់កាលទីពីរ ។ នៅដំណាក់កាលទីមួយ ក្រុមសិក្សាបានធ្វើសម្ភាសន៍ជាមួយពលករចំណាកស្រុកយ៉ាងតិច ៣នាក់ មកពីភូមិនីមួយៗខាងលើ ។ ក្នុងដំណាក់កាលនេះ ១០គ្រួសារក្នុងភូមិនីមួយៗត្រូវបានសម្ភាស ។ អ្នកផ្តល់ព័ត៌មានគន្លឹះ គឺជាឪពុកម្តាយ រឺសាច់ញាតិរបស់យុវជនចំណាកស្រុក ។ លើសពីនេះទៀត FGD បានធ្វើឡើងជាមួយមេភូមិ ឪពុកម្តាយ និងសាច់ញាតិរបស់ពលករចំណាកស្រុក ព្រមទាំងព្រឹទ្ធាចារ្យក្នុងភូមិ ដើម្បីទទួលបានទិន្នន័យបែបគុណភាព និងទស្សនៈខុសៗគ្នា ដើម្បីបន្ថែមលើទិន្នន័យបែបបរិមាណ ។ ទិន្នន័យបែបបរិមាណ ទទួលបានពីអង្កេតគ្រួសារ អាចយកទៅប្រើប្រាស់ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យបែបបរិមាណ ទទួលបានពីអង្កេតពលករចំណាកស្រុក ។

ភូមិទាំងនោះ មានដូចតទៅ:

- ភូមិស្ពឺ ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម
- ភូមិប្រាសាទ ឃុំជើងព្រៃ ស្រុកបាធាយ ខេត្តកំពង់ចាម
- ភូមិត្រពាំងតាម៉ុក ឃុំពានរោង ស្រុកព្រៃវែង ខេត្តព្រៃវែង
- ភូមិបល្ល័ង្ក ឃុំកន្ទ្បោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង
- ភូមិព្រៃដើមថ្នឹង ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

*ក្រាហ្វិក ១.១: ចំនួនអ្នកចំណាកស្រុកវ័យក្មេងដែលបានសម្ភាសតាមខេត្តនីមួយៗ*



# ជំពូកទី ២ ប្រជាជន និងចំណាកស្រុក

## ២.១. ទ្រឹស្តីពលកម្មចំណាកស្រុក

### ទ្រឹស្តីសេដ្ឋកិច្ចសមហេតុផល

ការសិក្សាភាគច្រើនអំពីចំណាកស្រុក បានសង្កត់ធ្ងន់លើហេតុផលរបស់ជនចំណាកស្រុក ។ ឧទាហរណ៍ Todaro (1989) សន្មតថា ជនចំណាកស្រុកធ្វើសកម្មភាពជាលក្ខណៈបុគ្គល ដោយផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួននៃសេដ្ឋកិច្ចសមហេតុផល ។ ការសម្រេចចិត្តធ្វើចំណាកស្រុក គឺផ្អែកលើការរំពឹងទុកពី "ផលចំណេញនៃការងារ" នៅកន្លែងគោលដៅដែលត្រូវទៅ ព្រមទាំង "ការវិភាគចំណាយ-ផលចំណេញ" ក្នុងគំនិតរបស់ជនចំណាកស្រុក[៧] ។ យោងតាមទស្សនៈនេះ ការសម្រេចចិត្តធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តបែបសេដ្ឋកិច្ចសមហេតុផលមួយ ដោយឈរជាសំខាន់លើកម្រិតខុសគ្នានៃប្រាក់បៀវត្សរ៍ នៅតំបន់កំពុងរស់នៅ និងគោលដៅត្រូវទៅ ។ សរុបមក គេសម្រេចចិត្តធ្វើចំណាកស្រុកនៅពេលមានផលប្រយោជន៍រំពឹងទុក ជាពិសេសខាងហិរញ្ញវត្ថុ វាធំជាងបន្ទុកចំណាយ ខាងហិរញ្ញវត្ថុ និងសង្គមកិច្ច ។

### ទ្រឹស្តីវិស័យពីរ

ឯកសារពីយូរហើយលើចំណាកស្រុក ផ្អែកលើគំរូអភិវឌ្ឍន៍ដែលថែងថា ប្រទេសទាំងអស់នៅដំណាក់កាលណាមួយ ត្រូវតែមានចលនាកម្លាំងពលកម្ម ចេញពីវិស័យកសិកម្មទៅកាន់វិស័យមិនមែនកសិកម្ម ។ ជារឿយៗ ការបែងចែកកម្លាំងពលកម្មទៅតាមវិស័យ ត្រូវមានចលនាផ្លាស់ប្តូរទីតាំងភូមិសាស្ត្រនៃពលករ ចេញពីតំបន់ជនបទទៅកាន់តំបន់ទីក្រុង (Lewis 1954) ។

ចំណាកស្រុកក្នុងប្រទេស តែងត្រូវចាត់ទុកជាដំណើរការធម្មតាមួយ ដែលក្នុងនេះ អតិរេកកម្លាំងពលកម្ម ត្រូវបានដកចេញជាបណ្តើរៗពីតំបន់ជនបទ ដើម្បីផ្តល់កម្លាំងពលកម្មដល់កំណើនឧស្សាហកម្មនៅទីក្រុង ។ ដំណើរការនេះ គួរតែមានគុណប្រយោជន៍ខាងសង្គមច្រើន ពីព្រោះធនធានមនុស្សនៅតាមតំបន់ ដែលការរកចំណូលបន្ថែមរបស់ពួកគេបានសឹងស្មើសូន្យ ត្រូវបានផ្លាស់ចេញទៅកាន់តំបន់ដែលការរកចំណូលបន្ថែមនេះមានតួលេខវិជ្ជមាន និងមានកំណើនយ៉ាងឆាប់រហ័ស ដោយសារមូលធនដែលបានបង្គរទុក និងការរីកចំរើនខាងបច្ចេកវិទ្យា (Todaro 1989: 274) ។ នៅក្នុងដំណើរការអភិវឌ្ឍន៍ ចលនាប្រជាជននៅគ្រប់ទិសទី គឺជាលក្ខណៈសំគាល់ដ៏សំខាន់មួយ ។ ហេតុការណ៍នេះ លោក Lewis បានដាក់បញ្ចូលទៅក្នុង "គំរូវិស័យពីរ" ដែលបានក្លាយទៅជាទ្រឹស្តីទូទៅនៃការអភិវឌ្ឍ នៅប្រទេសតតិយលោកដែលមានអតិរេកកម្លាំងពលកម្ម នៅអំឡុងទសវត្សរ៍ ១៩៦០ និង ១៩៧០ ។ នៅក្នុងគំរូរបស់ Lewis សេដ្ឋកិច្ចដែលមិនទាន់អភិវឌ្ឍន៍ មានវិស័យពីរជាសំខាន់ (១) វិស័យបុរាណរកបានត្រឹមមួយរស់នៅតាមជនបទដែលមានប្រជាជនច្រើនលើសកំណត់ និងមានផលិតភាពពលកម្មបន្ថែមស្មើសូន្យ (ដូច្នេះ Lewis ក៏អាចចាត់ទុកពលកម្មក្នុងស្ថានភាពទី១ នេះ ជាអតិរេកបាន ពីព្រោះពលកម្មបែបនេះ អាចដកចេញពីវិស័យកសិកម្ម ដោយគ្មានការខាតបង់ផលអ្វីមួយទេ និង (២) ផលិតភាពខ្ពស់នៃវិស័យឧស្សាហកម្មទំនើបនៅទីក្រុង ដែលទទួលយកជាបណ្តើរៗ នូវកម្លាំងពលកម្មមកពីវិស័យរកបានមួយរស់ ដូចបញ្ជាក់ខាងលើ (Todaro 1989: 69) ។

---

៧ Todaro, Michael (1989) "គំរូពលកម្មចំណាកស្រុក និងការអភិវឌ្ឍទីក្រុងនៅប្រទេសមានការអភិវឌ្ឍតិច" ។ American Economic Review, 138-148, quote in McDowell, C., and De Haan, A. (1997), p. 6 ។

### ទ្រឹស្តីកំណើនមានតុល្យភាព និងទ្រឹស្តីអភិវឌ្ឍន៍មិនស្របគ្នា

"វិធីសាស្ត្រកំណើនមានតុល្យភាព" ដែលផុសចេញពីទ្រឹស្តីសេដ្ឋកិច្ចសេរី បានសន្មតថា តាមរយៈការកាត់បន្ថយភាពគ្មានការងារធ្វើ និងការផ្តល់ផលជាប្រាក់ផ្ញើមកផ្ទះ និងជំនាញទទួលបាន សកម្មភាពចំណាកស្រុកបានជួយជំរុញការអភិវឌ្ឍ កាត់បន្ថយគំលាតក្នុងតំបន់ និងនៅទីបំផុតធ្វើអោយចំណាកស្រុកលែងចាំបាច់ទៀត ។ "វិធីសាស្ត្រអភិវឌ្ឍន៍មិនស្របគ្នា" ដែលពឹងផ្អែកខ្លាំងលើការសិក្សាកម្រិតមីក្រូ មិនបានទទួលស្គាល់ទេថា ចំណាកស្រុក ប្រាក់ផ្ញើមកផ្ទះ និងផលត្រឡប់ នាំឱ្យមានការអភិវឌ្ឍយ៉ាងលឿនជាស្វ័យប្រវត្តិនោះទេ (McDowell and de Haan 1997: 15) ។

ប្រាកដណាស់ ភាពក្រីក្រ គឺជាកត្តាបង្កចំណាកស្រុក ប៉ុន្តែមិនមែនមានតែភាពក្រីក្រនេះទេ ពីព្រោះវិសមភាពក៏ជាកត្តាមួយដែរ ។ សេដ្ឋកិច្ចទីផ្សារបាននាំមកនូវវិសមភាព និងគំលាតបៀវត្សរ៍ និងប្រាក់ចំណូល ដែលធ្វើអោយចំណាកស្រុកកើនឡើង ។ តាមមើល វិសមភាពពិតប្រាកដ និងចំណាប់អារម្មណ៍ថាមានវិសមភាព សុទ្ធតែអាចជាកត្តាកំណត់នៃសកម្មភាពចំណាកស្រុក (McDowell and de Haan 1997: 17) ។

### កត្តាបុគ្គល គ្រួសារ និងសហគមន៍

ទ្រឹស្តីចំណាកស្រុកមួយផ្សេងទៀត បានផ្តល់ពីហេតុផលដែលគួររំពឹងថា នឹងមានការចូលរួមដ៏ច្រើនរបស់យុវជននៅក្នុងចំណាកស្រុក គឺដោយសារកត្តាបុគ្គល គ្រួសារ និងសហគមន៍:

*កត្តាបុគ្គល:* ការបកស្រាយខាងសេដ្ឋកិច្ចបែបក្លាសិកចំពោះនិន្នាការនៃយុវជនក្នុងការធ្វើចំណាកស្រុកកាន់តែច្រើន គឺថា ចំណាកស្រុក គឺជាវិនិយោគមួយដែលតម្រូវអោយបុគ្គលម្នាក់ៗត្រូវមានចំណាយមួយចំនួន ដើម្បីបង្កើតបានប្រាក់ចំណូលខ្ពស់ (Sjaastad 1962; quoted in McKenzie 2006) ។ បន្ទុកចំណាយ រួមមាន ចំណាយលើការធ្វើដំណើរ ចំណាយរកការងារធ្វើ ប្រាក់ចំណូលត្រូវលះបង់ និងបន្ទុកចំណាយខាងផ្លូវចិត្ត ក្នុងការចាកចេញពីកន្លែងធ្លាប់រស់នៅ និងការសម្របខ្លួនទៅនឹងទីផ្សារការងារថ្មី (McKenzie 2006) ។

*កត្តាគ្រួសារ:* ឯកសារស្តីពីចំណាកស្រុក បានបង្ហាញពីរូបភាពសេដ្ឋកិច្ចថ្មីដ៏សំខាន់មួយ (Stark and Levhari 1982, quoted in McKenzie 2006) គឺជារឿយៗ ការសម្រេចចិត្តធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តរបស់គ្រួសារទាំងមូល មិនមែនជាការសម្រេចចិត្តរបស់សាមីខ្លួនតែម្នាក់ឯងនោះទេ ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍន៍ ។ គ្រួសារនីមួយៗ អាចអោយសមាជិកម្នាក់ធ្វើចំណាកស្រុក ដោយរំពឹងថា ប្រាក់ផ្ញើមកផ្ទះនឹងជួយពួកគេទប់ទល់នឹងវិបត្តិ ។ ពួកគេសម្រេចជ្រើសរើសសមាជិកណាម្នាក់ គឺមិនមែនត្រឹមតែដោយសារអ្នកនោះ អាចរកបានចំណូលច្រើនជាងគេពីចំណាកស្រុកនោះទេ ប៉ុន្តែក៏យោងផងដែរ ទៅលើការងាររបស់បុគ្គលនោះនៅក្នុងគ្រួសារ និងទំនុកចិត្តថា បុគ្គលនោះនឹងមានផ្ញើប្រាក់មកផ្ទះ (McKenzie 2006) ។

*កត្តាសហគមន៍:* នៅពេលមានយុវជនមួយចំនួនបានធ្វើចំណាកស្រុកហើយ ពេលនោះច្រើនតែមានយុវជនផ្សេងទៀតធ្វើចំណាកស្រុកដែរ ។ ហេតុផលមួយ គឺបណ្តាញសង្គមរបស់ជនចំណាកស្រុក ដែលជួយកាត់បន្ថយបន្ទុកចំណាយ និងបង្កើនផលប្រយោជន៍នៃការធ្វើចំណាកស្រុក ។ ដោយហេតុថា យុវជនច្រើនតែជាអ្នកធ្វើចំណាកស្រុកមុនគេ យុវជនជាបេក្ខជនធ្វើចំណាកស្រុក តែងតែមានស្គាល់ជនទើបធ្វើចំណាកស្រុកថ្មីៗ ច្រើនជាងបេក្ខជនមានវ័យចំណាស់ជាង ដូច្នេះ តែងទទួលបានផលប្រយោជន៍ច្រើនជាងពីបណ្តាញទំនាក់ទំនងនេះ (McKenzie 2006) ។

## ២.២. ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម

កម្ពុជាមានប្រជាជនវ័យក្មេងច្រើន ដោយសារការស្ទុះឡើងខ្លាំងនៃកំណើតទារកក្រោយរបបប៉ុលពត ត្រូវបញ្ចប់ ។ ចំនួនប្រជាជន កើនឡើងជាមធ្យម ១,៨១% ក្នុងមួយឆ្នាំ ។ នៅឆ្នាំ២០២០ ប្រជាជនកម្ពុជាគ្រោងឡើងដល់ ១៨,៧លាននាក់ ធៀបនឹង ១៤,៤លាននាក់ នៅឆ្នាំ២០០៧ (NIS 2006) ។ ប្រមាណ ៦០% នៃប្រជាជនសរុប មានអាយុ ២៤ឆ្នាំ រឺតិចជាងនេះ[៨] ហើយការបង្កើតការងារសម្រាប់ពួកគេ គឺជាការងារយ៉ាងធំសំបើមមួយសម្រាប់រដ្ឋាភិបាល ។ ប្រជាជនជាង ៨០% រស់នៅក្នុងតំបន់ជនបទ និងធ្វើសកម្មភាពខាងកសិកម្មជាសំខាន់ ដែលតាមធម្មតាផ្តល់ការងារអោយពួកគេបានត្រឹម ៣-៦ខែប៉ុណ្ណោះ ដូច្នេះ ក៏មានយុវជនកាន់តែច្រើនឡើងៗ បានចាកចេញពីភូមិកំណើតទៅរកការងារធ្វើនៅទីក្រុង ។ បញ្ហាពុំមានការងារធ្វើឱ្យបានពេញៗមួយឆ្នាំនៅជនបទកម្ពុជា បានបង្ហាញពីទំហំនៃភាពអត់ការងារធ្វើ និងកង្វះការងារ ។

ខាងផ្នែកតម្រូវការវិញ ការងារនៅតំបន់ទីក្រុង ជាពិសេសការងារនៅតាមរោងចក្រកាត់ដេរ និងកន្លែងសំណង់ ជាចំណុចសំខាន់របស់អ្នកភូមិនៅជនបទ ជាពិសេសយុវជន ។ ពីចុងទសវត្សរ៍១៩៩០ ដល់ដើមទសវត្សរ៍២០០០ រោងចក្រកាត់ដេរនៅជុំវិញទីក្រុងភ្នំពេញ បានផុសឡើងជាបន្តបន្ទាប់ ទន្ទឹមគ្នានឹងការរីកដុះដាលយ៉ាងលឿននៃសំណង់ផ្ទះថ្មីៗនៅក្រុងភ្នំពេញ ហើយនិងសណ្ឋាគារថ្មីៗ និងសំណង់ទេសចរណ៍ផ្សេងៗនៅខេត្តសៀមរាប នៅពេលដែលចំនួនភ្ញៀវទេសចរមកកម្ពុជា បានកើនឡើងយ៉ាងលឿនដល់ ២០% ក្នុងមួយឆ្នាំ ។ វិស័យសេវាកម្មក៏ស្ទុះឡើងដែរ ជាពិសេសក្នុងផ្នែកពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន និងក្រុមហ៊ុនទេសចរណ៍ជាដើម ។

នៅឆ្នាំ២០០៦ មានកម្មករ ៣៣០.០០០នាក់ បម្រើការនៅក្នុងឧស្សាហកម្មកាត់ដេរ ។ ពួកគេមកពីតំបន់ជនបទ ហើយជាង ៩០% ជាស្ត្រីវ័យក្មេង ។ ផ្នែកសាងសង់បានផ្តល់ការងារដល់បុរសក្មេងៗ ២៦០.០០០នាក់ រីឯសណ្ឋាគារ និងភោជនីយដ្ឋាន បានផ្តល់ ៦១.០០០ការងារ[៩] ។ ពាណិជ្ជកម្មនៅតាមព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម កាន់តែរស់រវើកឡើងនៅទសវត្សរ៍ចុងក្រោយនេះ ដោយបង្កើតការងារសម្រាប់ពួកយុវជន ដូចជា អ្នកបម្រើការនៅភោជនីយដ្ឋាន និងកាស៊ីណូ និងអ្នកអូសរទេះជាដើម ។ ចំពោះមុខកំណើនឱកាសការងារយ៉ាងខ្លាំងនេះ យុវជននៅជនបទកម្ពុជា ក៏ចាប់ផ្តើមធ្វើចំណាកស្រុកទាំងហ្វូងៗ ។ គ្មានតំបន់ណាមួយដែលគេចផុតពីបាតុភូតនេះឡើយ ។ ផ្អែកតាមការសម្ភាស សូម្បីនៅតំបន់មិនងាយទៅដល់ ក៏មានយុវជនធ្វើចំណាកស្រុកមកដែរ (ភូមិពីរ ដែលមានយុវជនធ្វើចំណាកស្រុកច្រើន ត្រូវបានជ្រើសរើសជាកន្លែងគ្រោងចុះសិក្សា ទោះបីអ្នកស្រាវជ្រាវមិនអាចចូលទៅដល់ក្តី) ។ ចលនាយ៉ាងធំរបស់យុវជនក្នុងពេលដ៏ខ្លីបែបនេះ គឺជាដំណើរការផ្លាស់ប្តូរប្រជាសាស្ត្រមួយថ្មីទៀតហើយ ។

*តារាង ២.១: ចំនួនភ្ញៀវទេសចរមកដល់ (ឆ្នាំ១៩៩៥-២០០៦)*

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួន (ពាន់) | 219 | 260 | 218 | 286 | 367 | 466 | 604 | 784 | 701 | 1055 | 1421 | 1700 |
| អត្រាកំណើន (%) | -37.8 | 18.6 | -16.0 | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 19/7 |

*ប្រភព: ក្រសួងទេសចរណ៍*

៨ មើលឧបសម្ព័ន្ធ ២ របាយប្រជាជននៅកម្ពុជា ។

៩ មើលឧបសម្ព័ន្ធ ៣ សម្រាប់ព័ត៌មានលម្អិតនៃចំនួនការងារបែងចែកតាមវិស័យ ។

*តារាង ២.២: ការងារក្នុងផ្នែកកាត់ដេរ សំណង់ និងទេសចរណ៍ នៅកម្ពុជា (១៩៩៥-២០០៦)*

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រោងចក្រកាត់ដេរ | 20 | 24 | 67 | 129 | 152 | 190 | 186 | 188 | 197 | 206 | 250 | 294 |
| កម្មករកាត់ដេរ (ពាន់នាក់) | 19 | 24 | 51 | 79 | 96 | 123 | 188 | 210 | 234 | 246 | 296 | 330 |
| កម្មករសំណង់ (ពាន់នាក់) | 27 | 38 | 54 | 48 | 83 | 70 | 84 | 120 | 153 | 195 | 234 | 260 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 11 | 7 | 6 | 15 | 28 | 19 | 10 | 24 | 27 | 30 | 43 | 61 |

*ប្រភព: មូលនិធិរូបិយវត្ថុអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា*

## ២.៣. សាវតារសេដ្ឋកិច្ច-សង្គមកិច្ច នៃគ្រួសារយុវជនចំណាកស្រុក

### ចំណាត់ថ្នាក់សុខុមាលភាពនៃគ្រួសារយុវជនចំណាកស្រុក

ចំណាកស្រុកពីជនបទមកកាន់ទីក្រុងនៅប្រទេសកម្ពុជា មានលក្ខណៈធំទូលាយណាស់ ព្រោះមិនត្រឹមតែអ្នកក្រ និងអ្នកក្របំផុតទេ ដែលធ្វើចំណាកស្រុក ទោះបីអ្នកមធ្យម ក៏ធ្វើចំណាកស្រុកដែរ ។ គ្រួសារជាច្រើននៅក្នុងភូមិសិក្សា គឺមានសមាជិកម្នាក់យ៉ាងតិច ជាយុវជនធ្វើចំណាកស្រុកទៅរកការងារធ្វើនៅទីក្រុង ។ មានតែគ្រួសារដែលគ្មានសមាជិកជាយុវជន រឺក៏មានឪពុកម្តាយចាស់ជរា រឺពិការទេ ដែលគ្មានសមាជិកធ្វើចំណាកស្រុក ។

ក្រាហ្វិក ២.១ បង្ហាញថា ៥៤% នៃគ្រួសារយុវជនចំណាកស្រុក ស្ថិតក្នុងក្រុមអ្នកមធ្យម ៤០% ទៀត នៅក្នុងក្រុមអ្នកក្រ និង ៦% ក្នុងក្រុមអ្នកក្របំផុត ។ គ្រួសារយុវជនចំណាកស្រុក ៩៤% ដែលបានឆ្លើយសម្ភាសន៍ ស្ថិតក្នុងក្រុមអ្នកក្រ និងអ្នកមធ្យម ។ ក្រុមអ្នកក្របំផុត ជួបការលំបាកជាខ្លាំងក្នុងការធ្វើចំណាកស្រុក ពីព្រោះពួកគេខ្វះមូលធនហិរញ្ញវត្ថុ និងមូលធនសង្គម ។ ក្នុងករណីខ្លះ កូនៗក្នុងគ្រួសារក្របំផុតត្រូវតែនៅផ្ទះ ដើម្បីមើលថែឪពុកម្តាយចាស់ជរា រឺពិការ ដែលស្ថានភាពរបស់ពួកគាត់នេះជាកត្តាបង្កភាពក្រីក្រ រឺជាលទ្ធផលនៃភាពក្រីក្រ ។ យុវជនក្នុងគ្រួសារអ្នកធូរធារ គេបន្តរស់នៅក្នុងភូមិកំណើត ដោយសារហេតុផលផ្សេងៗ ។ គ្រួសារអ្នកធូរធារភាគច្រើន អាចបង្កើនប្រភពចំណូល ដូចជា ផ្តល់ប្រាក់អោយគ្រួសារអ្នកក្រខ្ចី រឺជួលឧបករណ៍អោយគេ ដូចជា ត្រាក់ទ័រ គោយន្ត ម៉ាស៊ីនកិនស្រូវ រឺក៏ធ្វើអាជីវកម្មតូចតាចនៅក្នុងភូមិ ។ ការងារទាំងអស់នេះជួយអោយពួកគេអាចជៀសផុតពីហានិភ័យ និងបញ្ហាប្រឈម ពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក ។

*ក្រាហ្វិក ២.១: សុខុមាលភាពនៃគ្រួសារយុវជនចំណាកស្រុកបានឆ្លើយសម្ភាសន៍*



## ២.៤. លក្ខណៈសំគាល់នៃយុវជនពលករចំណាកស្រុក

ដូចមានបង្ហាញក្នុងតារាង ២.៣ ការសិក្សានេះ ធ្វើឡើងលើជនចំណាកស្រុកមានអាយុពី ១៥ ដល់ ២៤ឆ្នាំ ។ ពលករចំណាកស្រុក ត្រូវបានជ្រើសដោយចៃដន្យ ប៉ុន្តែយុវជនមានអាយុ ១៥ឆ្នាំ មានចំនួនត្រឹមតែ ១២នាក់ រឺ ២% ប៉ុណ្ណោះ ដែលភាគច្រើន ជាអ្នកអូសរទេះ រឺកម្មករលាងរថយន្ត ។ ចំពោះយុវជនអាយុ ២៤ឆ្នាំ ភាគច្រើន ជាអ្នករត់ម៉ូតូឌុប កម្មករសំណង់ និង បុគ្គលិកកាស៊ីណូ ។

*តារាង ២.៣: ពលករចំណាកស្រុកបានសម្ភាស បែងចែកតាមអាយុ*

| អាយុ | ចំនួន | ភាគរយ |
|---|---|---|
| 15 | 12 | 2.00 |
| 16 | 27 | 4.50 |
| 17 | 31 | 5.17 |
| 18 | 51 | 8.50 |
| 19 | 58 | 9.67 |
| 20 | 71 | 11.83 |
| 21 | 57 | 9.50 |
| 22 | 61 | 10.17 |
| 23 | 60 | 10.00 |
| 24 | 172 | 28.67 |
| សរុប | 600 | 100.00 |

### អាយុមធ្យមរបស់ពលករចំណាកស្រុក

នៅកម្ពុជា ក៏ដូចជានៅប្រទេសភាគច្រើនទៀតដែរ ជនចំណាកស្រុកនៅក្នុងប្រទេសភាគច្រើនជាយុវជន ។ ក្នុងការសិក្សានេះ គំរូតាងបានជ្រើសយកមកក្នុងពីចំណោមពលករចំណាកស្រុកមានអាយុពី ១៥ ដល់ ២៤ឆ្នាំ ។ ក្នុងចំណោមក្រុមមុខរបរទាំង៨ ដែលបានធ្វើសម្ភាសនី ក្រុមអ្នករត់ម៉ូតូឌុបមានអាយុជាមធ្យមខ្ពស់ជាងគេ គឺ ២២.៩៥ឆ្នាំ រីឯក្រុមអ្នកអូសរទេះ មានអាយុជាមធ្យមតិចជាងគេត្រឹម ១៨.៧៣ឆ្នាំ ហើយមធ្យមភាគនៃអាយុជារួម គឺ ២១.០៤ឆ្នាំ ។ អ្នករត់ម៉ូតូឌុបតែងមានអាយុច្រើនជាងគេ ព្រោះមុខរបរនេះ ត្រូវការដើមទុនពី ៥០០-១០០០ដុល្លារ ដើម្បីទិញម៉ូតូមួយគ្រឿង ដែលនេះជាទឹកប្រាក់ដ៏ច្រើនសម្រាប់ប្រជាជននៅជនបទ ។ មុខរបរជាអ្នកបម្រើតុ កម្មករលាងរថយន្ត រឺជាពិសេសអ្នកអូសរទេះភាគច្រើនគឺយុវជនចំណាកស្រុកដែលមានអាយុតិច ព្រោះមិនទាមទារដើមទុន រឺជំនាញអ្វីឡើយ ។ ក្រុមស្រាវជ្រាវត្រូវចំណាយពេល ២ រឺ ៣ថ្ងៃ បន្ថែមពីលើផែនការស្នាក់នៅនៅក្រុងបាត់ដំបង ដើម្បីស្វែងរកអ្នករត់ម៉ូតូឌុបដែលមានអាយុមិនលើសពី ២៤ឆ្នាំ និងមកពីខេត្តដទៃទៀត ។

ក្នុងចំណោមអ្នកឆ្លើយសម្ភាសនី ៦០០នាក់ មានករណីពិសេសមួយចំនួនគឺ មាន ៣៥នាក់ កំព្រាឳពុកម្តាយ ៣៨នាក់ មកពីគ្រួសារដែលមានឳពុក រឺម្តាយចុង រឺមានបញ្ហាជាមួយបងប្អូន ហើយមានមួយករណី ដែលក្មេងស្រីម្នាក់ត្រូវគេចាប់រំលោភ មុនពេលសម្រេចចិត្តធ្វើចំណាកស្រុក ។

*តារាង ២.៤: អាយុរបស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍*

| ប្រភេទការងារ | អាយុជាមធ្យម |
|---|---|
| អ្នករត់ម៉ូតូឌុប | 22.95 |
| បុគ្គលិកកាស៊ីណូ | 21.73 |
| កម្មករសំណង់ | 21.44 |
| កម្មករកាត់ដេរ | 20.87 |
| អ្នកបម្រើភោជនីយដ្ឋាន | 20.20 |
| អ្នកលក់ដូរតូចតាច | 19.70 |
| កម្មករលាងរថយន្ត | 18.87 |
| អ្នកអូសរទេះ | 18.73 |
| សរុប | 21.04 |

## ស្ថានភាពប្តីប្រពន្ធរបស់ពលករចំណាកស្រុក

ពលករចំណាកស្រុកជាង ៧៥% នៅលីវ ។ ចំណុចនេះបញ្ជាក់គាំទ្រដល់សម្មតិកម្មដែលថា យុវជនធ្វើចំណាកស្រុកនៅលីវបានយូរជាងយុវជននៅឯភូមិ ។ អង្កេតគ្រួសារបានផ្តល់លទ្ធផលស្ទើរដូចគ្នា: ជនចំណាកស្រុក ៧៤% នៅលីវ ២០% រៀបការហើយ និង ៦% លែងលះគ្នា រឺស្លាប់ប្តី/ប្រពន្ធ ។ ត្រឹមកាលពី ១០ឆ្នាំមុននេះ ប្តីប្រពន្ធភាគច្រើន ជាអ្នកភូមិជាមួយគ្នាកាលពីគាត់មិនទាន់រៀបការ ។ ប៉ុន្តែក្រោយមក កាន់តែមានអាពាហ៍ពិពាហ៍ឆ្លងខេត្តច្រើនឡើង ក្នុងចំណោមពលករចំណាកស្រុកដែលនេះ បង្ហាញពីបំលាស់ប្តូរខាងប្រជាសាស្ត្រនៅក្នុងសង្គមបែបបុរាណមួយដែលធ្លាប់តែប្រើចំណងមេត្រីភាពមានមូលដ្ឋាននៅក្នុងភូមិ ជាលក្ខណៈវិនិច្ឆ័យលើទំនាក់ទំនងសង្គមសំខាន់របស់បុគ្គលម្នាក់ ។

*តារាង ២.៥: ស្ថានភាពនៅលីវ/រៀបការ របស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍*

| ស្ថានភាពនៅលីវ/រៀបការ | ចំនួន | ភាគរយ |
|---|---|---|
| នៅលីវ | 465 | 77.50 |
| រៀបការ | 124 | 20.67 |
| លែងលះ | 7 | 1.17 |
| មេម៉ាយ រឺពោះម៉ាយ (ប្តី រឺប្រពន្ធ ស្លាប់) | 4 | 0.67 |
| សរុប | 600 | 100.00 |

## កម្រិតអប់រំរបស់ពលករចំណាកស្រុក

ការអប់រំ គឺជាចំណែកដ៏សំខាន់មួយក្នុងជីវិតមនុស្ស ។ ការអប់រំសមស្រប ជួយឱ្យពលករចំណាកស្រុកទទួលបានព័ត៌មានពាក់ព័ន្ធនឹងការងារ និងអាចនាំឱ្យមានការសម្រេចចិត្តកាន់តែប្រសើរ និងសមហេតុផល ។ លទ្ធផលអង្កេតបង្ហាញថា ការអប់រំជារួមដែលយុវជនចំណាកស្រុកទទួលបានជាមធ្យម គឺ ៦,៣៩ឆ្នាំ ដូច្នេះ ភាគច្រើនមិនបានបញ្ចប់មធ្យមសិក្សាទេ[១០] ។ ដូចគ្នានឹងលទ្ធផលនៃការស្រាវជ្រាវឯទៀតៗដែរ អង្កេតបានបង្ហាញថា ពលករចំណាកស្រុកជាស្ត្រី ទទួលបានការអប់រំតិចជាងខាងបុរសចំនួនចាប់ពី ១ឆ្នាំឡើង ។

១០ យោងតាមការអង្កេតពីសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជាឆ្នាំ២០០៤ ប្រហែល ៧៣% នៃប្រជាជននៅជនបទ មិនបានបញ្ចប់បឋមសិក្សា ធៀបនឹង ៦២% នៅទីក្រុងដទៃទៀត និង ៣៧% នៅទីក្រុងភ្នំពេញ ។ អង្កេតមួយផ្សេងទៀតបានរកឃើញថា អ្នកដែលធ្វើចំណាកស្រុកចេញទៅ ច្រើនតែមានការ អប់រំខ្ពស់ជាងអ្នកដែលមិនបានធ្វើចំណាកស្រុក ។

ការរកប្រាក់ចំណូល ជាគោលបំណងធំបំផុតរបស់ពលករចំណាកស្រុកដែលបានសម្ភាស ។ ប៉ុន្តែជនចំណាកស្រុកក្មេងៗក៏អាចកសាងសមត្ថភាពផ្ទាល់ខ្លួនដែរ បើសិនបានចូលសាលារៀន រឺទទួលការបណ្តុះបណ្តាលជំនាញនៅឯកន្លែងគោលដៅ ។ ដើម្បីទទួលបានលក្ខខណ្ឌរស់នៅល្អប្រសើរនៅទីក្រុង យុវជនចំណាកស្រុកមួយចំនួនតូច បានចំណាយពេល ២-៣ម៉ោង ក្នុងមួយសប្តាហ៍ ដើម្បីរៀនភាសាបរទេស រឺជំនាញកុំព្យូទ័រ ។ កម្មករសំណង់មួយក្រុមនៅខេត្តសៀមរាប បានចំណាយពេលមួយម៉ោង និងប្រាក់ ៥០០រៀលក្នុងមួយថ្ងៃ ដើម្បីរៀនភាសាអង់គ្លេស ដោយសង្ឃឹមថា នឹងបានធ្វើជាមេក្រុមនៅក្នុងក្រុមហ៊ុនសំណង់បរទេស ។ ចំណុចវិជ្ជមានមួយទៀតដែលមិនកម្រជួបដែរ គឺអ្នករត់ម៉ូតូឌុបម្នាក់នៅខេត្តបាត់ដំបង ចំណាយពេលកន្លះថ្ងៃធ្វើការ និងកន្លះថ្ងៃទៀត រៀនភាសាអង់គ្លេស និងជប៉ុន ដោយសង្ឃឹមថា អាចបានធ្វើមគ្គុទេសក៍ទេសចរ រឺបុគ្គលិកការិយាល័យ ។ ករណីមួយផ្សេងទៀតនៅខេត្តបាត់ដំបង មានអ្នកបម្រើក្នុងភោជនីយដ្ឋានម្នាក់ ធ្វើការតែកន្លះពេលទេក្នុងមួយថ្ងៃ ដោយយកពេលពាក់កណ្តាលទៀតទៅសាលារៀន ។ ឱកាសបែបនេះ មិនងាយមានទេនៅតាមភូមិដាច់ស្រយាលរបស់ពួកគេ ។ ពិតហើយ ករណីបែបនេះឃើញមានមួយៗប៉ុណ្ណោះ រីឯយុវជនចំណាកស្រុកភាគច្រើនបានបោះបង់ការសិក្សាទាំងស្រុង នៅពេល រឺនៅមុនពេលចាកចេញទៅទីក្រុង ។ គោលដៅចំបងរបស់ពួកគេ គឺរកប្រាក់ចំណូលមិនមែនបន្តការសិក្សាទេ ។ តាមរយៈចំណាកស្រុកទៅទីក្រុង ពួកពលករក្មេងៗមានលទ្ធភាពកាន់តែប្រសើរ ដើម្បីទទួលបានការអប់រំ រឺការបណ្តុះបណ្តាល ប៉ុន្តែភាគច្រើនមិនបានឆក់យកឱកាសល្អនេះទេ ។ កម្រិតអប់រំរបស់ពលករចំណាកស្រុកក្មេងៗ គឺប្រហាក់ប្រហែលនឹងយុវជននៅជនបទដែរ ។ ពួកគេនឹងបញ្ឈប់ការសិក្សាដូចគ្នា ទោះបីមិនធ្វើចំណាកស្រុកក៏ដោយ ។ អង្កេតរកមិនឃើញភស្តុតាងណាមួយដែលថា ចំណាកស្រុកបានកាត់បន្ថយការអប់រំ រឺក៏បង្កើនអត្រាឈប់រៀននៅជនបទនោះទេ ។

*ក្រាហ្វិក ២.២: ចំនួនឆ្នាំសិក្សារបស់ពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍*







## ទំហំគ្រួសាររបស់ពលករចំណាកស្រុក

ក្នុងសង្គមបុរាណ ដូចជានៅកម្ពុជា ការសម្រេចចិត្តធ្វើចំណាកស្រុក ជាពិសេសពាក់ព័ន្ធនឹងយុវជន ភាគច្រើនគឺធ្វើឡើងដោយសមាជិកដទៃទៀតក្នុងគ្រួសារ មិនមែនដោយសាមីខ្លួនឡើយ ។ ហេតុនេះ គេគិតថា ទំហំគ្រួសារ និងចំនួនមនុស្សក្នុងបន្ទុកដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចថាតើគួរអោយសមាជិកគ្រួសារធ្វើចំណាកស្រុក រឺអត់ ។ គ្រួសារធំៗ ច្រើនមានសល់កម្លាំងពលកម្ម ដែលនាំឱ្យពួកគេអាចធ្វើចំណាកស្រុក ។ នៅឆ្នាំ១៩៩៨ ទំហំមធ្យមនៃគ្រួសារយុវជនចំណាកស្រុកឆ្លើយសម្ភាសន៍ គឺ ៥,៣នាក់ ធៀបនឹង ៥,១នាក់ សម្រាប់គ្រួសារទាំងអស់នៅកម្ពុជា ហើយនៅទីក្រុងវាមានកម្រិតខ្ពស់ជាង (៥,៤នាក់) បើធៀបនឹងជនបទ (៥នាក់) (NIS 2004b) ។ ដោយសារទំហំគ្រួសារយុវជនចំណាកស្រុក ស្ទើរតែស្មើគ្នានឹងមធ្យមភាគថ្នាក់ជាតិ ដូច្នេះ គេមិនអាចចាត់ទុកទំហំគ្រួសារ ជាកត្តារុញច្រានអោយមានចំណាកស្រុកឡើយ ។

### ចំនួនពលករចំណាកស្រុកក្នុងមួយគ្រួសារ

គ្រួសារដែលមានសមាជិកលើសពីម្នាក់ធ្វើចំណាកស្រុក មិនមែនជាករណីកម្រទេ ។ អង្កេតគ្រួសារបានបង្ហាញថា គ្រួសារមានសមាជិកធ្វើចំណាកស្រុកលើសពីម្នាក់ មានច្រើនជាងគ្រួសារដែលមានសមាជិកតែម្នាក់ធ្វើចំណាកស្រុក ។ ជាក់ស្តែង ៤៦% នៃគ្រួសារបានឆ្លើយសម្ភាសន៍ មានសមាជិកធ្វើចំណាកស្រុកតែម្នាក់គត់ ៤៤% មានសមាជិកធ្វើចំណាកស្រុក ២នាក់ និង ១០% មានលើសពី ២នាក់ ។ ក្នុងករណីមួយ មានគ្រួសារមួយមានកូនដល់ទៅ ៥នាក់ ដែលបានធ្វើចំណាកស្រុកទៅទីក្រុងទាំងអស់ ។ ជាទូទៅ កូនច្បងបង្អស់ធ្វើចំណាកស្រុកមុនគេ បន្ទាប់មក ត្រឡប់មកយកប្អូនៗទៅទៀត ក្រោយពេលបង្កើតបានបណ្តាញទំនាក់ទំនងរបស់ខ្លួននៅឯទីក្រុងហើយ ។

*ក្រាហ្វិក ២.៣: ចំនួនពលករចំណាកស្រុកក្នុងមួយគ្រួសារដែលបានសម្ភាស*




### គោលដៅការងាររបស់សាច់ញាតិយុវជនពលករចំណាកស្រុក

ស្របគ្នានឹងទិន្នន័យបានពីអង្កេតគ្រួសារ ជាងមួយភាគបី (៣៤,៥%) នៃយុវជនពលករចំណាកស្រុក បានឆ្លើយសម្ភាសន៍ គឺមានយ៉ាងហោចណាស់សមាជិកគ្រួសារម្នាក់ទៀត ដែលកំពុងស្វែងរកការងារក្នុងពេលជាមួយគ្នានៅទីក្រុងតែមួយ រឺនៅកន្លែងផ្សេងទៀតក្នុងប្រទេស រឺឆ្លងកាត់ព្រំដែន ។ ក្រាហ្វិក ២.៤ បង្ហាញថា ក្រុងភ្នំពេញជាគោលដៅមានប្រជាប្រិយភាពជាងគេ បន្ទាប់មក គឺខេត្តបន្ទាយមានជ័យ (ប៉ោយប៉ែត) សៀមរាប និងបាត់ដំបង ។ ក្នុងចំណោមគោលដៅអន្តរជាតិ ប្រទេសថៃឈរនៅលំដាប់ទីមួយ ។

*ក្រាហ្វិក ២.៤: គោលដៅការងាររបស់សាច់ញាតិយុវជនពលករចំណាកស្រុក*



## ២.៥. ចំណាកស្រុកតាមរដូវ រឺជាអចិន្ត្រៃយ៍?

ក្នុងការសិក្សានេះ ពលករ "តាមរដូវ" សំដៅលើអ្នកដែលមកធ្វើការនៅទីក្រុង ហើយវិលទៅភូមិវិញតាមពេលវេលា យ៉ាងទៀងទាត់ ដើម្បីជួយការងារកសិកម្មក្នុងគ្រួសារ ឯក្រៅពីនេះ ជាពលករ "អចិន្ត្រៃយ៍" ។ ការសិក្សាបង្ហាញថា ក្នុងចំណោម យុវជនពលករចំណាកស្រុក ៤នាក់ ប្រហែលមានម្នាក់ជាពលករ "តាមរដូវ" ។ រឿងនេះគ្មានអ្វីប្លែកទេ ពីព្រោះពួកគេស្ថិតក្នុង វ័យជំទង់ រឺមានអាយុត្រឹមជាង ២០ឆ្នាំ ហើយជារឿយៗ គឺជាកម្លាំងពលកម្មដ៏សំខាន់ក្នុងគ្រួសារ ។ អង្កេតគ្រួសារដំណាក់កាល ទីពីរ នៅខេត្តកំពង់ចាម និងព្រៃវែង ដែលមានបញ្ជូនពលករចំណាកស្រុកច្រើនជាងគេ បានបង្ហាញនូវតួលេខខុសគ្នាបន្តិច (២១%) សម្រាប់យុវជនជាពលករចំណាកស្រុកតាមរដូវ ។

កម្មករសំណង់ ៦០% គឺជាកម្មករតាមរដូវ ។ តាមធម្មតា ពួកគេមិនធ្វើការជាប់ជាមួយក្រុមហ៊ុនណាមួយទេ ប៉ុន្តែ ធ្វើការផ្អែកលើគម្រោង ពោលគឺពេលសំណង់មួយបានបញ្ចប់ ពួកគេប្តូរទៅសំណង់មួយថ្មីទៀត ។ អ្នកខ្លះវិលទៅភូមិវិញ រង់ចាំការទាក់ទងពីមេក្រុមសំណង់ រឺមិត្តភ័ក្តិ ។ ការងាររត់ម៉ូតូឌុប ក៏មានពលករតាមរដូវច្រើនដែរ ។ ពួកគេភាគច្រើន មិនអាចរកការងារធ្វើពេញមួយឆ្នាំបាន ដូច្នេះ ក៏ត្រូវចាប់យកការងារបណ្តោះអាសន្នបែបនេះ ។ ចំពោះពលករស៊ីប្រាក់ឈ្នួលវិញ ក្នុងចំណោមកម្មករលាងរថយន្ត ៥នាក់ មាន ២នាក់ ជាកម្មករតាមរដូវ ហើយចំណុចគួរភ្ញាក់ផ្អើលគឺ ក្នុងចំណោមកម្មករកាត់ដេរ ១០នាក់ មាន ១នាក់ ជាកម្មករតាមរដូវដែរ ។ បុគ្គលិកកាស៊ីណូមានប្រាក់កម្រៃខ្ពស់ជាងគេក្នុងចំណោមពលករទាំង ៨ក្រុម ហើយសុទ្ធតែជាពលករអចិន្ត្រៃយ៍ ។ អ្នករូសរទេះភាគច្រើន និងអ្នកលក់ដូរតូចតាចទាំងអស់ គឺជាពលករអចិន្ត្រៃយ៍ ព្រោះពួកគេ ភាគច្រើនធ្វើចំណាកស្រុកទាំងគ្រួសារតែម្តង ។

ថ្វីបើចំនួនយុវជនចាកចេញពីជនបទបានស្ទុះឡើងក្តី ប៉ុន្តែនៅជនបទមិនទាន់មានរបាយការណ៍ពីកង្វះខាតកម្លាំងពលកម្ម នៅឡើយទេ ។ គ្រួសារមានកូន រឺមានប្តី រឺប្រពន្ធ ធ្វើការជាអចិន្ត្រៃយ៍នៅទីក្រុង ជាទូទៅតែងជួលអ្នកភូមិឯទៀតៗអោយ ធ្វើស្រែឱ្យខ្លួន ដោយបង់អោយគេពី ៤០០០រៀល ទៅ ៥០០០រៀល/ថ្ងៃ ។

ក្រាហ្វិក ២.៥: ការងារតាមរដូវ និងអចិន្ត្រៃយ៍របស់យុវជនពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍




## ២.៦. មូលហេតុនៃការធ្វើចំណាកស្រុក

វិសាលភាព និងទំហំនៃការធ្វើចំណាកស្រុករបស់យុវជន បានឡើងដល់កម្រិតមួយដែលមិនធ្លាប់មានពីមុនមក ។ រឿងនេះមិនមែនថ្មីទេ ប៉ុន្តែនាពេលថ្មីៗនេះ វាកើនឡើងខ្លាំងណាស់ ។ ដូចបានលើកឡើងពីខាងដើម ចំណាកស្រុកនៃកម្លាំង ពលកម្មជាយុវជន បណ្តាលឡើងជាសំខាន់ពីកត្តារុញច្រាន ដោយមានកត្តាទាក់ទាញថែមខ្លះផង ។ ភាពក្រីក្ររ៉ាំរ៉ៃ ភាពអត់ដីធ្លី

ការរេចរិលធនធានធម្មជាតិ/ធនធានទ្រព្យរួម កង្វះការងារពេញមួយឆ្នាំ បំណុល និងគ្រោះធម្មជាតិ បានបង្ខំឱ្យយុវជនជាច្រើននៅជនបទកម្ពុជាធ្វើចំណាកស្រុក ។ តម្រូវការកម្មករគ្មានជំនាញយ៉ាងច្រើនក្នុងវិស័យកាត់ដេរ និងសំណង់ ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន និងទស្សនៈពីការងារមានប្រាក់កម្រៃ និងការចង់បានជីវភាពប្រសើរឡើង បានបង្កើតជាកត្តាទាក់ទាញឱ្យធ្វើចំណាកស្រុក ។ ក្រៅពីនេះ មានយុវជនមួយចំនួនបានធ្វើចំណាកស្រុកជាមួយគ្រួសារខ្លួន ។ ក្នុងករណីមួយចំនួនទៀត និន្នាការសំភារៈនិយម បានអូសទាញខ្លាំងពេក ធ្វើឱ្យយុវជនមួយចំនួនក្នុងគ្រួសារអ្នកមធ្យមដែលមានការហូបចុកគ្រប់គ្រាន់ហើយ ក៏ធ្វើចំណាកស្រុកដែរ ដោយចង់បានឯករាជ្យខាងហិរញ្ញវត្ថុ និងប្រាក់បន្ថែមសម្រាប់ការកំសាន្តសប្បាយ ។

យុវជនចំណាកស្រុកជិតពាក់កណ្តាល បានសម្រេចចិត្តធ្វើចំណាកស្រុក ពីព្រោះគ្មានការងារធ្វើឱ្យបានពេញៗមួយឆ្នាំនៅក្នុងភូមិ ។ កង្វះការងារពេញមួយឆ្នាំ គឺជាកត្តារុញច្រានមួយដ៏ចំបង ប៉ុន្តែវាក៏ស្របគ្នានឹងបំណងរបស់ពួកយុវជន ដែលចង់ចាកចេញពីការងារជាប្រពៃណី (ដូចជា ធ្វើស្រែចំការ រកត្រី) ទៅរកការងារមានប្រាក់កម្រៃពេញមួយឆ្នាំ ព្រោះបានមើលឃើញ/ស្តាប់ឮរឿងជោគជ័យរបស់សាច់ញាតិ មិត្តភ័ក្តិ និងយុវជនផ្សេងទៀត ដែលបានធ្វើចំណាកស្រុកចេញពីភូមិ ។ យុវជនចំណាកស្រុក ១៧% បានលើកពីកង្វះស្បៀងអាហារថាជាមូលហេតុនាំឱ្យធ្វើចំណាកស្រុក ។ កត្តាទី៤ គឺចំណាកស្រុកដោយសារបញ្ហាគ្រួសារ ។ ប៉ុន្តែចំណុចគួរអោយភ្ញាក់ផ្អើលគឺ យុវជនចំណាកស្រុក ៤,២% ឆ្លើយថា ពួកគេធ្វើចំណាកស្រុកដោយសារមានគ្រោះធម្មជាតិ ហើយមានតែ ៣,២% ប៉ុណ្ណោះ ដែលឆ្លើយថា ដោយសារជំពាក់បំណុលគេ ។ ទោះយ៉ាងនេះក្តី អង្កេតគ្រួសារបានបង្ហាញថា យុវជន ១២,៣% បានធ្វើចំណាកស្រុកដោយសារកត្តាបំណុល ។ នាដំណាលគ្នានេះ អង្កេតជាមួយយុវជនចំណាកស្រុក បានឱ្យដឹងថា យុវជន ១០% បានធ្វើចំណាកស្រុកដោយសារកង្វះដីធ្លី និង ៣,២% ដោយសារបំណុល ហើយកត្តាទាំងពីរនេះ គឺជាមូលហេតុចំបងសម្រាប់យុវជនចំណាកស្រុកនៅក្នុងគ្រួសារក្រីក្របំផុត ។

*ក្រាហ្វិក ២.៦: មូលហេតុចំបងនៃចំណាកស្រុករបស់យុវជនពលករចំណាកស្រុក*



# ជំពូកទី ៣ បណ្ដាញសង្គម និងចំណាកស្រុក

## ៣.១. ប្រភពព័ត៌មាន

ទ្រឹស្ដីបណ្ដាញបានកំណត់ថា ចំណាកស្រុកកើតមានឡើងដោយសារមានទំនាក់ទំនងផ្ទាល់ខ្លួន ទំនាក់ទំនងខាងវប្បធម៌ និង/រឺ សង្គម ។ នៅក្នុងតំបន់ រឺប្រទេសនានា យុវជនទទួលបានព័ត៌មានស្ដីពីការងារ និងលក្ខខណ្ឌរស់នៅក្នុងតំបន់ រឺប្រទេសដែលខ្លួនចង់ធ្វើចំណាកស្រុកទៅ តាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន ដូចជា មិត្តភ័ក្តិ និងអ្នកជិតខាង ដែលបានធ្វើចំណាកស្រុក ។ សាច់ញាតិជនចំណាកស្រុក តែងជួយពួកគេអោយរកបានការងារ និងសម្របខ្លួនបានជាមួយបរិយាកាសរស់នៅថ្មី (Oishi Nana 2002, quoted in Kim 2005) ។

ការចាកចេញពីកន្លែងមួយទៅកន្លែងមួយទៀត ទោះបីទៅតាមរដូវ រឺទៅជាអចិន្ត្រៃយ៍ក្ដី តែងមានហានិភ័យ និងបន្ទុកចំណាយហិរញ្ញវត្ថុ និងសង្គម ។ ព័ត៌មានទទួលបានល្អ និងគ្រប់គ្រាន់ អាចជួយកាត់បន្ថយហានិភ័យចំណាកស្រុកបានយ៉ាងច្រើន និងបង្កើនលទ្ធភាពទទួលបានជោគជ័យ ។ ការសិក្សាបង្ហាញថា យុវជនពលករចំណាកស្រុកភាគច្រើន ទទួលព័ត៌មានទាក់ទងនឹងការងារល្អ ការរស់នៅ និងបរិយាកាសការងារនៅទីក្រុងបានតិចតួចបំផុត ។ ពួកគេពឹងផ្អែកខ្លាំងលើប្រភពព័ត៌មានក្រៅផ្លូវការ ហើយព័ត៌មានទទួលបានមុនពេលសម្រេចចិត្តធ្វើចំណាកស្រុក ភាគច្រើនពាក់ព័ន្ធនឹងការងារដែលអាចរកបាន មិនមែនពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ រឺលក្ខខណ្ឌរស់នៅឡើយ ។ ក្នុងករណីភាគច្រើន ពួកគេមិនបានយល់ដឹងគ្រប់គ្រាន់ពីបន្ទុកចំណាយ និងផលប្រយោជន៏នៃការសម្រេចចិត្តនេះទេ ។

យុវជនចំណាកស្រុក ប្រហែល ៥០% បានទទួលព័ត៌មានដំបូងលើឱកាសការងារអំពីសាច់ញាតិ ហើយ ៥០% ទៀតបានដឹងពីសមាជិកគ្រួសារ អ្នកជិតខាង អ្នកភូមិដទៃទៀត រឺមិត្តភ័ក្តិ ។ ចំណុចគួរកត់សំគាល់ គឺប្រព័ន្ធផ្សព្វផ្សាយស្ទើរគ្មានតួនាទីអ្វីសោះ ក្នុងការផ្សព្វផ្សាយព័ត៌មានស្ដីពីការងារទៅដល់ទីជនបទប្រទេសកម្ពុជា ។ រឿងនេះ បង្ហាញពីសារៈសំខាន់នៃបណ្ដាញសង្គម រវាងពលករចំណាកស្រុក និងតំបន់បញ្ជូនចេញពលករ ។ មេក្រុមសំណង់ម្នាក់ នៅក្នុងភូមិសិក្សាមួយ តែងទូរស័ព្ទទៅភូមិកំណើតរបស់គាត់ នៅពេលត្រូវការកម្លាំងពលកម្មបន្ថែម ។ ជាលទ្ធផល កម្មករគ្មានជំនាញរបស់គាត់ ភាគច្រើនជាយុវជនមកពីភូមិគាត់ ។ ដូចគ្នាដែរ អ្នកបម្រើតុក្នុងភោជនីយដ្ឋានមួយ ច្រើនមកពីភូមិជិតខាង រឺភូមិតែមួយជាមួយម្ចាស់ភោជនីយដ្ឋាន ។ ករណីមានបងប្អូន រឺមិត្តភ័ក្តិមកពីភូមិជាមួយគ្នា ចូលធ្វើការក្នុងរោងចក្រ ភោជនីយដ្ឋាន រឺកន្លែងលាងរថយន្តតែមួយ ឃើញមានជាទូទៅណាស់ ។ ឪពុកម្ដាយរបស់យុវជនចំណាកស្រុក ជាទូទៅតែងយល់ថា មិនសូវមានគ្រោះថ្នាក់ទេ បើសិនកូនគាត់មានចៅហ្វាយនាយជាអ្នកមកពីភូមិជាមួយគ្នា និងអាចមាន "ចិត្តស្ងប់" នៅពេលកូនរបស់គាត់មានអ្នករួមការងារជាអ្នកមកពីភូមិជាមួយគ្នា ។ ក្រាហ្វិក ៣.១ បង្ហាញពីអវត្តមានអន្តរការីនៅក្នុងចំណាកស្រុកក្នុងប្រទេស ។ ប៉ុន្តែនៅក្នុងចំណាកស្រុកឆ្លងប្រទេសវិញ អន្តរការីដើរតួនាទីសំខាន់ណាស់ ។

ការមានបណ្ដាញល្អ អាចជាកត្តាជោគជ័យសំខាន់មួយសម្រាប់ពលករចំណាកស្រុក ពីព្រោះវាផ្ដល់ឱកាសល្អ ដើម្បីរកបានការងារ និងមិនងាយត្រូវគេបោកប្រាស់ ។ អវត្តមានបណ្ដាញផ្លូវការ និងវត្តមានបណ្ដាញក្រៅផ្លូវការ ជាលក្ខណៈសំគាល់មួយនៃចំណាកស្រុករបស់យុវជននៅកម្ពុជា ។ ការសិក្សាបង្ហាញថា លក្ខណៈទូទៅមួយនៃចំណាកស្រុករបស់យុវជន គឺដំបូងមានយុវជនម្នាក់ រឺពីរនាក់ ធ្វើចំណាកស្រុក ហើយ ១-២ឆ្នាំ ក្រោយមក ពួកគេត្រឡប់មកភូមិវិញ រួចក៏ផ្សព្វផ្សាយព័ត៌មានពីការងារ និងផលប្រយោជន៏ទទួលបានពីចំណាកស្រុក ។ ជាទូទៅ អ្នកវិលមកភូមិវិញ តែងជួយសម្រួលដល់អ្នកភូមិ

ដទៃទៀត ។ ក្នុងសង្គមប្រពៃណី ដូចជា កម្ពុជា បណ្តាញសង្គមមានមូលដ្ឋាននៅក្នុងភូមិ ហើយរីកដុះដាលលាតចេញដូចសំណាញ់ ប៉ុន្តែសម្រាប់ចំណាកស្រុករបស់យុវជនចេញពីតំបន់ជនបទ បណ្តាញត្រង់មួយបានកកើតឡើង ដែលតភ្ជាប់តំបន់ទីក្រុង និងតំបន់ជនបទ ហើយបានជួយជំរុញដល់ការធ្វើចំណាកស្រុកចេញពីជនបទ ។ ខណៈដែលបណ្តាញជាប្រពៃណីនៅមានដដែល ថ្វីបើចុះខ្សោយជាងមុនខ្លះក្តី ប៉ុន្តែបណ្តាញត្រង់កើតថ្មីកាន់តែរឹងមាំឡើង និងដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួល ដល់ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង ។ ជាការច្បាស់ណាស់ ដែលអ្នកនៅខាងក្រៅបណ្តាញថ្មីនេះ ត្រូវជួបការលំបាកកាន់តែខ្លាំងក្នុងការធ្វើចំណាកស្រុក ។

*ក្រាហ្វិក ៣.១: ប្រភពព័ត៌មានពាក់ព័ន្ធនឹងការងារ*




## ៣.២. ការធ្វើដំណើរតែម្នាក់ឯង រឺមានគ្នា

វត្តមានអ្នករួមដំណើរ មានសារៈសំខាន់ណាស់សម្រាប់យុវជនពលករចំណាកស្រុក ជាពិសេសនារី ។ យុវជនចំណាកស្រុកភាគច្រើនមិនធ្លាប់ទៅទីក្រុងទេ ហើយការធ្វើដំណើរទៅរកការងារនៅទីក្រុង គឺជាដំណើរលើកដំបូងរបស់ពួកគេ ។ម្យ៉ាងទៀត ឪពុកម្តាយភាគច្រើន តែងរារែកខ្លាំងក្នុងការបណ្តោយអោយកូនខ្លួនធ្វើដំណើរតែឯង ។ ជាក់ស្តែង មានយុវជនចំណាកស្រុកតែ ២០% ប៉ុណ្ណោះ ដែលធ្វើដំណើរទៅទីក្រុងតែម្នាក់ឯង ក្រៅពីនេះ សុទ្ធតែធ្វើដំណើរដោយមានគ្នា ដូចជា ជាមួយសាច់ញាតិ រឺសមាជិកគ្រួសារជាដើម ។ ក្នុងចំណោមពលករបុរស អ្នកឆ្លើយសម្ភាសន៍មាន ២៦,៨៥% បានធ្វើដំណើរតែឯង រីឯខាងពលករនារីមានតែ ១៤,៤០% ប៉ុណ្ណោះ ។

*ក្រាហ្វិក ៣.២: អ្នករួមដំណើរជាមួយយុវជនពលករចំណាកស្រុក*



## ៣.៣. ការចំណាយ

មូលធនសង្គម និងហិរញ្ញវត្ថុ ជាកត្តាដ៏សំខាន់ដែលកំណត់ថា យុវជនណាម្នាក់អាចធ្វើចំណាកស្រុកបាន រឺអត់ ។ គេគិតថា ការសូកប៉ាន់ ក៏មានតួនាទីសំខាន់ដែរ សម្រាប់ការរកបានការងារនៅទីក្រុង ហើយវាអាចជាឧបសគ្គដ៏ធំមួយចំពោះអ្នកក្រ និង អ្នកក្របំផុត ដែលមានប្រាក់តិចតួចសម្រាប់ចំណាយលើការធ្វើដំណើរ ការហូបចុក និងការស្នាក់នៅបណ្តោះអាសន្ន ។ ទោះជា យ៉ាងនេះក្តី ការសូកប៉ាន់ ឃើញមានរាយការណ៍តែក្នុងចំណោមកម្មកររោងចក្រកាត់ដេរប៉ុណ្ណោះ ដោយមាន ១០% បានបង់ប្រាក់ ដើម្បីបានការងារធ្វើក្នុងរោងចក្រ ។ ទឹកប្រាក់ត្រូវបង់ជាមធ្យម គឺ ១០២.០០០រៀល[១១] ដែលច្រើនខ្លាំងណាស់សម្រាប់ប្រជាជន នៅជនបទ ។ ទឹកប្រាក់សូកប៉ាន់ជាក់ស្តែង ប្រែប្រួលពី ២០.០០០រៀល ដល់ ៤០០.០០០រៀល ។

*តារាង ៣.១: តើអ្នកមានសូកប៉ាន់អ្នកណា ដើម្បីទទួលបានការងារបច្ចុប្បន្ននេះទេ?*

| | ប្រភេទការងារ | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | អ្នកបម្រើ ប្រុស/ស្រី | អ្នករត់ម៉ូតូឌុប | កម្មករសំណង់ | កម្មកររោងចក្រ | កម្មករលាងរថយន្ត | អ្នកលក់ដូរតូចតាច | បុគ្គលិកកាស៊ីណូ | អ្នកអូសរទេះ | |
| មានសូក | 0 | 0 | 0 | 12 | 0 | 0 | 0 | 0 | 12 |
| គ្មានទេ | 120 | 120 | 120 | 108 | 30 | 30 | 30 | 30 | 588 |

ពិតមែនតែពលករមិនស៊ីប្រាក់បៀវត្សរ៍ទាំងបីក្រុម (អ្នករត់ម៉ូតូឌុប អ្នកលក់ដូរតូចតាច និងអ្នកអូសរទេះ) មិនចាំបាច់ សូកប៉ាន់នរណា ដើម្បីបានការងារធ្វើក្តី ប៉ុន្តែអ្នករត់ម៉ូតូឌុបត្រូវការដើមទុនមួយចំនួនសម្រាប់ចាប់ផ្តើមអាជីវកម្មរបស់ខ្លួន ពោលគឺ ត្រូវចំណាយជាច្រើនរយដុល្លារ ដើម្បីទិញម៉ូតូប្រើហើយមួយគ្រឿងដែលនៅល្អគួរសម រឺត្រូវចំណាយលើសពី ១០០០ដុល្លារ ដើម្បីទិញម៉ូតូថ្មីមួយ ។ តាមការរាយការណ៍ អ្នកលក់ដូរតូចតាចត្រូវបង់ប្រាក់អោយទៅអាជ្ញាធរសម្រាប់កន្លែងលក់ដូរ រឺក៏ ដើម្បីកុំអោយគេដេញក្រោមមូលហេតុថា "រក្សាសណ្តាប់ធ្នាប់សាធារណៈ" ។ អ្នកអូសរទេះ ក៏ត្រូវចែករំលែកប្រាក់បន្តិចបន្តួច ដែលខ្លួនរកបានយ៉ាងលំបាកទៅអោយប៉ូលីសព្រំដែន នៅពេលអូសរទេះកាត់ព្រំដែនដែរ ។ អ្នកអូសរទេះមិនត្រូវការដើមទុនទេ ហើយភាគច្រើនពុំមានរទេះផ្ទាល់ខ្លួនឡើយ គឺគាត់ជួលរទេះគេប្រើក្នុងតម្លៃ ២០បាត/ថ្ងៃ ។

## ៣.៤. បន្ទុកចំណាយពាក់ព័ន្ធនឹងចំណាកស្រុក

គេបានចាត់ទុកថា ចំណាកស្រុកជាវិនិយោគមួយជាយូរណាស់មកហើយ ។ គោលដៅសំខាន់នៃចំណាកស្រុក ជាពិសេស ការចេញពីជនបទមកទីក្រុង គឺដើម្បីធ្វើអោយស្ថានភាពសេដ្ឋកិច្ចប្រសើរឡើង ។ នៅជនបទកម្ពុជា គេតែងប្រមែប្រមូលដើមទុន ដើម្បីអោយសមាជិកគ្រួសារអាចធ្វើចំណាកស្រុក ។ ថវិកាភាគច្រើន ទុកសម្រាប់ចំណាយលើការធ្វើដំណើរ ហូបចុក និង ស្នាក់នៅ រហូតទាល់តែរកបានការងារ ។ ការសិក្សាបង្ហាញថា ជាមធ្យម យុវជនពលករចំណាកស្រុក ត្រូវចំណាយ ២៧.៨០០រៀល ចាប់តាំងពីពេលចាកចេញពីផ្ទះ រហូតទទួលបានការងារ ។ ប្រាក់ទាំងនេះ ភាគច្រើនត្រូវចំណាយលើការធ្វើដំណើរ និងម្ហូបអាហារ ។ ជាទូទៅ ជនចំណាកស្រុកតែងទទួលបានការស្នាក់នៅដោយឥតគិតថ្លៃ ពីសាច់ញាតិ រឺមិត្តភ័ក្តិមកពីភូមិជាមួយគ្នា ។

---

១១ ប្រាក់រៀល ជារូបិយវត្ថុជាតិក៏ពិតមែន ប៉ុន្តែប្រាក់ដុល្លារ និងប្រាក់បាត មានប្រើប្រាស់យ៉ាងទូលាយនៅកម្ពុជា ។ ប្រាក់បាតមាន ប្រើប្រាស់ច្រើននៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដែលនៅជិតព្រំដែនថៃ រីឯប្រាក់ដុល្លារ មានប្រើប្រាស់ច្រើននៅខេត្តសៀមរាប ដែលជាតំបន់ទេសចរណ៍សំខាន់នៅកម្ពុជា ។ អ្នកឆ្លើយសំនួរ បានផ្តល់ព័ត៌មានជាប្រាក់រៀល ដុល្លារ និងបាត ។ នៅពេលធ្វើការសិក្សានេះ នៅពាក់កណ្តាលឆ្នាំ២០០៧ អត្រាប្តូរប្រាក់គឺ ១ដុល្លារ=៤១០០រៀល និង ១បាត=១២០រៀល ។

ពលករចំណាកស្រុកម្នាក់ ត្រូវចំណាយជាមធ្យម ៦ថ្ងៃ ចាប់ពីពេលចាកចេញពីផ្ទះ រហូតរកបានការងារ ។ ពួកគេមួយចំនួន រកបានការងារតាមរយៈសាច់ញាតិ រឺមិត្តភ័ក្តិ តាំងពីមុនពេលចេញដំណើរម្ល៉េះ ហើយចូលធ្វើការភ្លាមនៅពេលទៅដល់ទីក្រុង ។

## ៣.៥. ប្រភពហិរញ្ញវត្ថុ

នៅពេលសាកសួរពីប្រភពហិរញ្ញវត្ថុ មានមួយភាគបី បានលើកពីប្រាក់សន្សំក្នុងគ្រួសារ ។ ប្រាក់សន្សំផ្ទាល់ខ្លួនឈរនៅលំដាប់ទីពីរ រីឯប្រាក់កម្ចី និងការលក់ទ្រព្យសម្បត្តិ ឈរនៅលំដាប់ទីបី និងទីបួន ។ មាន ៥% ទទួលបានប្រាក់ពីសាច់ញាតិ និង ៣% ទទួលបានពីអនាគតថៅហ្វាយនាយ ។ ការដែលមាន ៣៧% បានខ្ចីប្រាក់គេ រឺលក់ទ្រព្យសម្បត្តិ វាជួយបកស្រាយពីមូលហេតុដែលគ្រួសារមួយចំនួនមានជីវភាពកាន់តែលំបាក ក្រោយពេលបរាជ័យក្នុងការធ្វើចំណាកស្រុក ។ ប្រាក់កម្ចីបានដាក់សំពាធលើយុវជនចំណាកស្រុក អោយខិតខំរកចំណូលអោយបានច្រើន ដើម្បីសងប្រាក់ដែលខ្ចីពីគេនៅមុនពេលចេញដំណើរ ។

*ក្រាហ្វិក ៣.៣: ប្រភពហិរញ្ញវត្ថុសម្រាប់ចំណាយលើការធ្វើដំណើរ និងរកការងារ របស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍*




នៅជនបទប្រទេសកម្ពុជា អ្នកក្រ និងអ្នកក្របំផុត ខ្វះថវិកា សូម្បីសម្រាប់ធ្វើវិនិយោគតូចតាចបំផុត ។ ពួកគេភាគច្រើនពឹងផ្អែកលើប្រាក់កម្ចីពីអ្នកចងការប្រាក់ រឺស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ។ អ្នកចងការប្រាក់ ជាមធ្យោបាយជាប្រពៃណី រីឯ MFIs ដែលទើបចូលទៅដល់ជនបទកម្ពុជានាពេលថ្មីៗ គឺជាជម្រើសមួយបន្ថែមទៀតសម្រាប់អ្នកក្រ ។ ទោះយ៉ាងនេះក្តី កម្ចី គឺជាការសម្រេចចិត្តដ៏ធ្ងន់ធ្ងរមួយសម្រាប់អ្នកក្រនៅជនបទ ។ តាមធម្មតា អ្នកចងការប្រាក់មិនទាមទាររបស់បញ្ចាំទេ ប៉ុន្តែគិតការប្រាក់ខ្ពស់ណាស់ មិនតិចជាង ១០% ក្នុងមួយខែទេ ។ ផ្ទុយទៅវិញ MFIs គិតការប្រាក់ត្រឹម ៣% ក្នុងមួយខែ ប៉ុន្តែតម្រូវអោយអ្នកខ្ចីដាក់របស់បញ្ចាំ ដែលក្នុងករណីភាគច្រើន គឺជាដីស្រែ ។

# ជំពូកទី ៤ សមាហរណកម្មចូលក្នុងបរិយាកាសទីក្រុង

## ៤.១. ការចូលរួមក្នុងសកម្មភាពសង្គមនៅពេលទំនេរ

យុវជនចំណាកស្រុកភាគច្រើនឆ្លើយថា ការធ្វើដំណើរមកកាន់ទីក្រុងដើម្បីរកការងារ គឺជាដំណើរលើកដំបូងរបស់ខ្លួន ។ ការសិក្សាបង្ហាញថា ការធ្វើសមាហរណកម្មចូលក្នុងជីវភាពទីក្រុងរបស់ពួកគេ មានលក្ខណៈ "រាក់កំភែលបំផុត" ។ មិត្តភ័ក្តិថ្មីរបស់ពួកគេ ច្រើនជាអ្នកមកពីតំបន់ជនបទផ្សេងទៀតនៃប្រទេសកម្ពុជា ជាជាងអ្នកទីក្រុងដែលពួកគេកំពុងរស់នៅ ។ ជាទូទៅ ពួកគេរវល់ពេក រឺមួយខ្លាចមិនហ៊ានចេញដើរខាងក្រៅ រឺមួយមិនចង់ចំណាយប្រាក់ដើម្បីស្គាល់ពីទីក្រុង ។ តួយ៉ាងដូចជា អ្នកបម្រើភោជនីយដ្ឋាន តែងនៅតែក្នុងកន្លែងធ្វើការ និងកម្រចេញទៅក្រៅណាស់ ចំណែកឯកម្មករលាងរថយន្ត ក៏ដូចគ្នាដែរ ។ កម្មករសំណង់ភាគច្រើន ស្នាក់នៅតែក្នុងរោង/ខ្ទម ដែលនៅក្នុង រឺនៅជុំវិញកន្លែងសាងសង់ ហើយពួកកម្មករកាត់ដេរស្គាល់ត្រឹមតែផ្លូវទៅកាន់កន្លែងធ្វើការប៉ុណ្ណោះ ។

ជិតពាក់កណ្តាលនៃអ្នកឆ្លើយសំនួរ ប្រាប់ថា "គ្មានទៅណាទេ" នៅពេលសាកសួរពីសកម្មភាពនៅពេលទំនេរ ។ អ្នកឆ្លើយសម្ភាសន៍ ១៦,៦៦% ប្រាប់ថា ទៅជួបសមាជិកគ្រួសារ/មិត្តភ័ក្តិ ១៤,៦៦% ទៅដើរលេងជាមួយមិត្តភ័ក្តិ ៥% ឆ្លើយថា គ្មានពេលទំនេរ ហើយ ២,៦៦% ប្រាប់ថា ប្រើពេលទំនេរខំរៀនសូត្រ ដែលភាគច្រើន គឺការសិក្សាភាសាបរទេស ។ កម្រិតសិក្សាជាមធ្យមរបស់ជនចំណាកស្រុក គឺ ៦,៣៩ឆ្នាំ និងមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលខិតខំឆ្លៀតពេលឆក់យកឱកាសល្អនៃការអប់រំនៅទីក្រុង ។ ពិតណាស់ ការសិក្សាមានសារៈសំខាន់តិចជាងការរកការងារ និងប្រាក់ចំណូលឱ្យបាន ។ អ្នកឆ្លើយសម្ភាសន៍ ៦៦% ផ្សេងទៀត មិនបានឆ្លើយសំនួរទេ ។

*តារាង ៤.១: សកម្មភាពរបស់យុវជនពលករចំណាកស្រុកនៅពេលទំនេរ*

| សកម្មភាពនៅពេលទំនេរ | ចំនួន | ភាគរយ |
|---|---|---|
| មិនទៅណា | 281 | 46.83 |
| ជួបសមាជិកគ្រួសារ/មិត្តភ័ក្តិ | 101 | 16.83 |
| ដើរលេងជាមួយមិត្តភ័ក្តិ | 88 | 14.66 |
| គ្មានពេលទំនេរ | 31 | 5.16 |
| សិក្សា | 16 | 2.66 |
| ជួយធ្វើការងារផ្ទះ | 10 | 1.66 |
| ផ្សេងៗ | 7 | 1.16 |
| សរុប | 534 | 89.00 |

មិត្តភ័ក្តិដែលធ្វើចំណាកស្រុកចេញមកពីភូមិជាមួយគ្នា និយាយថា ពួកគេជួបគ្នាជាញឹកញាប់នៅពេលទំនេរ ។ សាច់ញាតិ រឺសមាជិកគ្រួសារ ជាអ្នកជិតស្និទ្ធទីពីរ បន្ទាប់មក គឺមិត្តភ័ក្តិថ្មី ហើយបន្ទាប់មកទៀត គឺអ្នករួមការងារ ។ ការដែលយុវជនចំណាកស្រុក តែងជួបមិត្តភ័ក្តិចាស់ច្រើនជាងជួបមិត្តភ័ក្តិថ្មី បង្ហាញថា បណ្តាញ និងទំនាក់ទំនង ដែលកសាងកន្លងមកនៅតែ

មាំទាំ ។ ភាគតិចប៉ុណ្ណោះ ដែលរកមិត្តភ័ក្តិថ្មី ហើយមិត្តភ័ក្តិថ្មីទាំងនោះ ភាគច្រើនជាអ្នកធ្វើចំណាកស្រុកចេញពីជនបទដែរ ។ នេះជាទំនាក់ទំនងជនបទ និងជនបទ ជាជាងជនបទ និងទីក្រុង ។ ទំនាក់ទំនងរវាងយុវជនពលករចំណាកស្រុក និងម្ចាស់ផ្ទះរបស់ពួកគេមានតិចតួចណាស់ ។

*ក្រាហ្វិក ៤.១: អ្នកដែលយុវជនចំណាកស្រុកជួបច្រើនជាងគេនៅពេលទំនេរ*




## ៤.២. ប្រភេទនៃការស្នាក់នៅ

ប្រភេទការស្នាក់នៅ ខុសគ្នាខ្លាំងទៅតាមប្រភេទការងារ ។ តាមការសម្ភាស យុវជនពលករចំណាកស្រុក ៣៣% រស់នៅក្នុងផ្ទះជួល ជាង ២៥% រស់នៅក្នុងសយនដ្ឋាន ដែលនិយោជកផ្តល់ឱ្យដោយឥតគិតថ្លៃ និង ជាង ១៧% រស់នៅការដ្ឋានសំណង់ ។ កម្មករភោជនីយដ្ឋាន ១០៤នាក់ក្នុងចំណោមកម្មករ ១២០នាក់ រស់នៅក្នុងសយនដ្ឋាន ដោយឥតបង់ថ្លៃ ។ អ្នករត់ម៉ូតូឌុបជាង ៥០% រស់នៅក្នុងផ្ទះជួល ឯក្រៅពីនេះ ភាគច្រើនរស់នៅជាមួយសាច់ញាតិ ។ កម្មករកាត់ដេរ ៧៥% រស់នៅក្នុងផ្ទះជួល ហើយក្រៅពីនេះ រស់នៅក្នុងសយនដ្ឋានមានបង់ថ្លៃ រឺគ្មានបង់ថ្លៃ រឺរស់នៅជាមួយសាច់ញាតិ ។ ដោយឡែកកម្មករលាងរថយន្តទាំងអស់ រស់នៅក្នុងសយនដ្ឋានឥតបង់ថ្លៃ ផ្តល់ឱ្យដោយម្ចាស់យានដ្ឋាន ។ ការស្នាក់នៅរបស់អ្នកលក់ដូរតូចតាច មានពីរករណី: ទីមួយ រស់នៅក្នុងផ្ទះរបស់ខ្លួនផ្ទាល់ និង ទីពីរ រស់នៅជាមួយសាច់ញាតិ ពីព្រោះអ្នកលក់ដូរតូចតាចភាគច្រើនធ្វើចំណាកស្រុកជាគ្រួសារ ។ អ្នកអូសរទេះមួយចំនួន ក៏ធ្វើចំណាកស្រុកជាគ្រួសារដែរ ក្នុងនេះ ២០% រស់នៅក្នុងផ្ទះខ្លួនឯង ជាង ២០% ទៀត រស់នៅជាមួយសាច់ញាតិ និង ប្រហែល ៥០% រស់នៅក្នុងផ្ទះជួល ។ បុគ្គលិកកាស៊ីណូប្រហែល ៦៧% រស់នៅក្នុងផ្ទះជួល ហើយក្រៅពីនេះ រស់នៅក្នុងសយនដ្ឋានឥតបង់ថ្លៃ ។

អ្នកត្រូវបង់ប្រាក់សម្រាប់ការស្នាក់នៅ (សយនដ្ឋាន រឺផ្ទះជួល) គេបង់ជាមធ្យម ៤២.៦០០រៀល/ខែ ។ ករណីជាទូទៅមួយ គឺយុវជនពលករចំណាកស្រុកតែងរួមគ្នាជាក្រុម មានពី ៤ ទៅ ៧នាក់ ជាមួយអ្នករួមការងារ ដើម្បីជួលផ្ទះនៅ ដោយកាត់បន្ថយចំណាយអោយនៅតិចបំផុត ។ ស្ថានភាពអ្នកអូសរទេះនៅប៉ោយប៉ែត លំបាកខ្លាំងជាងគេ ដោយផ្ទះជួលតម្លៃថោករបស់ពួកគេស្ថិតនៅលើភក់ជ្រាំ មានគំនរសំរាមនៅជុំវិញ និងគ្មានប្រព័ន្ធអគ្គិសនី រឺទឹកស្អាតឡើយ ។ ស្ថានភាពអ្នកទទួលបានសយនដ្ឋានឥតបង់ថ្លៃ ក៏មិនប្រសើរជាងនេះប៉ុន្មានទេ ។ នៅក្រុងសៀមរាប កម្មករសំណង់មួយក្រុម មានគ្នា ១៥នាក់ គេរស់នៅរួមគ្នាក្នុងជម្រកបណ្តោះអាសន្នមួយ ប្រវែង ៥ គុណនឹង ៦ម៉ែត្រ ដោយគ្មានអគ្គិសនី ទឹក និងបង្គន់អនាម័យឡើយ ។ បង្គន់អនាម័យមួយនៅក្បែរនោះ ត្រូវប្រើប្រាស់រួមគ្នា ដោយកម្មកររាប់រយនាក់ ដែលធ្វើការក្នុងគម្រោងសាងសង់ដ៏ធំមួយ ។

*តារាង ៤.២: ការស្នាក់នៅរបស់យុវជនពលករចំណាកស្រុក*

| | ប្រភេទ | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | សយនដ្ឋានឥតបង់ថ្លៃ | សយនដ្ឋានបង់ថ្លៃ | ផ្ទះជួល | នៅជាមួយសាច់ញាតិ | ផ្ទះខ្លួនឯង | រស់នៅកន្លែងសំណង់ | គ្មានជម្រក (ឧ.តាមផ្លូវ) | |
| អ្នកបម្រើតុ | 104 | 2 | 8 | 2 | 4 | 0 | 0 | 120 |
| អ្នករត់ម៉ូតូឌុប | 0 | 1 | 65 | 41 | 13 | 0 | 0 | 120 |
| កម្មករសំណង់ | 0 | 0 | 8 | 0 | 1 | 111 | 0 | 120 |
| កម្មកររោងកាត់ដេរ | 15 | 6 | 90 | 8 | 1 | 0 | 0 | 120 |
| កម្មករលាងរថយន្ត | 30 | 0 | 0 | 0 | 0 | 0 | 0 | 30 |
| អ្នកលក់ដូរតូចតាច | 2 | 0 | 3 | 11 | 13 | 0 | 1 | 30 |
| បុគ្គលិកកាស៊ីណូ | 8 | 2 | 19 | 0 | 1 | 0 | 0 | 30 |
| អ្នកអូសរទេះ | 1 | 0 | 15 | 8 | 6 | 0 | 0 | 30 |
| សរុប | 160 | 11 | 208 | 70 | 39 | 111 | 1 | 600 |

## ៤.៣. អ្នករួមបន្ទប់

យុវជនចំណាកស្រុក ៣៨% រស់នៅជាមួយសាច់ញាតិ ដែលមានមួយចំនួន ជាពលករចំណាកស្រុកដូចគ្នា ។ យុវជនចំណាកស្រុកប្រហែល ២០% មានអ្នករួមបន្ទប់ជាអ្នកមកពីភូមិតែមួយ គឺច្រើនបន្តិចជាងយុវជនដែលមានអ្នករួមបន្ទប់ជាអ្នករួមការងារ ហើយរឿងនេះដោយសារទំនាក់ទំនងដែលបានកសាងឡើងនៅក្នុងភូមិ ។ គេឃើញមានច្រើនដែរនូវយុវជនចំណាកស្រុកចេញមកពីភូមិតែមួយ ដែលមកផ្តុំគ្នានៅការដ្ឋានសំណង់ ភោជនីយដ្ឋាន យានដ្ឋាន រឺរោងចក្រកាត់ដេរតែមួយ ។ កម្មករដែលរស់នៅតែឯង មានតិចជាង ២% ។

សរុបមក ការធ្វើសមាហរណកម្មរបស់យុវជនចំណាកស្រុកចូលទៅក្នុងទីក្រុង គឺនៅមានកម្រិតតិចតួចនៅឡើយ ។ យុវជនភាគច្រើន ពុំហ៊ានធ្វើដំណើរទៅកាន់តំបន់កណ្តាលទីក្រុងទេ គឺនៅតែជាមួយសាច់ញាតិ រឺមិត្តភ័ក្តិ ដែលមកពីភូមិជាមួយគ្នា ។ ពួកគេគ្មានលទ្ធភាពទទួលបានកម្រិតជីវភាពខ្ពស់ដូចអ្នកនៅទីក្រុងទេ ។ ប៉ុន្តែពួកគេភាគច្រើន ហាក់ដូចមិនសូវយកចិត្តទុកដាក់ពីរឿងអ្វីផ្សេង ក្រៅពីលទ្ធភាពរកប្រាក់បាននោះទេ ។ មានយុវជនមិនច្រើនទេ ដែលបានត្អូញត្អែរពីកម្រិតធ្វើសមាហរណកម្មចូលទៅក្នុងជីវភាពទីក្រុង រឺពីគុណភាពជីវិតរបស់ពួកគេ ។

*តារាង ៤.៣: អ្នករួមបន្ទប់របស់យុវជនពលករចំណាកស្រុក*

| តើអ្នកស្នាក់នៅជាមួយនរណា? | ចំនួន | ភាគរយ |
|---|---|---|
| សាច់ញាតិ | 126 | 37.95 |
| អ្នកមកពីភូមិជាមួយគ្នា | 68 | 20.48 |
| អ្នករួមការងារ | 60 | 18.07 |
| គ្រួសារ | 41 | 12.35 |
| មិត្តភ័ក្តិ | 31 | 9.34 |
| ម្នាក់ឯង | 6 | 1.80 |
| សរុប | 332 | 100.00 |

## ៤.៤. ការបណ្តុះបណ្តាលជំនាញ និងរយៈពេល

យុវជនចំណាកស្រុកភាគច្រើន មានតែការអប់រំជាមូលដ្ឋានមួយចំនួនប៉ុណ្ណោះ និងគ្មានជំនាញ រឺការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារឡើយ ។ ទោះយ៉ាងនេះក្តី គួរពិចារណាដែរថា ប្រជាជនកម្ពុជានៅជនបទ ៧៣% មិនបានបញ្ចប់បឋមសិក្សាទេ ហើយនៅក្នុងសហគមន៏ដែលបញ្ជូនពលករចេញ ពួកយុវជនពលករចំណាកស្រុកដែលមានការអប់រំជាមធ្យម ៦,៣៩ឆ្នាំ គឺស្ថិតក្នុងចំណោមអ្នកមានការអប់រំយ៉ាងល្អ ។ ផ្អែកលើ FGD ពួកគេជាក្តីសង្ឃឹមធំបំផុតរបស់ក្រុមគ្រួសារ ។ ចំណាកស្រុកមិនមែនជាមូលហេតុធ្វើអោយពួកគេបោះបង់ការសិក្សាទេ ។ ការបោះបង់ការសិក្សាភាគច្រើន បណ្តាលមកពីស្ថានភាពហិរញ្ញវត្ថុគ្រួសារ និងការលំបាកធ្វើដំណើរទៅរៀនជាវិទ្យាល័យនៅឆ្ងាយពីផ្ទះ ដែលជាទូទៅ ស្ថិតនៅក្នុងទីរួមស្រុក រឺឃុំ ។

យុវជនពលករចំណាកស្រុកភាគច្រើន ទទួលបានការងារប្រើជំនាញតិច រឺមិនប្រើជំនាញ ។ ក្នុងចំណោមក្រុមគំរូតាងទាំង៨ មាន ៥ក្រុម (កម្មករសំណង់ អ្នកបម្រើតុភោជនីយដ្ឋាន កម្មករកាត់ដេរ កម្មករលាងរថយន្ត និងបុគ្គលិកកាស៊ីណូ) ទទួលបានការងារមានប្រាក់បៀវត្សរ៍ ។ ប៉ុន្តែក្នុងចំណោមកម្មករ ៥ក្រុមនេះ មានតិចនាក់ណាស់ ដែលទទួលបានការបណ្តុះបណ្តាលមុនពេលចាប់ផ្តើមការងារ ។ គ្មានកម្មករលាងរថយន្តណាម្នាក់ទទួលបានការបណ្តុះបណ្តាលទេ និងមានតែកម្មករសំណង់ ៥% និងអ្នកបម្រើ ៧,៥០% ប៉ុណ្ណោះ ដែលទទួលបានការបណ្តុះបណ្តាលមូលដ្ឋានមួយចំនួន ។ ប៉ុន្តែកម្មករកាត់ដេរ និងបុគ្គលិកកាស៊ីណូជាករណីលើកលែង ព្រោះសម្រាប់ពីរក្រុមនេះ មានកម្មករ ៣០% និង ៦០% ទទួលបានការបណ្តុះបណ្តាល ។ គិតជារួម ការបណ្តុះបណ្តាលការងារមានរយៈពេលជាមធ្យម ១៧ថ្ងៃ ។

*ក្រាហ្វិក ៤.២: ការបណ្តុះបណ្តាលជំនាញនៃយុវជនពលករចំណាកស្រុក*




## ៤.៥. លទ្ធភាពទទួលបានការថែទាំសុខភាព

ដោយសារការសិក្សានេះ ធ្វើឡើងនៅតំបន់ទីក្រុង លទ្ធភាពទទួលបានការថែទាំសុខភាពមិនចោទជាបញ្ហាទេ សម្រាប់យុវជនចំណាកស្រុកដែលឆ្លើយសម្ភាសន៏ ។ ពលករចំនួនមួយភាគបី មិនធ្លាប់ឈឺទេចាប់តាំងពីធ្វើចំណាកស្រុក ។ ចំពោះអ្នកធ្លាប់មានជំងឺ ភាគច្រើនជាជំងឺស្រាលៗ ដូចជា ឈឺក្បាល វិលមុខ និងរាគរូសជាដើម ហើយកន្លែងលក់ថ្នាំពេទ្យ គឺជាប្រភពព្យាបាលដ៏សំខាន់ ដែលជួយមនុស្សបាន ៧០% ។ ប្រហែល ១៤% ទៅរកគ្លីនិកឯកជន និងតិចជាង ១០% ទៅរកមន្ទីរពេទ្យសាធារណៈ រឺមណ្ឌលសុខភាពសាធារណៈ ។ អ្នកឆ្លើយសម្ភាសន៏ភាគច្រើន បង្ហាញពីការមិនជឿជាក់ចំពោះប្រព័ន្ធសុខភាព

សាធារណៈ មានការបារម្ភខ្លាំងអំពីជំនាញ និងឥរិយាបថរបស់បុគ្គលិកនៅទីនោះ ព្រមទាំងខ្លាចទទួលបានការថែទាំមិនល្អ ។ មាន ៦% ពឹងផ្អែកលើការកោសខ្យល់[១២] និង ១% ទៅរកគ្រូថ្នាំបុរាណ ។

ករណីមានជំងឺក្រពះធ្ងន់ធ្ងរ ឃើញមានរាយការណ៍ ២-៣ ករណី ។ កម្មករភាគច្រើន និយាយថា នៅពេលមានជំងឺតូចតាច ពួកគេទៅធ្វើការទាំងឈឺ មិនបានសុំច្បាប់ទេ ។ មានករណីធ្ងន់ធ្ងរតិចតួច ដែលកម្មករត្រូវត្រឡប់ទៅព្យាបាលខ្លួននៅឯផ្ទះក្នុងភូមិវិញ ជាជាងការទទួលយកសេវាថែទាំសុខភាពដ៏ល្អនៅទីក្រុង ពីព្រោះពុំមានអ្នកនៅកំដរជួយមើលថែទាំ ប្រសិនបើព្យាបាលនៅមន្ទីរពេទ្យឯទីក្រុង ។

*តារាង ៤.៤: លទ្ធភាពទទួលបានការថែទាំសុខភាពរបស់យុវជនពលករចំណាកស្រុក*

| តើអ្នកធ្លាប់ឈឺទេ ចាប់ពីមករស់នៅកន្លែងបច្ចុប្បន្ន ? | ចំនួន | % | តើអ្នកតែងទៅព្យាបាលនៅកន្លែងណា? | ចំនួន | % |
|---|---|---|---|---|---|
| បាទ/ចាស | 400 | 66.66 | កន្លែងលក់ថ្នាំពេទ្យ | 279 | 69.75 |
| ទេ | 200 | 33.33 | គ្លីនិកឯកជន | 55 | 13.75 |
| សរុប | 600 | 100.00 | មន្ទីរពេទ្យ/មណ្ឌលសុខភាពសាធារណៈ | 38 | 9.50 |
| | | | កោសខ្យល់ | 24 | 6.00 |
| | | | គ្រូថ្នាំបុរាណ | 4 | 1.00 |
| | | | សរុប | 400 | 100.00 |

## ៤.៦. បញ្ហាប្រឈម និងការលំបាក

ពលករឆ្លើយសម្ភាសន៍ភាគច្រើន បានរាយការណ៍ពីភាពងាយស្រួលក្នុងការរស់នៅឯទីក្រុង ។ ទោះបីត្រូវធ្វើការពី ១២ ទៅ ១៤ម៉ោង/ថ្ងៃ និង ៧ថ្ងៃ/សប្តាហ៍ ក៏ដោយ ក៏មិនសូវមានអ្នកត្អូញត្អែរពីការលំបាកទេ ។ រឿងនេះ បញ្ជាក់ថែមទៀតថា យុវជនចំណាកស្រុក យកចិត្តទុកដាក់ខ្លាំងណាស់លើការរកប្រាក់ចំណូល និងតិចតួចណាស់លើលក្ខខណ្ឌការងារ ការរស់នៅ រឺសុខុមាលភាពជាទូទៅរបស់ពួកគេ ។ ការត្អូញត្អែរខ្លាំងជាងគេក្នុងចំណោមពលករ ដែលបានរាយការណ៍ពីការលំបាក គឺ "ការរើសអើង" និង "ការស្តីបន្ទោស" របស់ចៅហ្វាយ រឺអតិថិជន ។

អ្នកបម្រើភោជនីយដ្ឋាន ទទួលរងការស្តីបន្ទោសច្រើនជាងក្រុមពលករដទៃទៀត ហើយបុគ្គលិកនៅកាស៊ីណូ ក៏ត្រូវប្រឈមជាសំខាន់នឹងបញ្ហានេះដែរ ។ អ្នករត់ម៉ូតូឌុប ច្រើនជួបប្រទះបញ្ហាប្រាក់កាសជាមួយអតិថិជន និងការរើសអើងពីភ្ញៀវ ជាបន្ថែមលើបញ្ហាសន្តិសុខ (ប្លន់ប្រដាប់អាវុធ ជាពិសេសចំពោះអ្នករត់ម៉ូតូនៅពេលយប់) ។ យុវជនអ្នកអូសរទេះ និយាយថា ទំនាស់ជាមួយអាជ្ញាធរ ជាបញ្ហាចំបងសម្រាប់ពួកគេ ដោយមានច្រើននាក់ត្អូញត្អែរយ៉ាងខ្លាំងពីរឿងអាជ្ញាធរជរិតយកប្រាក់ដែលពួកគេខំរកបានយ៉ាងលំបាក ។ ពួកគេពុំមាន រឺមានការជឿជាក់តិចតួចណាស់ទៅលើអាជ្ញាធរ និងចាត់ទុកអាជ្ញាធរជាអ្នកបង្កបញ្ហា ជាជាងជួយដោះស្រាយបញ្ហាដែលពួកគេជួបប្រទះ ។ ក្រុមយុវជនពលករចំណាកស្រុកផ្សេងទៀត ក៏បានរាយការណ៍ពីការមិនជឿជាក់នេះដែរ ។

---

១២ ការព្យាបាលបែបបុរាណសម្រាប់ជំងឺតូចតាច គឺគេយកសេនមួយលាបប្រេងឱសថ ហើយកោសលើខ្នងអ្នកជំងឺ ។ វិធីនេះ គេនិយមប្រើច្រើនណាស់នៅជនបទកម្ពុជា ។

តារាង ៤.៥: បញ្ហាប្រឈម និងការលំបាកដែលយុវជនពលករចំណាកស្រុកជួបប្រទះ

| ប្រភេទនៃការងារ | | តើការរស់នៅរបស់អ្នកជួបប្រទះការលំបាកអ្វីខ្លះ ? | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ការស្តីបន្ទោសពី ចៅហ្វាយ/អតិថិជន | ការធ្វើបាប ខាងរាងកាយ | ការមើលងាយ (គេថា អ្នករកស៊ីផ្លូវភេទ) | ការរើសអើង (គេថា ពលករស៊ីឈ្នួលថោកៗ) | ទំនាស់ជាមួយ អាជ្ញាធរ (ប៉ូលីស) | បញ្ហាប្រាក់កាស ជាមួយអតិថិជន | គ្មានបញ្ហា | |
| អ្នកបម្រើតុ ប្រុស/ស្រី | ប្រុស | 12 | 0 | 0 | 1 | | | 36 | 49 |
| | ស្រី | 17 | 1 | 2 | 4 | | | 47 | 71 |
| | សរុបរង | 29 | 1 | 2 | 5 | | | 83 | 120 |
| អ្នករត់ម៉ូតូឌុប | ប្រុស | 3 | 4 | | 19 | | 22 | 72 | 120 |
| | សរុបរង | 3 | 4 | | 19 | | 22 | 72 | 120 |
| កម្មករសំណង់ | ប្រុស | | 3 | | 9 | | | 98 | 110 |
| | ស្រី | | 0 | | 1 | | | 9 | 10 |
| | សរុបរង | | 3 | | 10 | | | 107 | 120 |
| កម្មករកាត់ដេរ | ប្រុស | | | | 0 | | | 15 | 15 |
| | ស្រី | | | | 6 | | | 99 | 105 |
| | សរុបរង | | | | 6 | | | 114 | 120 |
| កម្មករលាងរថយន្ត | ប្រុស | 2 | | | | | | 14 | 16 |
| | ស្រី | 0 | | | | | | 14 | 14 |
| | សរុបរង | 2 | | | | | | 28 | 30 |
| អ្នកលក់ដូរតូចតាច | ប្រុស | 1 | | | 0 | 0 | 0 | 8 | 9 |
| | ស្រី | 0 | | | 3 | 2 | 2 | 14 | 21 |
| | សរុបរង | 1 | | | 3 | 2 | 2 | 22 | 30 |
| បុគ្គលិកកាស៊ីណូ | ប្រុស | 0 | | | 0 | | | 5 | 5 |
| | ស្រី | 8 | | | 2 | | | 12 | 22 |
| | សរុបរង | 8 | | | 2 | | | 17 | 27 |
| អ្នកអូសរទេះ | ប្រុស | 1 | | | 3 | 11 | | 11 | 26 |
| | ស្រី | 1 | | | 0 | 1 | | 2 | 4 |
| | សរុបរង | 2 | | | 3 | 12 | | 13 | 30 |
| សរុប | ប្រុស | 19 | 7 | 0 | 32 | 11 | 22 | 259 | 350 |
| | ស្រី | 26 | 1 | 2 | 16 | 3 | 2 | 197 | 247 |
| | សរុបរង | 45 | 8 | 2 | 48 | 14 | 24 | 456 | 597 |

សម្ភាសន៍ជាមួយគ្រួសារនៃពលករចំណាកស្រុកនៅឯភូមិ បង្ហាញថា កម្មករប្រហែលពាក់កណ្តាលបានរាយការណ៍ពីការលំបាកដែលពួកគេបានជួបប្រទះទៅប្រាប់គ្រួសារ រីឯពាក់កណ្តាលទៀត មិនបានរាយការណ៍ទេ ។ ចំពោះការលំបាកដែលរាយការណ៍ឡើង លក្ខខណ្ឌការងារ ដូចជា ការងារពេលយប់ ការងារធ្ងន់ ម៉ោងធ្វើការវែង និងកន្លែងធ្វើការក្តៅស្អុះ មានចំនួន ៤៣% នៃបញ្ហាដែលបានរាយការណ៍ ។ ការងារមានប្រាក់ខែទាប ដែលមាន ៤០% ឈរនៅលំដាប់ទីពីរ ហើយការលំបាកក្នុងការស្នាក់នៅ មាន ១៤% ។ បញ្ហាគួរអោយកត់សំគាល់មួយទៀត គឺការស្តីបន្ទោសរបស់ថៅកែ រឺអ្នកគ្រប់គ្រង ។

*តារាង ៤.៦: ការលំបាកដែលយុវជនពលករចំណាកស្រុករាយការណ៍ទៅគ្រួសារ*

| ប្រភេទការងារ* | | លក្ខខណ្ឌការងារ | ប្រាក់ខែទាប | ការស្នាក់នៅ | ការស្តីបន្ទោសពីចៅហ្វាយ | សរុប |
|---|---|---|---|---|---|---|
| អ្នករត់ម៉ូតូឌុប | ប្រុស | 3 | 4 | 6 | | 13 |
| | សរុបរង | 3 | 4 | 6 | | 13 |
| កម្មករសំណង់ | ប្រុស | 1 | 5 | | | 6 |
| | ស្រី | 0 | 0 | | | 0 |
| | សរុបរង | 1 | 5 | | | 6 |
| កម្មករកាត់ដេរ | ប្រុស | 8 | 0 | | 0 | 8 |
| | ស្រី | 14 | 11 | | 1 | 26 |
| | សរុបរង | 22 | 11 | | 1 | 34 |
| កម្មករលាងរថយន្ត | ប្រុស | 1 | 5 | 3 | 1 | 10 |
| | ស្រី | 0 | 0 | 0 | 0 | 0 |
| | សរុបរង | 1 | 5 | 3 | 1 | 10 |
| សរុប | ប្រុស | 13 | 14 | 9 | 1 | 37 |
| | ស្រី | 14 | 11 | 0 | 1 | 26 |
| | សរុបរង | 27 | 25 | 9 | 2 | 63 |

* នៅអំឡុងពេលធ្វើអង្កេតគ្រួសារ ក្រុមស្រាវជ្រាវបានជួបជាមួយក្រុមគ្រួសាររបស់កម្មករតែបួនក្រុមប៉ុណ្ណោះ

## ៤.៧. ការដោះស្រាយបញ្ហា និងកិច្ចការពារខាងសង្គមកិច្ច

អ្នកឆ្លើយសំនួរស្ទើរពាក់កណ្តាល បានអោយដឹងថា ពួកគេតែងស្វែងរកជំនួយជ្រោមជ្រែងពីសាច់ញាតិ រឺក្រុមគ្រួសារនៅពេលជួបបញ្ហាក្នុងការងារ រឺជីវិត ។ មាន ២៥% បានទៅរកចៅកែ រឺអ្នកគ្រប់គ្រងផ្ទាល់ ហើយ ២០% ទៀត គ្មានអ្នកណាអាចពឹងពាក់បានក្រៅពីខ្លួនឯងឡើយ ។ ការធ្វើ FGD បានអោយដឹងថា អ្នកដែលគ្មានអ្នកណាអាចពឹងពាក់បាន ច្រើនតែជាពលករធ្វើចំណាកស្រុកតែម្នាក់ឯង និងគ្មានមិត្តភ័ក្តិ រឺសាច់ញាតិរស់នៅតំបន់ដែលខ្លួនស្នាក់នៅ ហើយពួកនេះតែងមានអារម្មណ៍អស់សង្ឃឹមជាខ្លាំង ។ ចំណុចគួរកត់សំគាល់មួយ គឺគ្មាននរណាម្នាក់ឆ្លើយថា អាជ្ញាធរជាអ្នកផ្តល់យុត្តិធម៌ រឺអ្នកជួយដោះស្រាយបញ្ហាឡើយ ។ យុវជនពលករចំណាកស្រុកទាំងនេះ ខ្វះកិច្ចការពារខាងសង្គមកិច្ចនៅក្នុងការងារ និងការរស់នៅរបស់ពួកគេ ។ ដោយសារកង្វះកិច្ចការពារខាងសង្គមកិច្ច ពួកគេត្រូវពឹងផ្អែកខ្លាំងលើទំនាក់ទំនងសង្គមផ្ទាល់ខ្លួនដែលបានសាងឡើងមុនពេលធ្វើចំណាកស្រុក រឺបន្ទាប់ពីពួកគេបានទៅដល់គោលដៅមួយរយៈពេលខ្លី ។

*ក្រាហ្វិក ៤.៣: ការដោះស្រាយបញ្ហា និងកិច្ចការពារខាងសង្គមកិច្ច*



# ជំពូកទី ៥ បន្ទុកចំណាយ និងផលប្រយោជន៍នៃចំណាកស្រុក

## ៥.១. ការងារនៅតំបន់ទីក្រុង

អង្កេតលើពលករងាយរងគ្រោះធ្វើឡើងដោយ វបសអ រៀងរាល់ត្រីមាស ចាប់តាំងពីឆ្នាំ១៩៩៨ មក បានបង្ហាញថា ពលករងាយរងគ្រោះប្រហែល ៩០% មកពីតំបន់ជនបទប្រទេសកម្ពុជា ។ ការងារដែលគេឱ្យតម្លៃទាប និងមានប្រាក់កម្រៃទាប ជាទូទៅ បានទៅលើពលករចំណាកស្រុកដែលភាគច្រើនជាយុវជន ដោយសារមូលហេតុជាច្រើន ។ យុវជនពលករចំណាកស្រុក ភាគច្រើន រឺទាំងអស់ គ្មានជំនាញទេ ដូច្នេះ មិនអាចរកការងារផ្សេងធ្វើបានឡើយ ។ ពួកគេត្រូវតែទទួលយកការងារគ្មានជំនាញ ដែលងាយរងគ្រោះខ្លាំងណាស់ ។

### ៥.១.១. អំឡុងពេលនៃការរស់នៅក្នុងទីក្រុង និងបម្រើការងារបច្ចុប្បន្ន

ជាមធ្យម យុវជនពលករចំណាកស្រុករស់នៅក្នុងទីក្រុងលើសពី ២២ខែបន្តិច ។ អ្នកឆ្លើយសម្ភាសន៍ ៧០នាក់ រស់នៅក្នុងទីក្រុងបានចំនួន ១២ខែ និង ៦៩នាក់ បាន ២ឆ្នាំ ។ អ្នកអូសរទេះអាចរស់នៅក្នុងទីក្រុងបានយូរជាងគេ គឺជាមធ្យម ៣៦,៤៧ខែ ។ បុគ្គលិកកាស៊ីណូ និងអ្នករត់ម៉ូតូឌុប អាចរស់នៅក្នុងទីក្រុងបានជាមធ្យម ៣៤,៣៣ខែ និង ៣១,៧៦ខែ ។ កម្មករសំណង់រស់នៅបានតិចខែជាងគេ គឺ ៩,១១ខែ ដោយសារលក្ខណៈការងារខាងសំណង់ ។

អ្នកឆ្លើយសម្ភាសន៍ មានអាយុជាមធ្យម ២១,០៤ឆ្នាំ ដែលបានន័យថា ពួកគេបានចាកចេញពីផ្ទះនៅអាយុ ១៩ឆ្នាំ ។ មានមូលហេតុជាច្រើនដែលធ្វើអោយពួកគេត្រូវរង់ចាំយ៉ាងយូរ ដើម្បីធ្វើចំណាកស្រុក ក្រោយពេលពួកគេបោះបង់ការសិក្សា នៅអាយុ ១៣ រឺ ១៤ឆ្នាំ ។ ទីមួយ ដោយសារនៅក្មេងពេក គ្រួសារភាគច្រើនមិនអនុញ្ញាតអោយកូនៗធ្វើចំណាកស្រុក ទៅរកការងារនៅទីក្រុង ដែលមាន "អំពើពាលា" ច្រើននោះទេ ជាពិសេសកូនស្រី ។ មូលហេតុមួយទៀត គឺត្រូវចំណាយពេលច្រើនលើការសាងទំនាក់ទំនង ។ ឪពុកម្តាយភាគច្រើន អនុញ្ញាតអោយកូនធ្វើចំណាកស្រុក លុះត្រាតែពួកគេមានទំនាក់ទំនងដែលអាចពឹងផ្អែក និងជឿទុកចិត្តបាន ។ មានយុវជនចំណាកស្រុកមួយចំនួនតូចប៉ុណ្ណោះ ដែលឆ្លើយថា បានធ្វើចំណាកស្រុកមកទីក្រុងដោយគ្មានបណ្តាញអ្វីទេ ។ មូលហេតុទីបី គឺត្រូវចំណាយពេលច្រើន ដើម្បីប្រមូលបានដើមទុនដ៏ចាំបាច់ ។

ជាមធ្យម យុវជនពលករចំណាកស្រុកបានចំណាយពេល ១៦,៩៨ខែ បម្រើការងារបច្ចុប្បន្នរបស់ពួកគេ ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ៦០០នាក់ មាន ៧៩នាក់ ចំណាយពេល ១២ខែ ធ្វើការងារបច្ចុប្បន្ន ។ គ្មានអ្វីប្លែកទេ ដែលយុវជនពលករចំណាកស្រុកមានអាយុក្រោម ២៤ឆ្នាំ គេធ្លាប់ធ្វើការបានរហូតដល់ ៨ ទៅ ១០ឆ្នាំ ។

ក្នុងចំណោមក្រុមគំរូតាងទាំង ៨ កម្មករកាត់ដេរ និងអ្នកអូសរទេះ បានចំណាយពេលយូរជាងគេក្នុងការងារបច្ចុប្បន្នរបស់ខ្លួន គឺលើសពី ២ឆ្នាំ ។ បុគ្គលិកកាស៊ីណូ អ្នករត់ម៉ូតូឌុប និងអ្នកលក់ដូរតូចតាច ចំណាយពេលពីមួយឆ្នាំទៅមួយឆ្នាំកន្លះ រីឯអ្នកបម្រើតុ កម្មករលាងរថយន្ត និងកម្មករសំណង់ បានចំណាយពេលតិចជាងមួយឆ្នាំ ។

*ក្រាហ្វិក ៥.១: ពេលវេលាជាមធ្យមចំណាយនៅទីក្រុង និងលើការងារបច្ចុប្បន្ន (ជាខែ)*




## ៥.១.២. រយៈពេលរំពឹងថានៅបម្រើការងារបច្ចុប្បន្ន

អ្នកឆ្លើយសម្ភាសន៍ជាង ៦០% ប្រាប់ថា ពួកគេមិនដឹងនៅបម្រើការងារបច្ចុប្បន្នបានយូរប៉ុណ្ណាទេ ។ មាន ១៣% ឆ្លើយថា នឹងនៅបម្រើការងារបច្ចុប្បន្នដោយគ្មានកាលកំណត់ ហើយ ២៧% ប្រាប់ថា បានកំណត់ច្បាស់ពីពេលវេលាត្រូវបម្រើការងារបច្ចុប្បន្ន ដែលមានចំនួនជាមធ្យម ១៥ខែ ។

*តារាង ៥.១: រយៈពេលរំពឹងថានៅបម្រើការងារបច្ចុប្បន្ន*

| | មិនដឹង | គ្មានកាលកំណត់ | មធ្យម | |
|---|---|---|---|---|
| | | | ខែ | ករណី |
| អ្នកបម្រើតុប្រុស/ស្រី | 79 | 10 | 12.29 | 31 |
| អ្នករត់ម៉ូតូឌុប | 72 | 19 | 16.76 | 29 |
| កម្មករសំណង់ | 60 | 12 | 9.87 | 48 |
| កម្មករកាត់ដេរ | 82 | 11 | 2137 | 27 |
| កម្មករលាងរថយន្ត | 15 | 6 | 16.77 | 9 |
| អ្នកលក់ដូរតូចតាច | 22 | 5 | 7.66 | 3 |
| បុគ្គលិកកាស៊ីណូ | 17 | 8 | 33.60 | 5 |
| អ្នកអូសរទេះ | 15 | 6 | 10.55 | 9 |
| សរុប | 362 | 77 | 15.13 | 161 |

សន្តិសុខការងារ ជាក្តីបារម្ភចំបងមួយ ។ ការងារដែលយុវជនចំណាកស្រុកទទួលបាន គឺជាការងារងាយប្រែប្រួល និងងាយរងគ្រោះ ដែលធ្វើឱ្យការរស់នៅរបស់ពួកគេ និងក្រុមគ្រួសារគ្មានលំនឹង ។ កម្មករមួយចំនួនធំមិនដឹងច្បាស់ទេថា នឹងនៅបម្រើការងារបច្ចុប្បន្នបានយូរប៉ុណ្ណា ហើយអ្នកនៅសល់ រំពឹងថា មិនចំណាយពេលយូរក្នុងការងារបច្ចុប្បន្នទេ ។ បុគ្គលិកកាស៊ីណូគ្រោងចំណាយពេលជាមធ្យមលើសពី ៣៣ខែ ដោយសារមានលក្ខខណ្ឌការងារល្អ (ការងារស្រាល និងប្រៀវត្សរ៍ខ្ពស់) ។ ហើយសូម្បីតែការងារកាត់ដេរដែលគេតែងសំគាល់ថា ជាការងារមានស្ថិរភាពជាងគេនោះ ក៏ពួកកម្មកររំពឹងថា អាចនៅបម្រើការងារមិនលើសពី ២ឆ្នាំឡើយ ។

## ៥.២. លក្ខខណ្ឌការងារ

ការងារដែលយុវជនមកពីជនបទធ្វើ ជារឿយៗ មានលក្ខណៈសំគាល់បីយ៉ាង: កខ្វក់ លំបាក និងគ្រោះថ្នាក់ ។ រឿងនេះហាក់ដូចមិនល្អសោះ នៅពេលគេដឹងថា ពលករភាគច្រើនណាស់ធ្វើការក្នុងវិស័យកាត់ដេរ និងសំណង់ ។ ការងាររបស់ពួកគេមានកម្រិតជំនាញទាប និងទទួលបានប្រាក់កម្រៃទាប ហើយយុវជននៅទីក្រុងភាគច្រើន មិនចាប់អារម្មណ៍លើការងារទាំងនេះទេ ។ នៅអំឡុងពេលធ្វើ FGD ពលករចំណាកស្រុកមួយចំនួន ទទួលស្គាល់ថា ការងារនៅទីក្រុងមិនលំបាកដូចការងារកសិកម្មនៅឯផ្ទះពួកគេទេ ។

### ៥.២.១. ចំនួនថ្ងៃធ្វើការក្នុងមួយសប្តាហ៍

ជារួម មានយុវជនពលករចំណាកស្រុកចំនួន ៧៧,៣៣% ឆ្លើយថា ត្រូវធ្វើការ ៧ថ្ងៃ/សប្តាហ៍ ហើយ ២១,៥០% ធ្វើការ ៦ថ្ងៃ/សប្តាហ៍ និងមានតែ ១,១៦% ដែលធ្វើការតិចជាង ៦ថ្ងៃ/សប្តាហ៍ ។ កម្មករលាងរថយន្ត អ្នកលក់ដូរតូចតាច អ្នកអូសរទេះទាំងអស់ និង ៩៥% នៃអ្នកបម្រើតុ ព្រមទាំងអ្នករត់ម៉ូតូឌុប ធ្វើការ ៧ថ្ងៃ/សប្តាហ៍ ។ មានតែកម្មករកាត់ដេរ និងបុគ្គលិកកាស៊ីណូទេ ដែលភាគច្រើនធ្វើការ ៦ថ្ងៃ/សប្តាហ៍ ។

*ក្រាហ្វិក ៥.២: ចំនួនថ្ងៃធ្វើការក្នុងមួយសប្តាហ៍របស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍*




### ៥.២.២. ម៉ោងធ្វើការក្នុងមួយថ្ងៃ

ជាមធ្យម ពលករឆ្លើយសម្ភាសន៍ ធ្វើការ ១០,៦២ម៉ោង/ថ្ងៃ ។ ក្រុមគំរូតាង ៣ក្រុម (អ្នករត់ម៉ូតូឌុប បុគ្គលិកកាស៊ីណូ និងកម្មករកាត់ដេរ) ធ្វើការជាមធ្យមលើសពី ១០ម៉ោង/ថ្ងៃ ។ អ្នករត់ម៉ូតូឌុបធ្វើការច្រើនម៉ោងជាងគេដល់ ១២,១៥ម៉ោង ។ កម្មករសំណង់ធ្វើការតិចម៉ោងជាងគេក្នុងចំណោម ៨ក្រុម ត្រឹមតែ ៨,៧៥ម៉ោង ។ ចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍របស់ក្រុមពលករចំណាកស្រុកទាំងនេះ វាច្រើនគួរឱ្យភ្ញាក់ផ្អើល គឺរហូតដល់ ៧២ម៉ោង/សប្តាហ៍ ។

ក្រាហ្វិក ៥.៣: ម៉ោងធ្វើការក្នុងមួយថ្ងៃរបស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍




## ៥.២.៣. ការពេញចិត្តចំពោះការងារ

ថ្វីបើត្រូវធ្វើការច្រើនម៉ោងក៏ដោយ កម្មករចំនួន ៦៨,០០% ឆ្លើយថា ពួកគេ "ពេញចិត្ត" ចំពោះការងារ និង ៧,៣៣% ឆ្លើយថា "ពេញចិត្តខ្លាំង" ។ មានតែកម្មករ ១៩,១៦%ប៉ុណ្ណោះ ដែលឆ្លើយថា "មិនពេញចិត្ត" និង ៥,៥០% ឆ្លើយថា "មិនពេញចិត្តសោះ" ចំពោះការងារ ។

ជាង ៨០% នៃកម្មករកាត់ដេរ កម្មករលាងរថយន្ត អ្នកបម្រើតុ និងកម្មករសំណង់ "ពេញចិត្តខ្លាំង" រឺ "ពេញចិត្ត" ចំពោះការងារ ពីព្រោះពួកគេមានរបាំងការពារច្រើនពីមជ្ឈដ្ឋានខាងក្រៅ ។ មានតែអ្នកអូសរទេះប៉ុណ្ណោះ ដែលមានយោបល់អវិជ្ជមានច្រើនជាងវិជ្ជមាន ដោយសារពួកគេត្រូវដោះស្រាយជាមួយខាងអាជ្ញាធរជាបន្ថែមពីលើការងារទៀត ហើយពួកគេក៏ជាក្រុមងាយរងគ្រោះបំផុតក្នុងចំណោមក្រុមគំរូតាងទាំង ៨ក្រុម ដែលបានសិក្សា ។

ក្រាហ្វិក ៥.៤: ការពេញចិត្តចំពោះការងាររបស់យុវជនពលករចំណាកស្រុកឆ្លើយសម្ភាសន៍



## ៥.៣. លក្ខខណ្ឌរកប្រាក់ចំណូល និងការរស់នៅ

### ៥.៣.១. ការរកប្រាក់ចំណូល

ជាទូទៅ យុវជនចំណាកស្រុកម្នាក់រកចំណូលបាន ៣០៧.៤០០រៀល/ខែ ។ ចំណូលជាមធ្យមនេះ មានកម្រិតខ្ពស់បន្តិច ដោយសារប្រាក់បៀវត្សរ៍ជាមធ្យមរបស់បុគ្គលិកកាស៊ីណូ វាខ្ពស់ដល់ ៦២១.៧០០រៀល ។ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់កម្មករលាងរថយន្ត គឺ ១០២.២០០រៀល ។ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់អ្នកបម្រើតុ មានចំនួន ១០០.០០០រៀល ប៉ុន្តែបូករួមនឹងប្រាក់អតិថិជនឱ្យក្រៅផង វាអាចឡើងដល់ ១៦៨.៩០០រៀល ។

*តារាង ៥.២: ការរកប្រាក់ចំណូលប្រចាំខែរបស់យុវជនពលករចំណាកស្រុក*

| ប្រភេទការងារ | ពាន់រៀល | ដុល្លារ |
|---|---|---|
| កម្មករលាងរថយន្ត | 102.2 | 24.92 |
| អ្នកបម្រើតុប្រុស/ស្រី | 168.9 | 41.19 |
| កម្មករកាត់ដេរ | 279.3 | 68.12 |
| កម្មករសំណង់ | 292.7 | 71.39 |
| អ្នកលក់ដូរតូចតាច | 356.3 | 86.90 |
| អ្នកអូសរទេះ | 381.1 | 92.95 |
| អ្នករត់ម៉ូតូឌុប | 430.8 | 105.07 |
| បុគ្គលិកកាស៊ីណូ | 621.7 | 151.63 |
| សរុប | 307.4 | 74.97 |

### ៥.៣.២. លំនាំចំណាយ

ការចំណាយជាងពាក់កណ្តាលរបស់យុវជនចំណាកស្រុក គឺទៅលើម្ហូបអាហារ ។ ម្ហូបអាហារឈរនៅលំដាប់ទីមួយសម្រាប់គ្រប់ក្រុមគំរូតាង លើកលែងតែកម្មករលាងរថយន្តដែលទទួលបានអាហារដោយឥតគិតថ្លៃពីម្ចាស់យានដ្ឋាន ។ ពួកពលករចំណាយអស់ ១៩០០រៀល/ខែសម្រាប់ការធ្វើដំណើរ ដែលបញ្ជាក់ម្តងទៀតថា ពួកគេមិនសូវធ្វើដំណើរច្រើនទេក្នុងទីក្រុង ។ ចំណាយជាមធ្យមលើការហូបចុកនៅខាងក្រៅនៅចុងសប្តាហ៍ គឺ ៧៨០០រៀល/ខែ ។ សរុបមក យុវជនពលករចំណាកស្រុកម្នាក់ចំណាយជាមធ្យម ១៤៥.៦០០រៀល/ខែ នៅទីក្រុងដែលសព្វសារពើមានថ្លៃខ្ពស់ ។ ក្រុមចំណាយតិចបំផុត គឺកម្មករលាងរថយន្ត និងក្រុមចំណាយច្រើនបំផុត គឺបុគ្គលិកកាស៊ីណូ ។

*តារាង ៥.៣: លំនាំចំណាយរបស់យុវជនពលករចំណាកស្រុក (ពាន់រៀល)*

| | មុខចំណាយ | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទការងារ | អាហារទៀងទាត់ | ហូបចុកខាងក្រៅ | ការធ្វើដំណើរ | ជួលផ្ទះ | សំលៀកបំពាក់ | ការថែទាំសុខភាព | ផ្សេងៗ | សរុប |
| អ្នកបម្រើតុ | 9.2 | 4.4 | 0.6 | 5.0 | 30.5 | 6.7 | 16.4 | 72.2 |
| អ្នករត់ម៉ូតូឌុប | 146.6 | 10.9 | 0.2 | 23.2 | 19.4 | 5.6 | 25.2 | 219.6 |
| កម្មករសំណង់ | 103.6 | 4.8 | 0.3 | 3.6 | 17.4 | 4.7 | 11.3 | 136.9 |
| កម្មករកាត់ដេរ | 77.1 | 8.1 | 1.4 | 20.6 | 20.8 | 6.1 | 15.2 | 149.1 |
| កម្មករលាងរថយន្ត | 0.00 | 3.4 | 0.00 | 0.00 | 19.0 | 0.7 | 5.9 | 28.0 |
| អ្នកលក់ដូរតូចតាច | 103.3 | 2.6 | 0.00 | 3.4 | 19.9 | 1.9 | 12.5 | 133.6 |
| បុគ្គលិកកាស៊ីណូ | 137.5 | 32.4 | 26.1 | 36.4 | 52.8 | 13.0 | 28.7 | 309.1 |
| អ្នកអូសរទេះ | 85.8 | 5.2 | 1.7 | 11.6 | 18.8 | 4.7 | 8.3 | 130.7 |
| សរុប | 84.0 | 7.8 | 1.9 | 13.0 | 23.1 | 5.6 | 16.4 | 145.6 |

### ៥.៣.៣. ការពេញចិត្តចំពោះប្រាក់ចំណូល

យុវជនពលករចំណាកស្រុកចំនួន ៨០% ឆ្លើយថា ពួកគេ "ពេញចិត្ត" ចំពោះប្រាក់ចំណូលដែលពួកគេរកបាន ។ ក្នុងគ្រប់ក្រុមពលករ លើកលែងតែក្រុមអ្នកអូសរទេះចេញ មាន ៧៥% ពេញចិត្តនឹងប្រាក់ចំណូលទទួលបាន ។ នៅពេលធ្វើសម្ភាសន៍ជាក្រុម ពួកគេនិយាយថា នេះជាលើកទីមួយហើយដែលពួកគេអាចរកប្រាក់ចំណូលបានដោយខ្លួនឯង ហើយប្រាក់ចំណូលរបស់ពួកគេមានចំនួនគ្រប់គ្រាន់សម្រាប់ម្ហូបអាហារ និងការចំណាយផ្សេងៗទៀត ហើយអាចនៅសល់ខ្លះសម្រាប់ផ្ដល់ឱ្យក្រុមគ្រួសារ ។ ចម្លើយជារឿយៗមួយ គឺពួកគេដឹងថា ពួកគេគ្មានជំនាញអ្វីច្រើនទេ ។

*ក្រាហ្វិក ៥.៥: ការពេញចិត្តចំពោះប្រាក់ចំណូល នៃយុវជនពលករចំណាកស្រុក*




ចំណូលរបស់យុវជនពលករមានកម្រិតខ្ពស់ បើធៀបនឹងប្រាក់ចំណូលគ្រួសារ ។ គ្រួសាររបស់យុវជនចំណាកស្រុកបានឆ្លើយនៅក្នុងអង្កេតគ្រួសារ ថា ពួកគេកាន់កាប់ដីជាមធ្យម ០,៧៥ហិកតាដែលអាចផលិតស្រូវបានជាមធ្យម ១,៥តោន/ឆ្នាំ[១៣] ។ ស្រូវមួយគីឡូក្រាម លក់បានថ្លៃ ៥០០រៀល ដូច្នេះ ផលស្រូវមានតម្លៃសរុប ៧៥០.០០០រៀល គឺទាបជាងប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមរបស់កម្មករលាងរថយន្តដែលជាក្រុមរកចំណូលបានតិចជាងគេនោះទៀត (១,២លានរៀល) ។

### ៥.៣.៤. ការចាកចេញដើម្បីជីវភាពប្រសើរឡើង

ពលករចំណាកស្រុកទាំងក្មេង ទាំងចាស់ បានចាកចេញពីភូមិ ដើម្បីឱ្យមានជីវភាពរស់នៅប្រសើរឡើង ។ នៅពេលស្នើឱ្យប្រៀបធៀបលក្ខខណ្ឌរស់នៅ នៅមុន និងនៅក្រោយពេលធ្វើចំណាកស្រុក មាន ៦,៥០% ឆ្លើយថា ជីវភាពរស់នៅរបស់ខ្លួន "ប្រសើរជាងមុនខ្លាំង" ៨០% ឆ្លើយថា "ប្រសើរជាងមុន" ៦,៦៧% ថា នៅដដែល ៦,៥០% ថា "លំបាកជាងមុន" និង ០,៣៣% ថា "លំបាកជាងមុនខ្លាំង" ។

អ្នកបម្រើតុ និងអ្នកអូសរទេះ មានចម្លើយអវិជ្ជមានច្រើនជាងគេ ដោយមានមិនដល់ ៦០% ទេ ប្រាប់ថា ជីវភាពរស់នៅរបស់ពួកគេបាន "ប្រសើរឡើង" និង "ប្រសើរឡើងខ្លាំង" ។ ចំពោះពលករ ៦ក្រុមទៀត អ្នកផ្ដល់ចម្លើយវិជ្ជមាន មានជាង ៨០% ។

---

១៣ ទិន្នផលជាមធ្យមនៅកម្ពុជា គឺ ១,៩៨តោន/ហិកតា យោងតាម "Cambodia Human Development Report 2007" បោះផ្សាយដោយក្រសួងផែនការ និង UNDP, p.67 ។

*ក្រាហ្វិក ៥.៦: ការចាកចេញដើម្បីជីវភាពប្រសើរឡើង*




"មានការងារធ្វើ" "អាចរកប្រាក់ចំណូលបាន" និង "មានអាហារគ្រប់គ្រាន់" គឺជាមូលហេតុដែលធ្វើអោយពួកគេផ្តល់ចម្លើយវិជ្ជមាន ក្នុងនេះ ការរកប្រាក់ចំណូលបាន គឺសំខាន់ជាងគេបំផុត ។ ចំពោះជនចំណាកស្រុកដែលផ្តល់ចំលើយអវិជ្ជមានពីស្ថានភាពរបស់ខ្លួន គេតែងលើកឡើងពីលក្ខខណ្ឌការងារមិនល្អ និងប្រាក់កំរៃការងារទាប ។

*តារាង ៥.៤: មូលហេតុធ្វើអោយជីវភាពរស់នៅប្រែប្រួល*

| | ប្រសើរឡើងខ្លាំង | ប្រសើរឡើង | នៅដដែល | លំបាកជាងមុន | លំបាកជាងមុនខ្លាំង | សរុប |
|---|---|---|---|---|---|---|
| មានការងារធ្វើ | 3 | 77 | 2 | 0 | 0 | 82 |
| អាចរកចំណូលបាន | 33 | 391 | 1 | 1 | 0 | 426 |
| មានអាហារគ្រប់គ្រាន់ | 3 | 6 | 0 | 0 | 0 | 9 |
| ការងារមិនធ្ងន់ពេក | 0 | 6 | 0 | 3 | 0 | 9 |
| ការងារច្រើនម៉ោងពេក | 0 | 0 | 1 | 10 | 0 | 11 |
| រកចំណូលបានតិចពេក | 0 | 0 | 33 | 19 | 2 | 54 |
| ការងារធ្ងន់ | 0 | 0 | 3 | 6 | 0 | 9 |
| សរុប | 39 | 480 | 40 | 39 | 2 | 600 |

# ជំពូកទី ៦ ផលប៉ះពាល់លើគ្រួសារ និងសហគមន៍របស់យុវជនចំណាកស្រុក

ចំណាកស្រុកអាចមានទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ទៅលើគ្រួសារ និងសហគមន៍ ដែលបញ្ជូនពលករចេញ ។ ចំណាកស្រុកផ្តល់ផលប្រយោជន៍ដល់គ្រួសារតាមរយៈប្រាក់ផ្ញើមកផ្ទះ ជំនាញ និងចំណេះដឹងដែលទទួលបាន ។ ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ ជះឥទ្ធិពលយ៉ាងច្រើនដល់សុខុមាលភាពគ្រួសារ និងការអភិវឌ្ឍសហគមន៍នាពេលអនាគត ។ ចំណុចអវិជ្ជមានចំបងគេនៃចំណាកស្រុក គឺកង្វះកម្លាំងពលកម្មសម្រាប់ការងារកសិកម្ម ។

## ៦.១. ប្រាក់ផ្ញើមកផ្ទះ

### ៦.១.១. *ភាគរយនៃយុវជនពលករចំណាកស្រុកដែលផ្ញើប្រាក់មកផ្ទះ*

ក្នុងចំណោមយុវជនពលករចំណាកស្រុក ៦០០នាក់ដែលឆ្លើយសម្ភាសន៍ មាន ៧០នាក់ បានធ្វើការតិចជាង ៣ខែ ។ ដូច្នេះពួកគេត្រូវបានដកចេញពីការវិភាគលើបញ្ហាពាក់ព័ន្ធនឹងប្រាក់ផ្ញើមកផ្ទះ ។

នៅពេលធ្វើ FGD ជាមួយឪពុកម្តាយ និងសាច់ញាតិរបស់យុវជនពលករចំណាកស្រុក ភាគច្រើននិយាយថា ការសម្រេចចិត្តធ្វើចំណាកស្រុក ជាការសម្រេចចិត្តរបស់គ្រួសារ ច្រើនជាងការសម្រេចចិត្តរបស់ជនចំណាកស្រុកផ្ទាល់ ។ ដូច្នេះ យុវជនចំណាកស្រុក គេចាកចេញទៅរកប្រាក់ដើម្បីគ្រួសារ ច្រើនជាងសម្រាប់ខ្លួនឯង ។

ក្នុងចំណោមយុវជនចំណាកស្រុក មានភាគច្រើនណាស់ ដល់ ៩៣,៣៨% បានផ្ញើប្រាក់មកផ្ទះ ។ ប៉ុន្តែដោយសារជនមួយចំនួនដែលមិនបានផ្ញើប្រាក់មកផ្ទះ គឺជាអ្នកដែលរស់នៅជាមួយគ្រួសារស្រាប់ ដូច្នេះ ភាគរយយុវជនដែលផ្តល់ប្រាក់ដល់ក្រុមគ្រួសារឡើងខ្ពស់ដល់ជិត ១០០% ។

អង្កេតគ្រួសារ បានបង្ហាញលទ្ធផលសឹងដូចគ្នា ពោលគឺគ្រួសារ ៩០,១២% ឆ្លើយថា បានទទួលប្រាក់ពីសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុក ។

*ក្រាហ្វិក ៦.១: ភាគរយយុវជនពលករចំណាកស្រុកដែលផ្ញើប្រាក់មកផ្ទះ*



## ៦.១.២. ភាពញឹកញាប់នៃការផ្ញើប្រាក់មកផ្ទះ

ការសិក្សាបង្ហាញថា យុវជនចំណាកស្រុកភាគច្រើន បានផ្ញើប្រាក់មកផ្ទះយ៉ាងទៀងទាត់ ។ អ្នកខ្លះផ្ញើប្រាក់មកផ្ទះនៅពេលសន្សំប្រាក់បានយ៉ាងច្រើន ឯអ្នកខ្លះទៀតផ្ញើប្រាក់មកផ្ទះនៅពេលបើកប្រាក់ខែបាន ។

គិតជាមធ្យម យុវជនពលករចំណាកស្រុកផ្ញើប្រាក់មកផ្ទះចំនួនមួយដង រៀងរាល់ ២,៣២ខែ ។ កម្មករមានប្រាក់បៀវត្សរ៍ផ្ញើប្រាក់មកផ្ទះបានញឹកញាប់ជាងកម្មករអ្នកគ្មានប្រាក់បៀវត្សរ៍ ។ ដោយឡែក គ្រួសារយុវជនចំណាកស្រុកបានរាយការណ៍ថា យុវជនចំណាកស្រុកផ្ញើប្រាក់មកផ្ទះរៀងរាល់ ១,៥៧ខែម្តង ។

*ក្រាហ្វិក ៦.២: ភាពញឹកញាប់នៃការផ្ញើប្រាក់មកផ្ទះ (គិតជាខែ)*




## ៦.១.៣. ចំនួនប្រាក់ផ្ញើក្នុងមួយលើក

យុវជនពលករចំណាកស្រុក បានរាយការណ៍ថា តែងផ្ញើប្រាក់ជាមធ្យម ១៤៨.៦០០រៀលក្នុងមួយលើក រីឯទិន្នន័យបានពីគ្រួសារមានការខុសគ្នាតែបន្តិចបន្តួច ដោយមានចំនួនជាមធ្យម ១១៤.៩០០រៀល ។ ចំនួនប្រាក់ផ្ញើមកផ្ទះ គិតជាមធ្យមខុសគ្នាយ៉ាងខ្លាំងទៅតាមក្រុមនីមួយៗ អាស្រ័យលើប្រាក់ចំណូល ។ កម្មករលាងរថយន្តផ្ញើប្រាក់ ៨៤.៧០០រៀលក្នុងមួយលើក រីឯបុគ្គលិកកាស៊ីណូដែលជាក្រុមរកចំណូលបានច្រើនជាងគេ ផ្ញើដល់ ២៨៤.០០០រៀលក្នុងមួយលើក ។

*ក្រាហ្វិក ៦.៣: ចំនួនប្រាក់ផ្ញើមកផ្ទះជាមធ្យមក្នុងមួយលើក (ពាន់រៀល)*



## ៦.១.៤. ចំនួនប្រាក់ផ្ញើមកផ្ទះក្នុងមួយឆ្នាំ

យុវជនពលករចំណាកស្រុក រាយការណ៍ថា ពួកគេផ្ញើប្រាក់មកគ្រួសារជាមធ្យម ១.០១២.៤០០រៀល/ឆ្នាំ ។ ប្រាក់ផ្ញើមានពី ៧៧៩.២០០រៀល សម្រាប់ក្រុមអ្នកបម្រើតុ ដល់ ២.៧៣៩.៧០០រៀល សម្រាប់ក្រុមបុគ្គលិកកាស៊ីណូ ។ ម្យ៉ាងទៀត អង្កេតគ្រួសារ បង្ហាញថា ពលករចំណាកស្រុកផ្ញើប្រាក់ជាមធ្យម ៩១៨.៩០០រៀល មកអោយគ្រួសារ ។ ទឹកប្រាក់នេះច្រើនគួរសមសម្រាប់ប្រជាជនកម្ពុជានៅជនបទ ហើយក្នុងករណីខ្លះ វាអាចជួយទ្រទ្រង់គ្រួសារបានទាំងស្រុងតែម្តង ។

*ក្រាហ្វិក ៦.៤: ប្រាក់ផ្ញើមកផ្ទះជាមធ្យមក្នុងមួយឆ្នាំ (ពាន់រៀល)*




## ៦.១.៥. ប្រាក់ផ្ញើមកផ្ទះគិតជាភាគរយនៃប្រាក់ចំណូល

ពលករឆ្លើយសម្ភាសន៍ បានផ្ញើប្រាក់មកផ្ទះជាមធ្យម ២៧,៤៤% នៃចំណូលសរុបរបស់ខ្លួន ។ ភាគរយនេះ ប្រែប្រួលខ្លាំងអាស្រ័យលើមុខរបរ ដោយមានចាប់ពី ១៥,៧៧% សម្រាប់ក្រុមអ្នករត់ម៉ូតូឌុប ដល់ ៧២,៩៦% សម្រាប់ក្រុមកម្មករលាងរថយន្ត ។ ចំណុចនេះ បញ្ជាក់ម្តងទៀតពីចំណងទាក់ទងយ៉ាងខ្លាំងរវាងតំបន់បញ្ជូនពលករចេញ និងតំបន់គោលដៅ ។

*តារាង ៦.១: ប្រាក់ផ្ញើជាចំណែកនៃប្រាក់ចំណូល*

| | ប្រាក់ផ្ញើប្រចាំឆ្នាំ (ពាន់រៀល) | ប្រាក់ចំណូលប្រចាំឆ្នាំ (ពាន់រៀល) | ប្រាក់ផ្ញើជាចំណែកនៃប្រាក់ចំណូល |
|---|---|---|---|
| អ្នករត់ម៉ូតូឌុប | 815.7 | 5169.6 | 15.77 |
| អ្នកលក់ដូរតូចតាច | 814.0 | 4275.6 | 19.04 |
| អ្នកអូសរទេះ | 1107.8 | 4573.2 | 24.22 |
| កម្មករសំណង់ | 1028.2 | 3512.4 | 29.27 |
| កម្មករកាត់ដេរ | 985.1 | 3351.6 | 29.39 |
| បុគ្គលិកកាស៊ីណូ | 2739.7 | 7460.4 | 36.72 |
| អ្នកបម្រើតុ | 779.2 | 2026.8 | 38.44 |
| កម្មករលាងរថយន្ត | 894.8 | 1226.4 | 72.96 |
| សរុប | 1012.4 | 3688.8 | 27.44 |

### ៦.១.៦. ច្រកផ្ញើប្រាក់មកផ្ទះ

ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើរតួនាទីតិចតួចក្នុងការផ្ញើប្រាក់មកផ្ទះ ដោយមានពលករតែ ៦,២៦% ប៉ុណ្ណោះដែលប្រើច្រកនេះ ។ ច្រកក្រៅផ្លូវការមានច្រើនជាងគេ ក្នុងនេះ ការផ្ញើតាមសាច់ញាតិ ការយកទៅខ្លួនឯងនៅពេលទៅលេងផ្ទះ និងការផ្ញើតាមមិត្តភ័ក្តិ រឺអ្នកភូមិ មាន ២៥% ស្មើៗគ្នា ។ ចំណុចគួរចាប់អារម្មណ៍ គឺយុវជនពលករចំណាកស្រុក ២,០២% មានសមាជិកគ្រួសារនៅភូមិឡើងមកយកប្រាក់ដោយផ្ទាល់ដល់កន្លែងពួកគេធ្វើការតែម្តង ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើរតួនាទីតែតិចតួច គឺដោយសារថ្លៃសេវាខ្ពស់ និងមានទម្រង់បែបបទសាំញ៉ាំ ។ ផ្ទុយទៅវិញ ការផ្ញើតាមរថយន្តតាក់ស៊ី និងសេវារបស់ហាងទូរស័ព្ទ មានភាពឆាប់រហ័ស និងបែបបទសាមញ្ញ ដែលទាក់ទាញពួកពលករឱ្យជ្រើសយកវិធីនេះ ។

*តារាង ៦.២: ច្រកផ្ញើប្រាក់*

| | ចំនួន | ភាគរយ |
|---|---|---|
| សមាជិកគ្រួសារឡើងមកយកប្រាក់ | 10 | 2.02 |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | 31 | 6.26 |
| សេវាទូរស័ព្ទ | 35 | 7.07 |
| អ្នកបើករថយន្តតាក់ស៊ី | 44 | 8.89 |
| មិត្តភ័ក្តិ/អ្នកភូមិ | 121 | 24.44 |
| យកទៅខ្លួនឯង | 124 | 25.05 |
| សាច់ញាតិ | 130 | 26.26 |
| សរុប | 495 | 100.00 |

### ៦.១.៧. ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ

ទំនាក់ទំនងរវាងភាពក្រីក្រ និងចំណាកស្រុក នៅតែជាបញ្ហាមួយស្មុគស្មាញណាស់ ។ ពិតហើយ ភាពក្រីក្រជាកត្តាចំបងមួយជំរុញអោយមានការធ្វើចំណាកស្រុក ហើយចំណាកស្រុកក៏អាចជួយកាត់បន្ថយភាពក្រីក្រដែរ ។ ការយល់ដឹងពីការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះរបស់គ្រួសារយុវជនចំណាកស្រុក មានសារៈសំខាន់បំផុត ដើម្បីស្វែងយល់ថា តើការធ្វើចំណាកស្រុកអាចជួយការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់សុខុមាលភាពគ្រួសារ និងសហគមន៍យ៉ាងដូចម្តេច ។ ការយក រឺមិនយកប្រាក់ផ្ញើមកបម្រើការងារផលិតកម្ម វាមានផលប៉ះពាល់យ៉ាងធំក្នុងរយៈពេលវែង ទៅលើក្រុមគ្រួសារ សហគមន៍ ព្រមទាំងពលករចំណាកស្រុកខ្លួនឯងថែមទៀត នៅពេលពួកគេត្រឡប់មកផ្ទះវិញ ។ នៅអំឡុងពេលធ្វើ FGD យុវជនពលករចំណាកស្រុកមិនបានដឹងច្បាស់ទេថា តើក្រុមគ្រួសារបានប្រើប្រាស់ប្រាក់ដែលពួកគេផ្ញើមកផ្ទះនោះយ៉ាងដូចម្តេច ។

យោងតាមអង្កេតលើពលករចំណាកស្រុក និងអង្កេតគ្រួសារ ក្រុមគ្រួសារប្រើប្រាស់ប្រាក់ផ្ញើ ទីមួយ ដើម្បីទិញម្ហូបអាហារ ទីពីរ ដើម្បីទិញទ្រព្យផលិតកម្ម (ដូចជា ពូជស្រូវ ជី គោក្របី រឺត្រាក់ទ័រ) និង ទីបី ដើម្បីចំណាយក្នុងពិធីផ្សេងៗ ដូចជាអាពាហ៍ពិពាហ៍ និងបុណ្យសាសនា ដែលមានញឹកញាប់ណាស់នៅជនបទកម្ពុជា ។ ចំណាយមួយទៀតដែលអាចចាត់ទុកថាជាចំណាយផលិតកម្មដែរ ទោះបីវាផ្តល់លទ្ធផលក្នុងរយៈពេលវែងក្តី គឺចំណាយលើការសិក្សា (ថ្លៃសាលារៀន ថ្លៃសៀវភៅ...) របស់បងប្អូនបង្កើត ដែលជាចំណាយទីបួនក្នុងអង្កេតលើយុវជនពលករចំណាកស្រុក និងជាចំណាយទីប្រាំក្នុងអង្កេតគ្រួសារ ។ ចំពោះការសងបំណុលគេ វាជាចំណាយទីបួននៅក្នុងអង្កេតគ្រួសារ និងចំណាយទីប្រាំក្នុងអង្កេតលើយុវជនចំណាកស្រុក ។

*ក្រាហ្វិក ៦.៥: ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ*




## ៦.១.៨. ផលប៉ះពាល់នៃប្រាក់ផ្ញើមកផ្ទះទៅលើគ្រួសារ និងសហគមន៍បញ្ជូនពលករ

ការសិក្សាបង្ហាញយ៉ាងច្បាស់ថា គ្រួសារយុវជនចំណាកស្រុកភាគច្រើន ទទួលបានផលប្រយោជន៍ពីការធ្វើចំណាកស្រុករបស់សមាជិក ប៉ុន្តែចំណាកស្រុកនេះ ជួយលើកស្ទួយជីវភាពបានយូរអង្វែង និងជួយកាត់បន្ថយភាពក្រីក្របានច្រើនប៉ុណ្ណា គឺជាបញ្ហាស្មុគស្មាញខ្លាំងណាស់ ។ ចាប់តាំងពីការរីកដុះដាលចំណាកស្រុករបស់យុវជន ពីជនបទទៅទីក្រុងនៅចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ មក គេឃើញមានលំហូរប្រាក់ផ្ញើយ៉ាងច្រើន ពីទីក្រុងទៅតំបន់ជនបទ ។ ប្រាក់ផ្ញើ ពិតជាជួយរក្សាស្ថិរភាពនៃជីវភាពនៅជនបទកម្ពុជា ។ ប៉ុន្តែសព្វថ្ងៃ មានទិន្នាការគួរអោយបារម្ភមួយក្នុងគ្រួសារនៅជនបទមួយចំនួនដែលទៅជាពឹងផ្អែកខ្លាំងពេកលើការធ្វើចំណាកស្រុករបស់សមាជិកគ្រួសារខ្លួន ។ នៅពេលធ្វើអង្កេតគ្រួសារតាមភូមិ ក្រុមស្រាវជ្រាវបានសង្កេតឃើញថា គ្រួសារមួយចំនួនមិនធ្វើការងារអ្វីទាំងអស់ ហើយរង់ចាំតែប្រាក់ផ្ញើមកពីទីក្រុង ។ ក្នុងករណីនេះ ចំណាកស្រុកមិនមែនជាប្រភពចំណូលបន្ថែមសម្រាប់គ្រួសារទេ ប៉ុន្តែជាប្រភពចំណូលតែមួយគត់ក្នុងគ្រួសារ ។ ការសិក្សាផ្សេងៗពីភាពក្រីក្រដែលធ្វើឡើងដោយ វបសអ បានបង្ហាញថា អ្នកក្រអាចចាកផុតពីភាពក្រីក្រ នៅពេលពួកគេអាចបង្កើនប្រភពចំណូល ដូច្នេះការបោះបង់ការងារស្រែចំការ ហើយរង់ចាំតែប្រាក់ដែលសមាជិកធ្វើចំណាកស្រុកផ្ញើមកឱ្យ អាចមានផលប៉ះពាល់អវិជ្ជមានទៅលើស្ថានភាពហិរញ្ញវត្ថុគ្រួសារ ។ បញ្ហាសំខាន់មួយទៀត គឺយុវជនពលករចំណាកស្រុកភាគច្រើន ជាកម្មករគ្មានជំនាញ រឺមានជំនាញតិចតួច ហើយការងាររបស់ពួកគេ មិនអាចធានាបានជាប់លាប់ឡើយ ។ ដូច្នេះ ការពឹងផ្អែកខ្លាំងពេកលើប្រាក់ផ្ញើមកផ្ទះអាចជាអន្ទាក់មួយ ។

ជាទូទៅ ចំណាកស្រុករបស់យុវជន មានផលប៉ះពាល់វិជ្ជមានខាងសេដ្ឋកិច្ចយ៉ាងធំទៅលើគ្រួសាររបស់ពួកគេ ។ ករណីរកការងារធ្វើមិនបាន រឺត្រូវគេបោកប្រាស់ អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់គ្រួសារ ប៉ុន្តែបរាជ័យនៃចំណាកស្រុកបែបនេះ មិនសូវមានញឹកញាប់ទេ បើធៀបនឹងចំណាកស្រុកឆ្លងប្រទេស ទោះបីគ្មានទំនាក់ទំនងសង្គមជាផ្លូវការ និងការការពារបានល្អក៏ដោយ ។ នៅពេលធ្វើសម្ភាសន៍ជាក្រុមជាមួយឪពុកម្តាយ រឺសាច់ញាតិ របស់ពលករចំណាកស្រុក គ្រួសារមួយចំនួនបានសារភាពថាពួកគេគ្មានធ្វើការអ្វីទេក្រៅតែពីរង់ចាំប្រាក់ដែលសមាជិកចំណាកស្រុកផ្ញើមកផ្ទះ ដើម្បីដោះស្រាយការចំណាយទាំងអស់ក្នុងគ្រួសារ ។ រឿងនេះបង្ហាញថា ក្នុងករណីខ្លះ ចំណាកស្រុកអាចជួយគ្រួសារអោយចាកផុត និងជៀសឆ្ងាយពីភាពក្រីក្រ ។ គ្រួសារដែលមានយុវជនពលករចំណាកស្រុក តែងមានស្ថិរភាពល្អជាងខាងហិរញ្ញវត្ថុ និងក្នុងករណីខ្លះ អាចឈានឡើងទៀតផង ប៉ុន្តែគ្រួសារក្រីក្របំផុត មិនមែនជាអ្នកដែលមានអត្រាធ្វើចំណាកស្រុកខ្ពស់ជាងគេនោះទេ ។

ប្រាក់ផ្ញើមកផ្ទះរបស់ពលករចំណាកស្រុក ក៏មានមានផលប៉ះពាល់វិជ្ជមានយ៉ាងច្បាស់ ទៅលើសហគមន៍បញ្ជូនចេញដែរ ដោយជួយជំរុញសេដ្ឋកិច្ចក្នុងមូលដ្ឋាន តាមរយៈការបង្កើតឡើងនូវអាជីវកម្ម និងពាណិជ្ជកម្មតូចៗថ្មីៗមួយចំនួន និងបង្កើនចំណាយប្រើប្រាស់ក្នុងគ្រួសារ ។ ភូមិដែលមានយុវជនពលករធ្វើចំណាកស្រុកច្រើននាក់ តែងមានសកម្មភាពសេដ្ឋកិច្ចច្រើនជាងភូមិដែលមានយុវជនពលករធ្វើចំណាកស្រុកតិចនាក់ ។

### ៦.១.៩. ការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុនៃគ្រួសារបញ្ជូនចេញ

ប្រាក់ផ្ញើមកផ្ទះ មានផលប៉ះពាល់វិជ្ជមានយ៉ាងច្បាស់ទៅលើស្ថានភាពហិរញ្ញវត្ថុគ្រួសារ ។ នៅពេលសាកសួរពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រួសារ ចាប់តាំងពីពេលមានសមាជិកគ្រួសារធ្វើចំណាកស្រុក មានគ្រួសារ ៨០% ឆ្លើយថា ហិរញ្ញវត្ថុគ្រួសារបានប្រសើរឡើង និងមានតែ ៧% ប៉ុណ្ណោះ ដែលនិយាយថា ហិរញ្ញវត្ថុគ្រួសារបានធ្លាក់ចុះ ។

*ក្រាហ្វិក ៦.៦: ការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុនៃគ្រួសារបញ្ជូនចេញ*




ក្រៅពីប្រាក់ផ្ញើមកផ្ទះ ចំណាកស្រុកមិនបានផ្តល់ផលប្រយោជន៍អ្វីច្រើនទៅឱ្យគ្រួសារ និងសហគមន៍អ្នកបញ្ជូនទេ ។ នៅពេលធ្វើ FGD ជាមួយអ្នកភូមិ មានអ្នកភូមិមួយចំនួនបានលើកឡើងថា តិរិយាបថរបស់យុវជនពលករចំណាកស្រុកចំពោះចាស់ទុំក្នុងភូមិ មិនមានប្រែប្រួលអ្វីច្រើនទេ ប៉ុន្តែមានមួយចំនួននិយាយថា ពួកគេបាននាំមកនូវវប្បធម៌ទំនើប (នារីចូលចិត្តស្លៀកខោខូយប៊យរឹបរាង ចូលចិត្តស្តាប់ចម្រៀងញាក់ជាងបទបុរាណ) ហើយចំណុចដែលធ្ងន់ធ្ងរ គឺពលករត្រឡប់មកផ្ទះវិញដោយក្លាយជាអ្នកញៀនថ្នាំ ។ ប៉ុន្តែករណីខ្លះៗនេះ មិនបានប៉ះពាល់អ្វីខ្លាំងដល់ផលប៉ះពាល់វិជ្ជមានជាទូទៅនៃចំណាកស្រុកនោះទេ ។

ការផ្ទេរជំនាញ និងបច្ចេកវិទ្យា តែងមានលើកឡើងជាទូទៅនៅក្នុងឯកសារ និងការស្រាវជ្រាវពីចំណាកស្រុក ។ ប៉ុន្តែការផ្ទេរជំនាញ និងបច្ចេកវិទ្យា តាមរយៈពលករចំណាកស្រុកដែលត្រឡប់មកផ្ទះវិញ គឺស្ទើរតែគ្មានសោះ ពីព្រោះមុខរបររបស់ពួកគេភាគច្រើន ជាមុខរបរគ្មានជំនាញ ។

ចំណាកស្រុកច្រើនគួរសម អាចបង្កការព្រួយបារម្ភពីកង្វះពលកម្មសម្រាប់កសិកម្ម ។ ប៉ុន្តែចំណាកស្រុកនៅកម្ពុជាមិនទាន់ឡើងដល់កម្រិតបង្កកង្វះខាតនៅជនបទនោះទេ ហើយក៏គ្មានភស្តុតាងណាមួយបង្ហាញថា សហគមន៍ដែលមានយុវជនធ្វើចំណាកស្រុកច្រើន កំពុងខ្វះខាតកម្លាំងពលកម្មសម្រាប់ធ្វើកសិកម្មនោះដែរ ។ ទោះយ៉ាងនេះក្តី គេឃើញច្បាស់ថា យុវជនយុវនារីនៅជនបទ គេចូលចិត្តការងារមិនមែនកសិកម្មនៅទីក្រុង ជាជាងការងារធ្វើស្រែចំការនៅក្នុងភូមិ ។

## ៦.២. ចំណងទាក់ទងជាមួយគ្រួសារ និងសហគមន៍អ្នកបញ្ជូន

### ៦.២.១. ការមកលេងផ្ទះ

នៅតាមតំបន់ផ្សេងៗក្នុងពិភពលោក ចំណាកស្រុកភាគច្រើនមានលក្ខណៈជារង្វង់ៈ ជនចំណាកស្រុកនៅតែរក្សាយ៉ាងយូរនូវចំណងទាក់ទងជាមួយកន្លែងដើមដែលពួកគេរស់នៅ ហើយក្រុមគ្រួសារ និងបណ្ដាញផ្ទាល់ខ្លួនផ្សេងទៀត មានសារៈសំខាន់បំផុតក្នុងការរក្សាចំណងទាក់ទងរវាងកន្លែងដើមទី និងកន្លែងគោលដៅចំណាកស្រុក (McDowell and Haan 1997: 15) ។ ចំណងទាក់ទងយ៉ាងខ្លាំងរវាងយុវជនពលករចំណាកស្រុក និងតំបន់ដើមដែលគេរស់នៅ គឺជាការរំពឹងទុកជាធម្មតានៅក្នុងសង្គមកម្ពុជាបែបបុរាណ ។ ការមកលេងផ្ទះញឹកញាប់ គឺជាសូចនាករសំខាន់ជាងគេ ដែលបង្ហាញពីកម្លាំងនៃទំនាក់ទំនងរវាងយុវជនពលករចំណាកស្រុក និងសហគមន៍អ្នកបញ្ជូន ។

តាមធម្មតា យុវជនពលករចំណាកស្រុកមកលេងផ្ទះ ២ដង/ឆ្នាំ ហើយអ្នកធ្វើដូច្នេះ មានជាង ២៥% និង មានជាង ១៣% ទៀតមកលេងផ្ទះ ១ដង/ឆ្នាំ ។ ពលករចំណាកស្រុកភាគច្រើន មកលេងផ្ទះយ៉ាងហោចណាស់ ១ដង/ឆ្នាំ ។ ជាទូទៅពួកគេមកលេងផ្ទះនៅថ្ងៃបុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ ដែលជាបុណ្យដ៏សំខាន់ក្នុងប្រតិទិនកម្ពុជា ។ រឿងនេះបានន័យថាជាទូទៅ ពួកគេប្រើប្រាស់ថ្ងៃឈប់សម្រាកដែលយូរ និងសំខាន់ជាងគេ នៅកន្លែងដើមដែលពួកគេរស់នៅ ។ គ្មាននរណាទទួលបានប្រាក់ឧបត្ថម្ភធ្វើដំណើរទេ ដូច្នេះ ពួកគេត្រូវចំណាយប្រាក់រកបានដោយលំបាក សម្រាប់ការធ្វើដំណើរ ។ចំណាយភាគច្រើនគឺថ្លៃរថយន្តឈ្នួល ដែលអាចកើនឡើងមួយជាពីរនៅថ្ងៃបុណ្យទាំងនេះ ។ ដំណើរនេះ បង្ហាញពីចំណងទាក់ទាក់ដ៏រឹងមាំរវាងយុវជនពលករចំណាកស្រុក និងសហគមន៍អ្នកបញ្ជូនពួកគេ ។

*តារាង ៦.៣: ចំនួនដងនៃការមកលេងផ្ទះរបស់យុវជនពលករចំណាកស្រុកបានឆ្លើយសម្ភាសន៍*

| | តាមរដូវ | | ជាអចិន្ត្រៃយ៍ | | សរុប | |
|---|---|---|---|---|---|---|
| ខែ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មិនធ្លាប់ | 0 | 0.00 | 10 | 2.25 | 10 | 1.66 |
| 0.5 | 2 | 1.29 | 0 | 0.00 | 2 | 0.33 |
| 1 | 27 | 17.42 | 21 | 4.72 | 48 | 8.00 |
| 2 | 22 | 14.19 | 24 | 5.39 | 46 | 7.66 |
| 3 | 14 | 9.03 | 48 | 10.78 | 62 | 10.33 |
| 4 | 9 | 5.80 | 31 | 6.96 | 40 | 6.66 |
| 5 | 3 | 1.93 | 15 | 3.37 | 18 | 3.00 |
| 6 | 21 | 13.55 | 133 | 29.88 | 154 | 25.66 |
| 7 | 0 | 0.00 | 3 | 0.67 | 3 | 0.50 |
| 8 | 0 | 0.00 | 1 | 0.22 | 1 | 0.16 |
| 12 | 3 | 1.93 | 78 | 17.53 | 81 | 13.50 |
| 24 | 0 | 0.00 | 4 | 0.90 | 4 | 0.66 |
| N.A | 54 | 34.84 | 77 | 17.30 | 131 | 21.83 |
| សរុប | 155 | 100.00 | 445 | 100.00 | 600 | 100.00 |

ដូចការរំពឹងទុក ពលករតាមរដូវទៅផ្ទះញឹកញាប់ជាងពលករអចិន្ត្រៃយ៍ ។ មួយភាគបីនៃពលករតាមរដូវ ទៅផ្ទះរៀងរាល់មួយខែ រីពីរខែម្ដង រីឯពលករអចិន្ត្រៃយ៍ ភាគច្រើនទៅផ្ទះនៅរៀងរាល់ ៦ខែម្ដង ។ ពលករ ១០នាក់ដែលពុំដែលទៅផ្ទះសោះ ស្ថិតក្នុងក្រុមពលករអចិន្ត្រៃយ៍ រីឯពលករ ៤នាក់ទៀត ដែលទៅផ្ទះ ២ឆ្នាំម្ដង ក៏ស្ថិតក្នុងក្រុមពលករអចិន្ត្រៃយ៍ដែរ ។

រយៈពេលមកលេងផ្ទះ ក៏អាចប្រើជាសញ្ញាបង្ហាញពីចំណងទាក់ទងដែលយុវជនពលករចំណាកស្រុករក្សាជាមួយកន្លែងដើមដែលគេរស់នៅផងដែរ ។ ជាមធ្យម យុវជនពលករចំណាកស្រុកចំណាយ ៥,៥៤ថ្ងៃ សម្រាប់ការមកលេងផ្ទះមួយលើក ។ យោងតាម FGD ពលករភាគច្រើន នៅលេងឯផ្ទះឱ្យបានយូរបំផុតទៅតាមចំនួនថ្ងៃឈប់សំរាកដែលបានអនុញ្ញាត ។

### ៦.២.២. កង្វះកម្លាំងពលកម្ម និងហិរញ្ញវត្ថុ

ក្នុងឯកសារមួយចំនួនស្តីពីចំណាកស្រុក លំហូរយុវជនយ៉ាងគំហុកទៅកាន់តំបន់ទីក្រុង អាចធ្វើឱ្យខ្វះកម្លាំងពលកម្មនៅក្នុងតំបន់ដើមរបស់ពួកគេ ។ ក្នុងកសិកម្មប្រើពលកម្មច្រើននៅកម្ពុជា កង្វះកម្លាំងពលកម្មអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កសិកម្មនៅតាមភូមិ ។ ប៉ុន្តែការសិក្សានេះ បង្ហាញថា ក្នុងចំណោមយុវជនពលករចំណាកស្រុក ៥នាក់ មាន ១នាក់ ជាពលករតាមរដូវ ដែលត្រឡប់ទៅផ្ទះវិញទៅតាមតម្រូវការការងារនៅឯផ្ទះ ជាពិសេសនៅពេលភ្ជួររាស់ និងដកស្ទូង ។ នៅអំឡុងពេលធ្វើអង្កេតគ្រួសារ ពួកគ្រួសារដែលមានសមាជិកជាពលករចំណាកស្រុកអចិន្ត្រៃយ៍នៅទីក្រុង គេបានរក្សាទុកកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់ធ្វើស្រែចំការ រីឯគ្រួសារដែលមិនបានធ្វើដូច្នេះ ពួកគេប្រើមធ្យោបាយផ្សេង ដូចជា ជួលកម្លាំងពលកម្មក្នុងភូមិ រឺមកពីភូមិនៅជិតនោះ ។ អង្កេតគ្រួសារ បង្ហាញថា គ្មានគ្រួសារណាមួយបានរាយការណ៍ រឹត្បិតញ្ញៃរពីកង្វះកម្លាំងពលកម្មធ្វើស្រែចំការឡើយ ។ សរុបមក នៅកម្ពុជា ការធ្វើចំណាកស្រុករបស់យុវជនពីជនបទទៅទីក្រុង មិនទាន់ឡើងដល់កម្រិតដែលបង្កកង្វះកម្លាំងពលកម្មនោះទេ ហើយក្នុងអនាគតកាលដែលអាចមើលឃើញ ក៏នៅតែមិនទាន់ដល់កម្រិតនេះដែរ ពីព្រោះហេតុផលសំខាន់បំផុតនៃចំណាកស្រុក គឺកង្វះការងារនៅឯផ្ទះ ហើយជនចំណាកស្រុកភាគច្រើន នឹងនៅក្នុងភូមិ បើសិនមានការងារធ្វើ ។

គ្រួសារនីមួយៗ ត្រូវមានដើមទុន ដើម្បីឱ្យសមាជិកអាចធ្វើចំណាកស្រុកបាន ។ ការសិក្សានេះ បង្ហាញថា ជាមធ្យម យុវជនពលករចំណាកស្រុកម្នាក់ ត្រូវចំណាយប្រាក់ ២៧.៨០០រៀល លើការធ្វើដំណើរ និងម្ហូបអាហារ គិតចាប់ពីពេលចាកចេញពីផ្ទះ រហូតរកបានការងារធ្វើ គឺច្រើនខ្លាំងណាស់សម្រាប់ប្រជាជនក្រីក្រនៅជនបទ ។ ការសិក្សាក៏បង្ហាញដែរថា ប្រាក់ដើមទុន ២០% បានមកពីកម្ចី ។ បញ្ហានេះ បង្កការបារម្ភពីកង្វះដើមទុនហិរញ្ញវត្ថុនៅក្នុងសហគមន៍បញ្ជូនចេញ ប៉ុន្តែការសិក្សាមិនមានភស្តុតាងអ្វីជាក់លាក់ពីកង្វះទុននេះទេ ។ គ្រួសារភាគច្រើនដែលខ្ចីប្រាក់គេដើម្បីឱ្យសមាជិកខ្លួនធ្វើចំណាកស្រុក ត្រូវសងប្រាក់នេះទៅគេវិញក្នុងអំឡុងពេលពី ៣ ទៅ ៦ខែ ។ បន្ទុកចំណាយនៃចំណាកស្រុក មានកម្រិតតិចតួចជាង បើធៀបនឹងលំហូរហិរញ្ញវត្ថុពីទីក្រុងទៅជនបទ ។

### ៦.២.៣. ជម្រើសការងារ

យុវជន-យុវនារីនៅជនបទ ភាគច្រើនដែលធ្វើចំណាកស្រុកទៅរកការងារធ្វើ តែងរកបានការងារមានជំនាញទាប រឺគ្មានជំនាញតែម្តង ដែលមានប្រាក់បៀវត្សរ៍តិច ប៉ុន្តែពួកគេគ្មានជម្រើសច្រើនទេ ។ នៅពេលសាកសួរពីការងារដែលពួកគេចង់បានជម្រើសទីមួយ និងច្រើនលើសលុបរបស់ពួកគេ គឺការធ្វើអាជីវកម្មតូចមួយ ។ ជម្រើសទីពីរ គឺចង់ក្លាយជាអ្នកបច្ចេកទេស ហើយជម្រើសទីបី គឺចង់ធ្វើការនៅការិយាល័យក្រុមហ៊ុនឯកជន ។ មានតែភាគរយតូចមួយប៉ុណ្ណោះ ដែលឆ្លើយថា ចង់ត្រឡប់ទៅធ្វើស្រែចំការវិញ ។ ពលករជាង ១០% មិនមានចក្ខុវិស័យសម្រាប់ថ្ងៃអនាគតទេ ដោយពួកគេមិនដឹងពីអ្វីដែលខ្លួនចង់ធ្វើ រឺក៏ "មិនដែលគិត" ពីការងារនៅថ្ងៃអនាគត ទោះបីត្រូវបានចុចសួរនៅពេលសម្ភាសក៏ដោយ ។ កម្មករកាត់ដេរជិត ២៥% ចង់យកជំនាញដែលខ្លួនទទួលបាន ដើម្បីបើកហាងកាត់ដេររបស់ខ្លួនផ្ទាល់ ។

*តារាង ៦.៤: ជម្រើសការងាររបស់យុវជនពលករចំណាកស្រុក*

| បំណងប្រាថ្នា | អ្នកលក់ | មន្ត្រីរាជការស៊ីវិល វិគ្រូបង្រៀន | អ្នកបច្ចេកទេស (ជួសជុលទូរស័ព្ទ រថយន្ត ម៉ូតូ) | ការងារនៅក្រុមហ៊ុនឯកជន | NGO | ធ្វើស្រែចំការ | មិនធ្លាប់គិត | មិនដឹង | ផ្សេងៗ | ហាងកាត់ដេរ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| អ្នកបម្រើតុ | 85 | 2 | 3 | 5 | 1 | 4 | 6 | 6 | 8 | 0 | 120 |
| អ្នករត់ម៉ូតូឌុប | 58 | 0 | 24 | 11 | 2 | 5 | 7 | 5 | 8 | 0 | 120 |
| កម្មករសំណង់ | 34 | 0 | 18 | 10 | 0 | 17 | 7 | 6 | 28 | 0 | 120 |
| កម្មករកាត់ដេរ | 60 | 1 | 2 | 3 | 0 | 7 | 1 | 10 | 7 | 29 | 120 |
| កម្មករលាងរថយន្ត | 4 | 0 | 0 | 1 | 0 | 4 | 0 | 6 | 15 | 0 | 30 |
| អ្នកលក់តូចតាច | 13 | 0 | 2 | 4 | 2 | 1 | 2 | 2 | 4 | 0 | 30 |
| បុគ្គលិកកាស៊ីណូ | 21 | 2 | 0 | 1 | 0 | 0 | 3 | 2 | 1 | 0 | 30 |
| អ្នកអូសរទេះ | 11 | 0 | 2 | 11 | 0 | 1 | 3 | 1 | 1 | 0 | 30 |
| សរុប | 286 | 5 | 51 | 46 | 5 | 39 | 29 | 38 | 72 | 29 | 600 |
| ភាគរយ | 47.66 | 0.83 | 8.50 | 7.66 | 0.83 | 6.50 | 4.83 | 6.33 | 12.00 | 4.83 | 100.00 |

## ៦.៧.៤. ផែនការទៅអនាគត

ទោះបីគ្មានទិន្នន័យអាចជឿជាក់បាន ស្តីពីចំនួនជាក់លាក់នៃយុវជនធ្វើចំណាកស្រុកពីជនបទទៅទីក្រុង និងពីទីក្រុងទៅជនបទក៏ដោយ ក៏គេគិតថា ចំណាកស្រុកពីជនបទទៅទីក្រុង មានច្រើនជាងពីទីក្រុងទៅជនបទ ។ អត្រាចំណាកស្រុកនៅតំបន់ទីក្រុង ច្រើនលើសនៅតំបន់ជនបទជាងពីរដង ។ ប្រជាជននៅទីក្រុងជាង ១៦% បានធ្វើចំណាកស្រុកក្នុងអំឡុង ៥ឆ្នាំចុងក្រោយនេះ រីឯប្រជាជននៅជនបទធ្វើចំណាកស្រុកមានត្រឹម ៧%[១៤] ។ ចំនួនពលករក្នុងវិស័យកសិកម្មធ្លាក់ចុះ រីឯពលករក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលផ្តុំគ្នានៅទីក្រុង បានកើនឡើងក្នុងទសវត្សរ៍ចុងក្រោយនេះ ។ ចំនួនប្រជាជននៅទីក្រុង ក៏បានកើនឡើងគួរកត់សំគាល់ដែរ នៅអំឡុងពេលដូចគ្នានេះ គឺចាប់ពីជាង ១០% នៅឆ្នាំ១៩៩៨ រហូតដល់ ១៧,៧% នៅឆ្នាំ២០០៥ ។

នៅឆ្នាំ២០០៦ វិស័យកាត់ដេរ សំណង់ និងសណ្ឋាគារ និងភោជនីយដ្ឋាន បានផ្តល់ការងារប្រហែល ៦៥០.០០០ ដែលភាគច្រើនបានទៅលើយុវជនមកពីជនបទប្រទេសកម្ពុជា ។ ផែនការអនាគតរបស់ពួកគេ (តើមានប៉ុន្មាននាក់មានផែនការរស់នៅជាអចិន្ត្រៃយ៍នៅទីក្រុង មានប៉ុន្មាននាក់មានផែនការទៅរស់នៅកន្លែងផ្សេង រឺត្រឡប់ទៅផ្ទះវិញ) មានផលប៉ះពាល់រយៈពេលវែងលើការផ្លាស់ប្តូរខាងប្រជាសាស្ត្រនេះ ។

យុវជនពលករឆ្លើយសម្ភាសន៍ ៥០% មានគម្រោងបន្តរស់នៅកន្លែងបច្ចុប្បន្ន និងមានជាង ២៥% គ្រោងត្រឡប់ទៅរស់នៅឯភូមិស្រុកដើមវិញ ។

១៤ NIS 2005, p. 38.

*ក្រាហ្វិក ៦.៧: ផែនការអនាគតរបស់យុវជនពលករចំណាកស្រុក*




នៅពេលធ្វើសម្ភាសន៍ជុំទីពីរ នៅតាមភូមិ ក្រុមស្រាវជ្រាវបានជួបជាមួយអ្នកត្រឡប់មកភូមិវិញមួយចំនួនតូច ។ មាននារីក្មេងម្នាក់ បានត្អូញត្អែរពីលក្ខខណ្ឌការងារដ៏លំបាក និងប្រាក់បៀវត្សរ៍តិចនៅឯរោងចក្រដែលនាងធ្វើការ ហើយប្រាប់ថា កង្វះលទ្ធភាពរកប្រាក់ចំណូល និងសន្សំប្រាក់បានច្រើន រួមទាំងការចង់ត្រឡប់មករស់នៅជួបជុំក្រុមគ្រួសារវិញផង បានជំរុញឱ្យនាងសម្រេចចិត្តត្រឡប់មកផ្ទះវិញ ។ អ្នកត្រឡប់មកផ្ទះវិញមួយចំនួនតូច បានលើកពីមូលហេតុខាងគ្រួសារ ដូចជា ការត្រូវមើលថែទាំឪពុកម្ដាយចាស់ជរា និងប្អូនតូចៗ រឺក៏ការវិលមករៀបការកសាងគ្រួសារ ។ ហេតុផលវិលមកផ្ទះវិញមានច្រើនបែបយ៉ាង ប៉ុន្តែមានបញ្ហាមួយលេចធ្លោជាងគេ គឺកង្វះប្រភពរកប្រាក់ចំណូលប្រកបដោយចីរភាព ។ ដូច្នេះ មានតម្រូវការធំណាស់នៃការបង្កើតការងារ ក្រៅពីការធ្វើស្រែចំការសម្រាប់អ្នកត្រឡប់មកផ្ទះវិញ ។

# ជំពូកទី ៧ សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ

ការធ្វើចំណាកស្រុកនៃកម្លាំងពលកម្ម មានផលប៉ះពាល់យ៉ាងធំ និងមានតួនាទីកាន់តែសំខាន់ឡើង ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ដែលមានប្រជាជនប្រហែល ៣៥% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ និងរកចំណូលបានតិចជាង ០,៥០ដុល្លារ/ថ្ងៃ ។ ប្រាក់ផ្ញើមកផ្ទះរបស់ជនចំណាកស្រុក មានចំនួនយ៉ាងច្រើន ហើយក្នុងករណីខ្លះ វាអាចផ្គត់ផ្គង់គ្រួសារនៅជនបទមួយបានពេញមួយឆ្នាំតែម្តង ។ កាលពីមុន គេចាត់ទុកចំណាកស្រុកជាប្រភពទីពីរ រឺទីបី នៃប្រាក់ចំណូលគ្រួសារ និងគ្រាន់តែជាប្រភពចំណូលបន្ថែមមួយប៉ុណ្ណោះ ប៉ុន្តែសម្រាប់គ្រួសារមួយចំនួន វាបានក្លាយជាប្រភពចំណូលដ៏ចំបងគេ ។ ចំណាកស្រុកបានជួយបង្កើនប្រភពចំណូល និងធ្វើអោយប្រជាជននៅជនបទអាចសន្សំប្រាក់បានខ្លះ ញ៉ាំងឱ្យពួកគេមានស្ថានភាពកាន់តែរឹងប៉ឹងក្នុងការទប់ទល់នឹងការប៉ះទង្គិចភ្លាមៗ ។ ប្រជាជនមួយចំនួន មានជីវភាពឈានឡើងដោយសារការលក់កម្លាំងពលកម្មនៅក្នុងខេត្តដទៃទៀត ។ គ្រួសារភាគច្រើនដែលមានសមាជិកធ្វើចំណាកស្រុក បានរាយការណ៍ថា ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនបានប្រែប្រួលល្អប្រសើរឡើង ។

លំហូរយុវជនពលករពីជនបទទៅទីក្រុងក្នុងប្រទេសកម្ពុជា នឹងមានជាបន្តតតថមថយទេក្នុងអនាគតកាលដែលអាចមើលឃើញ ។ ច្បាស់ណាស់ ចំណាកស្រុកមិនគួរមានការត្រួតត្រា រឺដាក់កំហិតអ្វីទេ ។ ការផ្គត់ផ្គង់កម្លាំងពលកម្ម ដែលគ្មានរឺមានជំនាញតិចតួចពីតំបន់ជនបទ មានច្រើនលើសតម្រូវការនៅទីក្រុងឆ្ងាយណាស់ ។ រឿងនេះមានន័យថា ការងារផ្សេងៗនៅមូលដ្ឋាន ក្រៅពីការធ្វើស្រែចំការ ត្រូវតែបង្កើតឡើងសម្រាប់ពួកយុវជននៅជនបទ ដែលកើនចំនួនរហូត ពីព្រោះការសិក្សាបានរកឃើញថា ពួកគេភាគច្រើនបានសម្រេចចិត្តធ្វើចំណាកស្រុក ដោយសារគ្មានការងារធ្វើឱ្យបានពេញៗមួយឆ្នាំនៅក្នុងភូមិស្រុកដើមរបស់ពួកគេ ។ ការសិក្សារកមិនឃើញមានភស្តុតាងអ្វីបង្ហាញពីកង្វះមូលធនហិរញ្ញវត្ថុ និងមូលធនមនុស្សនៅក្នុងភូមិដើមរបស់ជនចំណាកស្រុកទេ ប៉ុន្តែឃើញមានលំហូរទឹកប្រាក់ពីតំបន់ទីក្រុងទៅជនបទ ក្នុងទម្រង់ជាប្រាក់ផ្ញើមកផ្ទះ ។ ចំពោះការផ្ទេរជំនាញ និងបច្ចេកវិទ្យា តាមរយៈពលករចំណាកស្រុក ក៏មិនឃើញមានដែរ ។ ចំណាកស្រុកនៅកម្ពុជាមិនទាន់ឈានដល់កម្រិតធ្វើឱ្យខ្វះកម្លាំងពលកម្មនោះទេ ហើយនៅតាមភូមិបញ្ជូនពលករចេញ គឺនៅតែមានកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់ធ្វើស្រែចំការ ហើយគ្រួសារដែលគ្មានកម្លាំងពលកម្មគ្រប់គ្រាន់ គេអាចជួលពលករនៅក្នុងភូមិ រឺមកពីភូមិជិតខាង ។

ចំណាកស្រុក នៅតែជាបញ្ហាប្រឈមមួយធំ ដោយគេត្រូវប្រមែប្រមូលមូលធន និងកសាងបណ្តាញផ្សេងៗ ។ ការសិក្សាបង្ហាញថា មានយុវជនពលករចំណាកស្រុកតែមួយភាគតូចប៉ុណ្ណោះ ដែលមកពីគ្រួសារក្រីក្របំផុត ។ តម្រូវការមូលធន និងបណ្តាញ អាចរាំងស្ទះដល់អ្នកក្របំផុតក្នុងការធ្វើចំណាកស្រុក ដែលធ្វើឱ្យពួកគេបាត់បង់ប្រភពចំណូលមួយសម្រាប់ផ្គត់ផ្គង់គ្រួសារ ។ ការងារភាគច្រើនដែលពលករចំណាកស្រុកទទួលបាន មានប្រាក់កម្រៃទាប និងជាការងារថ្នាក់ទាប ដែលមិនសូវមានពលករអ្នកទីក្រុងធ្វើ ដូច្នេះ ពលករចំណាកស្រុកមិនបានប៉ះពាល់អ្វីច្រើនដល់ឱកាសការងាររបស់អ្នកទីក្រុងទេ ។ ទោះជាយ៉ាងនេះក្តី ការសម្របខ្លួនចូលក្នុងតំបន់ដែលពួកគេត្រូវស្នាក់នៅ នៅតែមានកម្រិតទាប ។ ពួកគេតែងឃុំខ្លួនឯងនៅកន្លែងធ្វើការ រឺកន្លែងស្នាក់នៅ ។ នៅពេលទំនេរ ពួកគេតែងទៅជួបសមាជិកគ្រួសារ សាច់ញាតិ រឺមិត្តភ័ក្តិដែលមកពីភូមិជាមួយគ្នា ។ មិត្តថ្មីដែលពួកគេស្គាល់ភាគច្រើន ក៏ជាពលករចំណាកស្រុកមកពីតំបន់ជនបទផ្សេងទៀត និងសឹងតែគ្មានអ្នកនៅទីក្រុងនោះទេ ។ ជាទូទៅ ពួកគេស្នាក់នៅផ្ទះជួល រឺផ្ទះតតមានបង់ថ្លៃ និងមានត្រឹមតែកន្លែងសម្រាប់ដេកប៉ុណ្ណោះ ។ ពួកគេភាគច្រើន គ្មានលទ្ធភាពចាយវាយទៅតាមស្តង់ដាររស់នៅកម្រិតខ្ពស់ដូចអ្នកទីក្រុងឡើយ ។ ពួកគេ

មិនចង់ចំណាយប្រាក់ទេ ដើម្បីអាចសន្សំប្រាក់ទុកផ្ញើមកអោយគ្រួសារនៅឯភូមិ ។ ចំណងទាក់ទងរវាងយុវជនពលករចំណាកស្រុក និងគ្រួសារពួកគេ មានលក្ខណៈខ្លាំងក្លា ដូចដែលអាចមើលឃើញតាមភាពញឹកញាប់នៃការទៅលេងផ្ទះ ភាពញឹកញាប់នៃការផ្ញើប្រាក់មកផ្ទះ ព្រមទាំងចំនួននៃទឹកប្រាក់ផ្ញើ ។

ក្នុងករណីភាគច្រើន បណ្តាញជួយសម្របសម្រួល និងការការពារជាផ្លូវការ គឺសឹងតែគ្មានសោះ ប៉ុន្តែបញ្ហានេះ មិនបានរារាំងដល់ចំណាកស្រុករបស់យុវជន ចេញពីជនបទមកទីក្រុងឡើយ ។ បណ្តាញក្រៅផ្លូវការ បានរីកធំឡើង និងដើរតួនាទីជំនួសបណ្តាញផ្លូវការ ។ ប៉ុន្តែដំណើរការបែបនេះ បង្កអោយមានការសម្របសម្រួលជាលក្ខណៈដាច់ដោយដុំដល់ការធ្វើចំណាកស្រុករបស់យុវជន ។ ពលករចំណាកស្រុក កម្រទទួលបានព័ត៌មានអាចទុកចិត្តបានអំពីលក្ខខណ្ឌការងារ រឺការរស់នៅឯតំបន់ទីក្រុងណាស់ ។ ព័ត៌មានតិចតួចដែលពួកគេទទួលបាន មុនពេលសម្រេចចិត្តធ្វើចំណាកស្រុក គឺព័ត៌មានអំពីការងារដែលអាចរកបាន ហើយព័ត៌មាននេះ ជាទូទៅមានខុសខ្លះទៀតផង ។ ការងារដែលយុវជនពលករចំណាកស្រុករកបានជាការងារងាយជួបបញ្ហាណាស់ ។ ពួកគេពិតជាត្រូវការកិច្ចការពារបន្ថែម ជាពិសេសពីសំណាក់អាជ្ញាធរ ។ ទោះជាយ៉ាងនេះក្តី គ្មានយុវជនពលករចំណាកស្រុកណាម្នាក់ ងាកទៅរកអាជ្ញាធរអោយជួយនៅពេលជួបបញ្ហាឡើយ ។

បញ្ហាចោទខាងគោលនយោបាយដ៏សំខាន់មួយ គឺតើការធ្វើចំណាកស្រុកនៃកម្លាំងពលកម្ម អាចជំនួសអោយការអភិវឌ្ឍតំបន់ជនបទនៅកម្ពុជាបានដែររឺទេ ។ ចំណាកស្រុក គឺជាដំណោះស្រាយរយៈពេលខ្លី រឺមធ្យម ជាជាងដំណោះស្រាយរយៈពេលវែង ។ ចំណាកស្រុកកម្លាំងពលកម្ម មិនអាចដោះស្រាយបានរួចភ្លាមនូវបញ្ហាកង្វះការងារមិនមែនកសិកម្ម នៅឯជនបទកម្ពុជាទេ ។ ដូច្នេះ គេត្រូវតែបង្កើតការងារផ្សេងៗទៀតនៅជនបទ ដើម្បីសម្រេចបានការអភិវឌ្ឍជនបទប្រកបដោយចីរភាព ។ ការអភិវឌ្ឍ តែងតែផ្សារភ្ជាប់ទៅនឹងកំណើនប្រជាជននៅទីក្រុង និងការថយចុះចំនួនប្រជាជននៅជនបទ ។ ចំណាកស្រុក ត្រូវតែមានលក្ខណៈអចិន្ត្រៃយ៍ ដើម្បីអោយប្រទេសមានការរីកលូតលាស់ ប៉ុន្តែចំណាកស្រុកមិនមែនសុទ្ធតែនាំឱ្យមានការអភិវឌ្ឍនោះទេ ។ អ្នកប្រាជ្ញខាងអភិវឌ្ឍន៍ជាច្រើននាក់ ដែលបានសរសេរអត្ថបទពីយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងឧស្សាហូបនីយកម្ម មានជំនឿថា វិស័យឧស្សាហកម្មត្រូវតែមានសកម្មភាពខ្លាំងក្លា និងរស់រវើក ដើម្បីអាចស្រូបយកពួកជនចំណាកស្រុកបាន ។

ដើម្បីធ្វើឱ្យចំណាកស្រុក មានភាពរលូន ទទួលបានផលខ្ពស់បំផុត ព្រមទាំងអាចការពារយុវជនពលករចំណាកស្រុកបានកាន់តែប្រសើរ វិធានការដូចខាងក្រោម គួរតែយកមកអនុវត្តៈ

(១) *ផ្តល់ការបណ្តុះបណ្តាលជំនាញដល់អ្នកត្រៀមធ្វើចំណាកស្រុកៈ* ការសិក្សាបង្ហាញច្បាស់ថា យុវជនពលករចំណាកស្រុក មានត្រឹមតែការអប់រំមូលដ្ឋានបន្តិចប៉ុណ្ណោះ ហើយស្ទើរតែគ្មានម្នាក់សោះ ដែលមានជំនាញដ៏ចាំបាច់សម្រាប់ឈានចូលទីផ្សារការងារ រឺបំពេញការងារមានជំនាញ និងមានប្រាក់កម្រៃខ្ពស់ឡើយ ។ ដោយសារគ្មានជំនាញ ពួកគេគ្មានជម្រើសអ្វីនៅក្នុងទីផ្សារការងារ ក្រៅពីការងារមានកម្រៃទាប និងការងារមានថ្នាក់ទាបប៉ុណ្ណោះ ។ ចំពោះពលករក្នុងវិស័យផ្លូវការ ដូចជា កម្មករសំណង់ជាដើម ពួកគេទទួលបានជំនាញតាមរយៈការបណ្តុះបណ្តាលភ្ជាប់នឹងការងារ ។ ចំពោះពលករក្នុងវិស័យមិនផ្លូវការ ដូចជា អ្នកអូសរទេះ អ្នកលក់ដូរតូចតាច ជាដើម ពួកគេបានបង្ហាញបំណងចង់ចូលទៅក្នុងវិស័យផ្លូវការ ប៉ុន្តែពុំអាចធ្វើដូច្នោះបាន ដោយសារខ្វះជំនាញដ៏ចាំបាច់ ។ ដូច្នេះ គួរតែផ្តល់ឱកាសកាន់តែច្រើនដល់យុវជនពលករមកពីជនបទ ដើម្បីទទួលបានជំនាញដ៏ចាំបាច់ តាមរយៈសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ។

(២) *ផ្តល់ការការពារកាន់តែប្រសើរដល់យុវជនពលករចំណាកស្រុកងាយរងគ្រោះៈ* គ្មានពលករចំណាកស្រុកណាម្នាក់ បានឆ្លើយសម្ភាសន៍ថា មានអាជ្ញាធរ រឺអង្គការមិនមែនរដ្ឋាភិបាល ដែលពួកគេអាចពឹងផ្អែកបាននៅពេលត្រូវជួបបញ្ហាឡើយ ។ យុវជនពលករ ហាក់មិនបានដឹងពីវត្តមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ ។ ការងាររបស់ពួកគេងាយរងគ្រោះខ្លាំងណាស់ ដូច្នេះ ត្រូវមានយន្តការការពារដ៏ខ្លាំងមួយ ។ អាជ្ញាធរពាក់ព័ន្ធ គួរជួយការពារយុវជនពលករចំណាកស្រុក ជាជាងគំរាមជំរិតយកប្រាក់ពីពួកគេ ។

(៣) ***ព័ត៌មានលំអិតគួរផ្តល់ទៅអោយយុវជនអ្នកត្រៀមធ្វើចំណាកស្រុក:*** ការសិក្សាបង្ហាញថា យុវជនពលករចំណាកស្រុកខ្វះខាតព័ត៌មានដ៏ចាំបាច់ នៅមុនពេលចាកចេញពីផ្ទះ និងក្នុងករណីខ្លះនៅក្រោយពេលបានទៅដល់គោលដៅទៀតផង ។ "ច្រកផ្តល់ព័ត៌មាន" គួរតែមានយ៉ាងហោចណាស់ នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដើម្បីផ្តល់អោយពួកយុវជននូវព័ត៌មានពីវត្តមានការងារ និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការងារ ព្រមទាំងព័ត៌មានពីលក្ខខណ្ឌធ្វើការងារ និងការរស់នៅឯទីក្រុង ។ ការផ្តល់ព័ត៌មានសុក្រឹត អាចជួយកាត់បន្ថយចំណាយ និងលទ្ធភាពត្រូវគេបោកប្រាស់ រឺរកការងារធ្វើមិនបាន ។

(៤) ***គួរបង្កើតបណ្តាញផ្លូវការ:*** ពួកយុវជនធ្វើចំណាកស្រុកគួរប្រើបណ្តាញក្រៅផ្លូវការ ។ ចំណាកស្រុកមិនគួរមានការត្រួតត្រា រឺដាក់កំហិតតឹងតែងទេ និងគួរទទួលបានការសម្របសម្រួល និងការជួយសម្រួលយ៉ាងច្រើន ។ បណ្តាញផ្លូវការគួរបង្កើតឡើង ដើម្បីជួយសម្រួល និងសម្របសម្រួលលំហូរពលករចំណាកស្រុកចេញពីតំបន់ជនបទ ។

(៥) *MFIs* ***គួរដើរតួនាទីសំខាន់:*** MFIs បានដើរតួនាទីតិចតួចបំផុត ក្នុងការជំរុញចំណាកស្រុកនៅកម្ពុជា ។ មានអ្នកក្រីក្របំផុតមួយចំនួន មិនធ្វើចំណាកស្រុកទេ ពីព្រោះមិនអាចប្រមែប្រមូលមូលធនហិរញ្ញវត្ថុបាន ។ *MFIs* អាចដើរតួនាទីសកម្មជាងនេះ ដើម្បីជួយអោយអ្នកក្រ និងអ្នកក្របំផុត មានលទ្ធភាពធ្វើចំណាកស្រុក ។ ក្រៅពីការផ្តល់កម្ចីមានអត្រាការប្រាក់ទាប *MFIs* អាចដើរតួនាទីជាច្រកបញ្ជូនប្រាក់ផ្ញើមកផ្ទះរបស់យុវជនចំណាកស្រុក ដោយបញ្ចុះថ្លៃសេវា និងកាត់បន្ថយភាពសាំញ៉ាំក្នុងការធ្វើលិខិតស្នាម ។

(៦) ***វិស័យក្រៅផ្លូវការមិនគួរមើលរំលងទេ:*** ពលករក្នុងវិស័យក្រៅផ្លូវការ តែងងាយរងគ្រោះ និងត្រូវការកិច្ចការពារច្រើនថែមទៀត ។ ទោះជាយ៉ាងនេះក្តី ពួកគេដើរតួនាទីសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច ។ ដូច្នេះ មិនគួរមើលរំលងពួកគេទេ ហើយគួរផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ពួកគេ ។

(៧) ***គួរបង្កើតការងារអោយបានច្រើនថែមទៀតនៅតំបន់ជនបទ:*** ជាទូទៅ ការងារធ្វើស្រែត្រូវចំណាយពេលតែ ៣ ទៅ ៦ខែប៉ុណ្ណោះ ។ ដូច្នេះ ត្រូវបង្កើតការងារដែលមានពេញៗមួយឆ្នាំនៅតំបន់ជនបទ ដើម្បីកាត់បន្ថយភាពគ្មានការងារធ្វើ រឺភាពគ្មានការងារធ្វើពេញលេញ ។ អ្នកវិលត្រឡប់មកភូមិវិញ ក៏ត្រូវការការងារដែរ ។

# ឯកសារយោង


Asian Migrant Centre (2004), Asian Migrant Yearbook 2003–2004 (Hong Kong: AMC)

CDRI (2007), *Moving Out of Poverty Study* (Phnom Penh: Cambodia Development Resource Institute)

CDRI (2007), *Participatory Poverty Assessment of the Tonle Sap* (Phnom Penh: Asian Development Bank and Cambodia Development Resource Institute)

Chan S. & So S. (1999), *Cambodian Labour Migration to Thailand: A Preliminary Assessment*, Working Paper 11 (Phnom Penh: Cambodia Development Resource Institute)

Dang, N.A. (2003) "Internal Migration Policies in the ESCAP Region", Asia-Pacific Population Journal, September

Department for International Development (DFID) 2004, "Migration and Development: How to Make Migration Work for Poverty Reduction", written evidence to International Development Committee, House of Common, sixth report, session 2003-04, Vol. II, House of Commons, DFID, the Stationery Office

Deshingkar P. (2005), "Maximising the Benefits of International Migration for Development", paper delivered to the conference Migration Development and Poverty Reduction in Asia, organised by IOM in Geneva

Development Analysis Network, (2001), *Labour Markets in Transitional Economies in Southeast Asia and Thailand* (Phnom Penh: Cambodia Development Resource Institute)

Godfrey, M., So S., Tep S., Pon D., Katz C., Acharya S., Sisowath D.C. & Hing T. (2001), *A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis*, Working Paper 18 (Phnom Penh: Cambodia Development Resource Institute)

International Organization for Migration (IOM) (2003), "Migration and Development: A Perspective from Asia", IOM Migration Research Series No. 14

International Organisation for Migration (2005), *Migration, Development and Poverty Reduction in Asia* (Geneva).

IOM (2003), "Labour Migration in Asia: Trend, Challenges and Policy Responses in Countries of Origin" (Phnom Penh: IOM).

Kim S.K. (2005), *Rural-Urban Migration in Cambodia. A Case Study: Migration to Phnom Penh* (Phnom Penh: Dept. of Sociology, Royal University of Phnom Penh).

Laczko F. (2005), "Migration, Development and Poverty in Asia", in IOM 2005

Lewis, A. (1994), "Development Economics in the 1950s", International Centre for Economic Growth, No. 2

Lewis, A. (1954), "Economic Development with Unlimited Supplies of Labour", The Manchester School of Economics and Social Studies, 22

Maltoni, B., (2006), "Review of Labour Migration Dynamics in Cambodia" (Phnom Penh: International Organisation for Migration)

McDowell, C., and de Haan, A. (1997), *Migration and Sustainable Livelihood: A Critical Review of the Literature*, Working Paper 65 (Institute of Development Studies)

McKenzie, D., (2006) "A Profile of the World's Young Developing Country Migrants", background paper to the 2007 World Development Report, Policy Research Working Paper 4021, Development Research Group, World Bank, October

Ministry of Planning and United Nations Development Programme (UNDP) Cambodia (2007), "Cambodia Human Development Report 2007: Expanding Choices for Rural People" (Ministry of Planning and UNDP)

National Institute of Statistics (2006), Statistical Yearbook 2006, (Phnom Penh: NIS, Ministry of Planning)

National Institute of Statistics (2004a), "Reclassification of Urban Areas in Cambodia", (Phnom Penh: NIS, Ministry of Planning

National Institute of Statistics (2004b), "Cambodia Inter-Censal Population Survey 2004, General Report," (Phnom Penh: NIS, Ministry of Planning)

National Institute of Statistics (2005), "Spatial Distribution and Migratory Movements: Analysis of Cambodia Inter-censal Population Survey 2004, Report 5" (Phnom Penh: NIS, Ministry of Planning)

Oishi Nana ()2002, "Gender and Migration and Integration Approach" (San Diego: University of California)

Sjaastad, Larry A. (1962), "The Costs and Returns of Human Migration", *Journal of Political Economy*, 70(5)

Stark, Oded, and David Levhari (1982), "On Migration and Risk in LDCs", *Economic Development and Cultural* Change, 31(1)

Todaro, M. (1989), *Economic Development in the Third World, fourth edition* (New York: Longman)

World Bank (May 2006), *Rural-Urban Migration in Developing Countries: 'A Survey of Theoretical Prediction s and Empirical Findings'*, Policy Research Working Paper 3915 (Washington DC: World Bank)

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖

ចំនួនជនចំណាកស្រុក និងជនចំណូលស្រុកនៅតាមខេត្ត

| | ជនចំណាកស្រុក | | ជនចំណូលស្រុក | |
|---|---|---|---|---|
| | GPCC 1998 | CIPS 2004 | GPCC 1998 | CIPS 2004 |
| បន្ទាយមានជ័យ | 49,072 | 72,575 | 69,532 | 113,304 |
| បាត់ដំបង | 113,573 | 162,383 | 68,848 | 136,746 |
| កំពង់ចាម | 147,672 | 179,088 | 109,750 | 91,744 |
| កំពង់ឆ្នាំង | 28,308 | 29,467 | 32,466 | 26,393 |
| កំពង់ស្ពឺ | 55,725 | 73,804 | 35,754 | 48,176 |
| កំពង់ធំ | 77,851 | 71,703 | 16,889 | 36,299 |
| កំពត | 72,512 | 103,336 | 17,636 | 33,242 |
| កណ្តាល | 177,619 | 179,564 | 127,104 | 152,862 |
| កោះកុង | 9,555 | 22,394 | 57,426 | 52,593 |
| ក្រចេះ | 25,416 | 25,203 | 22,596 | 23,717 |
| មណ្ឌលគិរី | 1,785 | 1,094 | 4,958 | 10,554 |
| ភ្នំពេញ | 80,794 | 113,463 | 395,246 | 363,429 |
| ព្រះវិហារ | 6,247 | 13,792 | 7,788 | 9,435 |
| ព្រៃវែង | 133,362 | 117,151 | 29,093 | 41,068 |
| ពោធិ៍សាត់ | 60,962 | 75,915 | 27,266 | 40,303 |
| រតនគិរី | 2,390 | 1,351 | 8,783 | 11,414 |
| សៀមរាប | 33,235 | 41,193 | 26,455 | 37,351 |
| ព្រះសីហនុ | 16,471 | 20,330 | 55,794 | 63,598 |
| ស្ទឹងត្រែង | 3,254 | 4,534 | 9,109 | 12,646 |
| ស្វាយរៀង | 45,745 | 52,565 | 94,950 | 97,797 |
| តាកែវ | 113,400 | 167,342 | 22,663 | 58,932 |
| ឧត្តរមានជ័យ | 12,228 | 17,180 | 11,172 | 35100 |
| កែប | 1,082 | 1,856 | 7,022 | 28,116 |
| ប៉ៃលិន | 2,179 | 5,560 | 12,142 | 28,024 |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

## ឧបសម្ព័ន្ធ ២៖

ចំនួនប្រជាជនឆ្នាំ ២០០៤ (គិតជា %)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

## ឧបសម្ព័ន្ធ ៣ៈ

*ការងារតាមវិស័យនៅក្នុងប្រទេសកម្ពុជា: ១៩៩៥–២០០៦ ( គិតជាពាន់ការងារ )*

| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | **4932** | **4456** | **4430** | **4909** | **5519** | **5275** | **6243** | **6571** | **6965** | **7496** | **7878** | **8053** |
| វិស័យកសិកម្ម | 4013 | 3482 | 3492 | 3771 | 4214 | 3889 | 4384 | 4426 | 4471 | 4520 | 4655 | 4619 |
| កសិកម្ម និងរុក្ខាប្រមាញ់ | 3964 | 3389 | 3413 | 3698 | 4109 | 3688 | 4123 | 4136 | 4147 | 4160 | 4255 | 4243 |
| នេសាទ | 49 | 94 | 79 | 73 | 105 | 147 | 261 | 291 | 323 | 360 | 400 | 376 |
| វិស័យឧស្សាហកម្ម | 142 | 211 | 210 | 216 | 352 | 444 | 640 | 741 | 835 | 947 | 1,059 | 1,169 |
| អាជីវកម្ម និងរ៉ែ | 6 | 1 | 8 | 6 | 5 | 3 | 4 | 15 | 16 | 17 | 19 | 20 |
| ផលិតកម្ម | 108 | 169 | 144 | 159 | 259 | 367 | 549 | 601 | 656 | 720 | 789 | 870 |
| ការផ្គត់ផ្គង់សាធារណៈ | 1 | 3 | 4 | 3 | 5 | 4 | 4 | 6 | 10 | 16 | 17 | 19 |
| សំណង់ | 27 | 38 | 54 | 48 | 83 | 70 | 84 | 120 | 153 | 195 | 234 | 260 |
| វិស័យសេវាកម្ម | 776 | 762 | 727 | 921 | 952 | 941 | 1219 | 1404 | 1659 | 2028 | 2163 | 2265 |
| ពាណិជ្ជកម្ម | 350 | 394 | 349 | 341 | 402 | 436 | 644 | 756 | 888 | 1042 | 1104 | 1140 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 11 | 7 | 6 | 15 | 28 | 19 | 10 | 24 | 27 | 30 | 43 | 61 |
| គមនាគមន៍ និងដឹកជញ្ជូន | 64 | 66 | 81 | 118 | 121 | 120 | 167 | 178 | 187 | 196 | 206 | 217 |
| អន្តរការីកម្មហិរញ្ញវត្ថុ | 5 | 4 | 11 | 1 | 5 | 8 | 6 | 9 | 12 | 16 | 23 | 32 |
| រដ្ឋបាលសាធារណៈ | 170 | 143 | 138 | 222 | 187 | 147 | 149 | 159 | 169 | 180 | 185 | 184 |
| ការអប់រំ | 86 | 61 | 56 | 81 | 88 | 87 | 88 | 94 | 100 | 106 | 113 | 120 |
| | ចំនួនសរុបគិតជាភាគរយ | | | | | | | | | | | |
| វិស័យកសិកម្ម | 81 | 78 | 79 | 77 | 76 | 74 | 70 | 67 | 64 | 60 | 59 | 57 |
| កសិកម្ម និងរុក្ខាប្រមាញ់ | 80 | 76 | 77 | 75 | 74 | 70 | 66 | 63 | 60 | 55 | 54 | 52 |
| នេសាទ | 1 | 2 | 2 | 1 | 2 | 3 | 4 | 4 | 5 | 5 | 5 | 4 |
| វិស័យឧស្សាហកម្ម | 3 | 5 | 5 | 4 | 6 | 8 | 10 | 11 | 12 | 13 | 13 | 14 |
| អាជីវកម្ម និងរ៉ែ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ផលិតកម្ម | 2 | 4 | 3 | 3 | 5 | 7 | 9 | 9 | 9 | 10 | 10 | 11 |
| ការផ្គត់ផ្គង់សាធារណៈ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| សំណង់ | 1 | 1 | 1 | 1 | 2 | 1 | 1 | 2 | 2 | 3 | 3 | 3 |
| វិស័យសេវាកម្ម | 16 | 17 | 16 | 19 | 17 | 18 | 20 | 21 | 24 | 27 | 27 | 28 |
| ពាណិជ្ជកម្ម | 7 | 9 | 8 | 7 | 7 | 8 | 10 | 12 | 13 | 14 | 14 | 14 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 1 | 1 |
| គមនាគមន៍ និងដឹកជញ្ជូន | 1 | 1 | 2 | 2 | 2 | 2 | 3 | 3 | 3 | 3 | 3 | 3 |
| អន្តរការីកម្មហិរញ្ញវត្ថុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| រដ្ឋបាលសាធារណៈ | 3 | 3 | 3 | 5 | 3 | 3 | 2 | 2 | 2 | 2 | 2 | 2 |
| ការអប់រំ | 2 | 1 | 1 | 2 | 2 | 2 | 1 | 1 | 1 | 1 | 1 | 1 |

*ប្រភព: អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ*

# បញ្ជីឯកសារពិភាក្សារបស់ វបសអ


១. Kannan, K. P. (វិច្ឆិកា 1995) ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា 1996) ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥ (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា1997) កំណែទម្រង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍកម្ពុជា (ឯកសារ ពិភាក្សាលេខ ៣) ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដួរីណា និងរ៉ូប៊ីន-ប៊ីដឺលវី (មិថុនា ១៩៩៨) ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរ ថ្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ 1998) សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សា លេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ 1998) ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ៃា (មករា ១៩៩៩) ប្រទេសកម្ពុជាៈ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ។

៩. តេង-យូគី ប៊ុន-ដួរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ តំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដួរីណា និង សុខ-ខេង (មិថុនា ១៩៩៩) បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាៈ ការពិនិត្យមើលជាទូទៅ (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃៈ ការប៉ាន់ស្មានជំហានដំបូង (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ៃា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍ៈ ទស្សនៈកម្ពុជា (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ឹង-ប៊ុនឡេង (សីហា ២០០០) ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) ប្រទេសកម្ពុជាៈ លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព ៖ នៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយៈ បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១0.000រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២000) កម្មសិទ្ធិការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជាៈ ការពិនិត្យវិភាគដោយត្រួសៗនូវ ទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.000រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរតំលៃ ៧.000រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ារី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង -ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២00១) ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជាៈ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែ តំរូវចំពោះវិបត្តិ (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរតំលៃ ៨.000រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ារី និង Sarthi Acharya (ធ្នូ ២00១) ការកាន់កាប់ដីនៅកម្ពុជាៈ ការវិភាគលើទិន្នន័យ ចុងក្រោយ (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២0. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ុំ-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២00២) ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២00២) ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ (ឯកសារពិភាក្សា លេខ ២១) តំលៃ ៨.000រៀល ។

២២. ច័ន្ទ-សុផលនិងSarthi Acharya (កក្កដា២00២) ការលក់ដូរដីធ្លីនៅកម្ពុជាៈ ការវិភាគទិន្នន័យនៃការផ្ទេរនិងការលក់ដូរដីធ្លី (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរតំលៃ ៨.000រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២00២) ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជាៈ ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរតំលៃ ១0.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២00២) ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជាៈ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.000រៀល ជាអង់គ្លេស តំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២00២) បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទៈ ការសិក្សាលើភូមិ ចំនួន ៩ នៅកម្ពុជា (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរតំលៃ ៨.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២00៣) ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មៈ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.000រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២00៣) ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃៈ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់ (ឯកសារពិភាក្សាលេខ២៧) ជាខ្មែរតំលៃ ៧.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជាៈ ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) ពាណិជ្ជកម្មត្រីក្នុងស្រុកៈ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ដុល្លារ ។

៣០. Caroline Hughes និង គីម សេតារា (មិថុនា ២០០៤) ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជាៈ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា (ឯកសារពិភាក្សា លេខ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទួត សុខផល្លី (ឧសភា ២០០៥) សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជាៈ ការសិក្សា ជំហានដំបូង (ឯកសារពិភាក្សាលេខ៣២) ភាសាខ្មែរ ៨.០០០រៀល ភាសាអង់គ្លេស ៥.០០ដុល្លារ ។

៣៣. Hansen, Kasper K. & Neth Top (December 2006), Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia.

៣៤. Pak Kimchoeun, Horng Vuthy, Eng Netra, Ann Sovatha, Kim Sedara, Jenny Knowles & David Craig (March 2007), Accountability and Neo-patrimonialism in Cambodia: A Critical Literature Review.

៣៥. Kim Sedara & Joakim Öjendal with the assistance of Ann Sovatha (May 2007), Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia.

ការផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត រមែងមានហានិភ័យ ជាពិសេសចំពោះពលករវ័យក្មេង ដោយពួកគេភាគច្រើនពុំធ្លាប់ចាកចេញឆ្ងាយពីភូមិកំណើតសោះ ហើយពួកគេថែមទាំងមានការអប់រំមូលដ្ឋានទាប និងគ្មាន រឺមានជំនាញតិចតួចប៉ុណ្ណោះ ។ ពិតហើយ មានហេតុផលជាក់ស្តែងមួយចំនួន ដែលធ្វើអោយយុវជនជាច្រើន ចាកចេញពីជនបទមកកាន់ទីក្រុង ។ ប៉ុន្តែ នៅមិនទាន់មានការស្វែងយល់អោយស៊ីជម្រៅនៅឡើយទេ អំពីដំណើរការចំណាកស្រុក ទំនាក់ទំនង លក្ខខណ្ឌរស់នៅនិងការងារ បញ្ហាប្រឈម និងការលំបាករបស់ពួកគេ រឺក៏ផលប៉ះពាល់នៃប្រាក់ផ្ញើមកផ្ទះ និងចំណាកស្រុក ទៅលើក្រុមគ្រួសារ និងសហគមន៏ ។ ការសិក្សាមានគោលដៅបំពេញនូវកង្វះខាតចំណេះដឹងទាំងនេះ តាមរយៈគោលបំណងជាក់លាក់ចំនួន ៥ (ក) ស្វែងយល់ពីសាវតារខាងសេដ្ឋកិច្ច-សង្គមកិច្ចរបស់គ្រួសារយុវជនចំណាកស្រុក (ខ) កំណត់ពីកត្តា និងកាលៈទេសៈ ដែលជំរុញអោយមានចំណាកស្រុក និងស្វែងយល់ពីបែបបទដែលយុវជនធ្វើការសម្រេចចិត្តធ្វើចំណាកស្រុក (គ) ពិនិត្យមើលពីតួនាទីនៃបណ្តាញសង្គមនៅក្នុងការជួយសម្រួលដល់ការធ្វើចំណាកស្រុក (ឃ) កំណត់ពីប្រភេទការងារផ្សេងៗនៅទីក្រុងសម្រាប់យុវជនចំណាកស្រុក និងការបញ្ចូលខ្លួនពួកគេទៅក្នុងការរស់នៅក្នុងទីក្រុង (ង) ស្វែងយល់ពីទំនាក់ទំនងរបស់ពួកគេជាមួយគ្រួសារដែលបញ្ជូនពួកគេមក និងផលប៉ះពាល់លើភាពក្រីក្រក្នុងគ្រួសារ និងសហគមន៏ពួកគេ ។






**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

☞ អាគារលេខ 56 ផ្លូវលេខ 315 ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រ 622 ភ្នំពេញ កម្ពុជា

☎ (855-23) 881-384/ 881-701/ 883-603 / 881-916

🖷 (855-23) 880-734

cdri@wicam.com.kh http://www.cdri.org.kh


តម្លៃ 6.000 រៀល


9789995052065